អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 13-Dec-2016, 14:11
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦**

**ម៉ោង ០៨:៥៩នាទី**

**សវនាការលើកទី៤៤៧**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម យ៉ា សុខន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឯម ហ៊ុយ

លោក ហាសាន អាធុរេលិយ៉ា
*(Mr.HARSHAN Athureliya)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង លាង

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

លោក លីវ សុវណ្ណា

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី គូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ហុង គឹមសួន

លោក វ៉េន ពៅ

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម យ៉ា សុខន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក សេង លាង | ខ្មែរ |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | អង់គ្លេស |
| លោកស្រី ស៊ីន សុវ៉ន | ខ្មែរ |
| លោក រ៉ិចឆ័រ កូប៉េ | អង់គ្លេស |
| លោក លីវ សុវណ្ណា | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក សេង សឿន (2-TCCP-219) | ខ្មែរ |
| លោកស្រី ជា ឌៀប (2-TCCP-286) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី៖ លោក សេង សឿន** (2-TCCP-219)


សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី .................................................................. ទំព័រ ៣

សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្ដើមពី.................................................................. ទំព័រ៣៥


**ការសួរសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី៖ លោកស្រី ជា ឡៀប** (2-TCCP-286)


សួរដោយប្រធានអង្គជំនុំ ផ្ដើមពី... ........................................................................ ទំព័រ ៤៣

សួរដោយលោកស្រី ស៊ីន សុវ៉ន ផ្ដើមពី.................................................................. ទំព័រ ៤៧

សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្ដើមពី.................................................... ទំព័រ ៦៤

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៨:៥៩:៤១]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងបន្តស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី សេង សឿន បញ្ចប់ ហើយនិងចាប់ផ្ដើមស្ដាប់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលមានរហស្សនាម 2-TCCP-286។

ក្រឡាបញ្ជីលោក ឯម ហ៊ុយ ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលទាំងឡាយដែលអង្គជំនុំជម្រះកោះអញ្ជើញចូលរួមក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវមកផ្ដល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះ គឺលោក សេង សឿន លោកមានវត្តមានរួចហើយនៅបន្ទប់សវនាការនេះ។ នៅថ្ងៃនេះដែរ មានដើមបណ្ដឹងរដ្ឋប្បវេណីបម្រុងមួយរូប ដែលមានរហស្សនាម 2-TCCP-286។ សូមអរគុណលោកប្រធាន។

[០៩:០១:៤៤]

**ប្រធានអង្គជំនុំ៖**

ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព

ឈឺក្បាល ឈឺចង្កេះមិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦។ មេធាវីការពារក្តីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះ មិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យ ព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា ថ្ងៃនេះមានអាការៈ ឈឺខ្នង ឈឺចង្កេះរ៉ាំរ៉ៃ អង្គុយយូរមិនបាន និងធ្វើឲ្យវិលមុខ និងបានផ្តល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

[០៩:០៣:០៦]

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅខាងក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅខាងក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ជាបន្ត អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅលោកមេធាវីក្តីលោក នួន ជា ក្នុងការតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម ហើយនិងភាគី ព្រមទាំងលោកដើមបណ្តឹងរដ្ឋប្បវេណី។

[០៩:០៤:០២]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ម្សិលមិញយើងបានផ្អាក <នៅពេល>យើង<>បានពិភាក្សាបញ្ហា<>នៃការអង្កេត ដែលលោកៗថា លោកមិនបានចូលរួម<>ស៊ើបអង្កេត អ្នកដែលបានលាក់ស្រូវអង្ករទុកឱ្យពួកកងទ័ពវៀតណាម<ទេ>។ អ៊ីចឹងខ្ញុំសូមសួរបន្តពីបញ្ហានេះតទៅទៀត។ តើលោកធ្លាប់បានចូលរួមក្នុងការស៊ើបអង្កេត ឬក៏ការស៊ើបអង្កេតមនុស្សទាំងឡាយដែលធ្វើអ្វីខុសនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**លោក សេង សឿន៖**

**ឆ៖** ខ្ញុំសូមជម្រាបខាងលោកមេធាវី ខ្ញុំមកដល់ខេត្តក្រចេះ ដូចបានជម្រាបហើយថា អត់បានពេញមួយខែសុទ្ធទេ ខ្វះប្រហែលជាបួនថ្ងៃអីបានគ្រប់មួយខែ។ អ៊ីចឹងរឿងអ្វីផ្សេងៗក្នុងខេត្តក្រចេះ ខ្ញុំបាទអត់បានដឹង អត់បានអីទេ។ ដូចខ្ញុំប្រាប់ជម្រាបហើយថា ខ្ញុំមកដល់ហ្នឹងមានតែភារកិច្ចតែមួយ មាសមុត គាត់ប្រើឱ្យប្រមូលទ័ពដែលកំពុងបាក់ពីយួនទៅព្រំដែនស្នួលនោះ។ បានដឹងតែប៉ុណ្ណឹងទេ ខ្ញុំ។

**ស៖** តើលោកធ្លាប់ចូលរួមក្នុងការចាប់ខ្លួនមនុស្សដែរឬទេ ហើយតើលោកខ្លួនឯងធ្លាប់ចាប់ខ្លួនអ្នកណាម្នាក់ដែរឬទេ?

**ឆ៖** ខ្ញុំអត់ដែលចាប់ចងអ្នកណាទេ ព្រោះការងារខ្ញុំអត់ដែលទទួលខាងហ្នឹងទេ រឿងចាប់ចងអីខ្ញុំខាងធ្វើបញ្ជី ខាងបញ្ជីម្រេយរបស់ស្រុក តែប៉ុណ្ណឹងឯង។

**ស៖** ម្សិលមិញលោកបាននិយាយអំពីហេតុការណ៍ដែលកើតឡើងនៅកោះគរ តើលោកស្គាល់មនុស្សដែលពាក់ព័ន្ធនឹងរឿងកោះគរ ហើយម្នាក់នុ៎ងឈ្មោះ ឈឹម។ ខ្ញុំមិនច្បាស់ថា ឈ្មោះនេះខ្ញុំអានត្រឹមត្រូវទេ ឈ្មោះ ឈឹម។ តើលោកស្គាល់គាត់ទេ បាទ ឈឹម?

[០៩:០៦:៤៩]

**ឆ៖** កាលនោះ ខ្ញុំអត់មានសិទ្ធិទេ តែគំនិតមួយចង់ដឹងកន្លែងគេយកមនុស្សទៅដាក់សម្លាប់ចោលនៅកោះគរហ្នឹង។ លួចពី -- អត់ឱ្យគណៈស្រុកដឹងទេ ទៅចង់ដឹងមើល ដល់តែឃើញទៅ ហេតុផ្ទាល់ ដល់អ៊ីចឹងខ្ញុំឃើញហើយ ដឹងហើយ មកម្ដងទៅ ក៏អត់ហ៊ានទៅជិត ទៅបៀត ហើយក៏មិនបានដឹងថាអ្នកណាឈ្មោះអីៗទេ ភ្លេចអស់ទៅហើយ។ ខ្ញុំគ្រាន់តែជួប*(ឮមិនច្បាស់)* ដែល អ្នកដែលគេយកទៅដាក់កន្លែងហ្នឹង ខ្ញុំដើរទៅមើលឃើញគាត់សុំបារីឱ្យខ្ញុំជក់ទៀត តែខ្ញុំភ្លេចបាត់ទៅហើយ។ ខ្ញុំបានដឹងប៉ុណ្ណឹង។ រួចលែងបាននៅទៅទៀតហើយ ផ្លាស់ទៅ មកក្រចេះបណ្ដោយមក។

**ស៖** សំណួររបស់ខ្ញុំ គឺច្បាស់។ ខ្ញុំសួរថា តើលោកស្គាល់មនុស្សដែលពាក់ព័ន្ធក្នុងហេតុការណ៍កោះគរដែរទេ ម្នាក់នោះឈ្មោះ ឈឹម?

**ឆ៖** ខ្ញុំទៅបានម្តង ហើយបានឃើញគេ ប៉ុន្តែមិនដឹងចាំឈ្មោះ មើលអ្នកដែលគេហៅមនុស្សចាប់ទៅហ្នឹងជាអ្នកមានទោសហ្នឹងបាទ។ ខ្ញុំអត់ដឹង ចាំឈ្មោះ តែខ្ញុំបានទៅឃើញម្តងកន្លែងហ្នឹង។

**ស៖** ដើម្បីឲ្យប្រាកដថា ខ្ញុំឲ្យសហសេវិកជាតិរបស់ខ្ញុំអានឈ្មោះឲ្យលោកស្តាប់ ក្រែងលោខ្ញុំអានទៅគេបកប្រែមិនច្បាស់ឲ្យលោកស្តាប់។

**លោក លីវ សុវណ្ណា៖**

បាទ សូមអនុញ្ញាតលោកប្រធាន គាត់ឈ្មោះ ជាម – ជាម។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** អ៊ីចឹងសំណួរខ្ញុំ ខ្ញុំសួរថា តើលោកស្គាល់គាត់ទេ គាត់ឈ្មោះ ជាម ដែលមេធាវីអានឲ្យលោកស្តាប់អំមិញ?

[០៩:០៩:០៩]

**លោក សេង សឿន៖**

**ឆ៖** ខ្ញុំដូចជាមិនច្បាស់ មានតែម្នាក់ទេ ខ្ញុំភ្លេចទាំងឈ្មោះទៀត គាត់ហ្នឹងគេធ្វើគណៈឃុំដែលគេចាប់ដែរ ខ្ញុំទៅផ្ទាល់ឃើញហ្នឹង ហើយសុំបារីខ្ញុំជក់ ខ្ញុំ -- គាត់ឈ្មោះ ភ្លេច -- ឈ្មោះនេះថាម៉េចមិនត្រូវទេ បានស្គាល់ហ្នឹងច្បាស់ហ្នឹង មុននឹងគេសម្លាប់ហ្នឹង ក្រោយមកខ្ញុំអត់ដឹងទេ ប៉ុន្តែវាជួបពេលហ្នឹង។ ខ្ញុំលួចទៅឃើញហ្នឹង វាហួសក្នុងចិត្ត មិនដឹងថាម៉េចទេ សុំបារីជក់នុំងខ្ញុំ ឲ្យបារីជក់។ ខ្ញុំគេចទៅកន្លែងអាប្រធានកោះគរហ្នឹង មកផ្ទះខ្ញុំនៅកន្លែងមន្ទីរខ្ញុំវិញមក ប៉ុណ្ណឹង។

**ស៖** បាទ លោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំអាចរំឭការចងចាំលោកបន្តិច។ ក្នុងបទសម្ភាសន៍ E3/5643 របស់មជ្ឈមណ្ឌលឯកសារកម្ពុជា <00753898>, ខ្មែរ00059404, ហើយបារាំង 0075 6648 "នៅកោះគរ គឺគួរឲ្យតក់ស្លុតណាស់។ សំណួរគេសួរថា តើអ្នកណាជាអ្នកទទួលបន្ទុកនៅពេលនោះ? ពេលនោះ លោកឆ្លើយថា "គឺ អាជាម នៅពេលនោះ។ ក្រោយមកៗ ខ្ញុំបានចាប់ខ្លួនគាត់។ សំណួរ៖ អ៊ូ! អ្នកឯងចាប់ខ្លួនគាត់? លោកឆ្លើយថា៖ ខ្ញុំចាប់ខ្លួន អាជាម។ សំណួរ៖ តើគាត់ធ្វើខុសអី? លោកឆ្លើយថា៖ គាត់បាន<ប្រឌិតចម្លើយសារភាព។ គាត់គ្រាន់តែសរសេរថា បុគ្គលម្នាក់នេះ មានទំនាក់ទំនងជាមួយបុគ្គលម្នាក់នោះ ប៉ុន្តែ>បន្ទាប់ពីស៊ើបទៅ យើងឃើញថា គាត់បានចាប់មនុស្សជា

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ច្រើន <ដូច្នេះហើយគាត់ត្រូវបាន>ចាប់ខ្លួន<>។" (ហើយទៅខាងក្រោមនោះតបន្តិចទៅទៀត)។ អ៊ីចឹងលោកដើមបណ្ដឹងរដ្ឋប្បវេណី តើខ្ញុំអានប៉ុណ្ណេះអាចរំឭកការចងចាំរបស់លោកបានដែរឬទេ?

[០៩:១១:៣៣]

**ឆ៖** បាទៗ នេះបានខ្ញុំចាំ។ ពេលនោះ ពិតមែន គឺបងគណៈស្រុកគាត់ប្រើខ្ញុំ ម្នាក់ទៀត បញ្ជាការស្រុកស្អាង ឲ្យខ្ញុំអ្នកភ្លង់ ឲ្យអាបញ្ជាការស្រុកអ្នកចង អាឈ្មោះអាចេត ម៉េចទេខ្ញុំភ្លេចហើយហ្នឹងប្រធានកោះគរ។ ហើយខ្ញុំដឹង ចេះតែសួរទៅបងគណៈស្រុកហ្នឹងថា បងឯងឲ្យចាប់វានេះរឿងអី? បានគាត់ប្រាប់ថា អាហ្នឹងវាបង្កើតចម្លើយ អាគ្នាអត់ដឹងផងចេះមកឆ្លើយដាក់គ្នាឯង ទៅតំបន់រាយ-ការណ៍ អត់ទៅចាប់គ្នានេះអស់ប៉ុន្មាននាក់ហើយ ប្រាកដហើយឥឡូវយកវាទៅដាក់ចោល។ អាហ្នឹងខ្ញុំធ្វើបានមែន ពេលហ្នឹងម្ដងហ្នឹងហើយ។

**ស៖** ប៉ុន្តែចម្លើយនោះ និយាយថា លោកខ្លួនឯងជាអ្នកចាប់ខ្លួនគាត់។ ឥឡូវនេះ លោកនិយាយថា លោកមិនចាប់ដោយផ្ទាល់ទេថា លោកបានចូលរួមភ្លង់ ចូលរួមអី។ អ៊ីចឹងថា តើអ្នកណាជាអ្នកចាប់ខ្លួន ជាម នោះដោយប្រាកដនោះ?

**ឆ៖** ខ្ញុំបញ្ជាក់ថា ភ្លង់ចាប់ហើយនិងចាប់ ពេលតែមួយ ព្រោះបញ្ជាពីគណៈស្រុក។ ដល់ចាប់ចងរួចហើយ គេដាក់ឡានទៅៗ ខ្ញុំក៏លែងដឹងអីទៀតទៅ បានតែប៉ុណ្ណឹងទេ ភារកិច្ចដែលខ្ញុំឆ្លើយ។

[០៩:១៣:៣៦]

**ស៖** ដូច្នេះ ខ្ញុំយល់ថា លោកបានចូលរួមក្នុងការចាប់ខ្លួនកម្មាភិបាល។ តើលោកអាចនឹងមានលទ្ធភាពដើម្បីដោះលែងសមាជិក<គ្រួសារ> ឬក៏អ្នកដែលត្រូវបានគេចាប់ខ្លួនដែរឬទេក្នុងកាលដែលលោកធ្វើការនៅទីនោះ?

**ឆ៖** ខ្ញុំអត់បានលែងអ្នកទោសអ្នកអី អត់ទេ។ បានម្ដងដែរ ដែលចាប់អាប្រធានគុក មានតែម្ដងហ្នឹង រួចអ្នកលែងណាណីដែលមានអីទៀត ខ្ញុំគ្មានសិទ្ធិអីទេ ខ្ញុំគ្រាន់បានឃើញគាត់ប្រើតែម្ដងហ្នឹងគណៈស្រុកហ្នឹង រួចក្រៅពីហ្នឹង ខ្ញុំអត់មានភារកិច្ចអីទៀតទេ។

**ស៖** អ៊ីចឹងខ្ញុំនឹងព្យាយាមដើម្បីរំឭកការចងចាំរបស់លោកបន្តិចទៀត។ នៅក្នុងបទសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាលោកបាននិយាយដូចតទៅ អង់គ្លេស 00753855, ខ្មែរ 00059350, បារាំង00796598*(ស៊ីក)*។ លោកបាននិយាយអំពីផែនការដើម្បីកម្ទេចជនជាតិចិន ហើយនិងវៀតណាម ហើយលោកនិយាយថា៖ "ខ្ញុំបានរៀបចំដើម្បីដោះលែងគ្រួសារពីរបី ដែលប្រពន្ធជាជនជាតិចិន ប្ដីជន

ជាតិខ្មែរ នៅពេលដែលគេយកប្រពន្ធទៅសម្លាប់ ហើយប្ដីបានមកជួបខ្ញុំសូមអន្តរាគមន៍ ហើយខ្ញុំយកឈ្មោះរបស់ពួកគាត់ ហើយខ្ញុំបញ្ជូនទៅឃុំ ហើយខ្ញុំអាចជួយបីប្អូនគ្រួសារនោះ។" បាទ ខ្ញុំអានប៉ុណ្ណេះ តើរំឭកដល់ការចងចាំរបស់លោកដែរឬទេ?

[០៩:១៥:៥៧]

**ឆ៖** រឿងហ្នឹងជារឿងជាពិត ប៉ុន្តែមិនមែនខ្ញុំដោះមនុស្សដែលគេដាក់គុកហើយលែងមកវិញទេ។ គឺម្នាក់នោះប្ដីជាទ័ពស្រុកស្អាង ឯប្រពន្ធមិនដឹងជាសុទ្ធ ឬមិនសុទ្ធទេ តែស្រាប់តែយំដាក់ខ្ញុំថាឲ្យជួយផងអាប្ដីនិងប្រពន្ធហ្នឹង។ បានខ្ញុំ ក៏មិនដឹងអីទេ ហើយចង់ដឹងមើលអាដែងមើលអាឈ្មោះដែលតាមឃុំគេឲ្យមក អ្អែងមើលខ្លួនឯងទៅអញមិនដឹងទេអ្វា! មើលឃើញទៅឈ្មោះហ្នឹង បើឃើញប្រាប់អញ។ ដល់វារកឆែកមើលទៅឃើញហ្នឹងបាន នេះយកសំបុត្រពីអញទៅឲ្យឃុំទៅ កុំឲ្យគេចាប់បញ្ជូនអ្អែងមក។ អានេះលើកទី១ ដែលខ្ញុំធ្វើ អត់មានទាន់គេថាលែងអ្នកទោសនៅឡើយទេ អត់មានទេ អានេះដឹងមុនរឿង។ ហើយមួយទៀត អាមួយធ្វើជាងរបស់ស្រុក ធ្វើឡានធ្វើអីហ្នឹង ដល់អ៊ីចឹង ខ្ញុំអត់ដឹងដែរ តែពេលហ្នឹង បងផុន ដែលគាត់គណៈស្រុកគាត់ថា សឿន ឯងធ្វើសំបុត្រប្រាប់ទៅមេឃុំ កុំឲ្យគេយកពុកម្ដាយអាជាងហ្នឹងទាំងម៉ែទាំងឪអីប្អូនសុទ្ធហ្នឹង កុំឲ្យយកគាត់មក ធ្វើសំបុត្រទៅ។ បាទ ខ្ញុំក៏ធ្វើតាមគាត់អ៊ីចឹងមក ក៏រួចខ្លួនទៅ។ អាហ្នឹងចុងក្រោយមុនគេផ្លាស់ទាំងគាត់ទាំងខ្ញុំមកក្រចេះ បានម្ដងហ្នឹងទេ។

[០៩:១៧:៤០]

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំមិនចូលទៅដល់សេចក្ដីលម្អិតច្រើនទៀតទេ ប៉ុន្តែក្នុងកម្រិតមួយចំនួនលោកបានចូលរួមក្នុងការដោះលែងមនុស្សប្រហែលពីរបីគ្រួសារ។ <យ៉ាងណាក៏ដោយ លោកមានតួនាទីពាក់ព័ន្ធនឹងការចាប់ ឬដោះលែងមនុស្សនេះ។> ហើយក្នុងឱកាសផ្សេងទៀត ហើយលោកបានចូលរួមក្នុងការចាប់ខ្លួនកម្មាភិបាលដែលថ្នាក់ខ្ពស់គួរសមដែរ ឈ្មោះថា ជាម។ អ៊ីចឹងថាតើលោកប្រាកដដែរឬទេ លោកមិនដែល<>ទទួលការណែនាំឲ្យស៊ើបអង្កេតអ្នកដែលបានលាក់ស្រូវអង្ករទុកឲ្យទាហានវៀតណាមនោះ?

**ឆ៖** បាទ ខ្ញុំអត់ដឹងទេ អារឿងការលាក់អង្ករលាក់អីហ្នឹង គឺខ្ញុំអត់ដឹងទេ។ ឯរឿងខ្ញុំបានធ្វើលិខិតមិនឲ្យគេចាប់ខ្លួនពីរគ្រួសារអាហ្នឹងខ្ញុំបានចាំ ហើយខ្ញុំបាននឹកឃើញកាលនោះរហូតមកដល់នេះតាមការរំឭករបស់តុលាការហ្នឹងមកឲ្យខ្ញុំដឹង អាហ្នឹងខ្ញុំបានធ្វើផ្ទាល់ដៃអត់មានទៅចាប់ទៅចងទេ គ្រាន់តែធ្វើសំបុត្រកុំឲ្យយកគាត់មកកន្លែងកោះគរ បានតែប៉ុណ្ណឹងទេ។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី ប្រជាជនខ្មែរ ឬក៏ខ្មែរកុម្មុយនីស្ដដែលបាន ចូលរួមទៅវៀតណាមក្នុងទសវត្សរ៍ឆ្នាំ៥០ ឬឆ្នាំ៦០នោះ <តើលោកស្គាល់អ្នកទាំងនោះទេ? បើ>លោកបានស្គាល់ <> តើលោកស្គាល់ឈ្មោះអ្នកណាខ្លះ?

**ឆ៖** ខ្ញុំអត់ ដូចជាគ្មានចាំ ឬក៏បានឃើញ បានដឹងទេ។ កាលខ្ញុំនៅទ័ព អត់ដែលដឹងទេ។ រហូតខ្ញុំពិការរហូតមកនេះខ្ញុំអត់ដែលទាក់ទិនអីហ្នឹងប្រជាជនអីណាឯណីទេបាទ ក្លាយទៅជាជនអ្នកពិការ នៅក្រវៀនៗហ្នឹងកន្លែងមន្ទីរហ្នឹង មានតែប៉ុណ្ណឹង។

[០៩:២០:២០]

**ស៖** បាទ អ៊ីចឹងយើងពិនិត្យមើលថាតើត្រឹមត្រូវដែរឬទេ។ ខ្ញុំនឹងអានដើម្បីរំឭការចងចាំរបស់លោកដើមបណ្ដឹងរដ្ឋប្បវេណី គឺថា គឺឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជាគឺ E3/5643 គឺ ERN <ភាសាអង់គ្លេស> 00753826, ភាសា<ខ្មែរ> 00059318, ហើយបារាំង <00756569> គឺមានសំណួរដែលសួរឈ្មោះ យ៉ា ដែលគាត់ជា<អតីតលេខា>ភូមិ<ភាគ>ព្លិសាន ហើយលោកបានឆ្លើយថា៖ "ទោះជាយ៉ាងណាក៏ដោយ ខ្ញុំមិនស្គាល់អនុរបស់គាត់ទេ <> ឬក៏អនុលេខាហ្នឹង<ទេ។ លេខាតំបន់នៅពេលនោះ> គឺច្របូកច្របល់។ គឺថាម្នាក់មកពីហាណូយត្រូវបានគេ<ជ្រើសរើស>។ គេហៅគាត់ថាតាហាណូយ នៅពេលនោះ។ គេសួរថា៖ តាអ្វី? ហើយលោកឆ្លើយថា គេហៅគាត់ថា តាហាណូយ។ គឺសំដៅខ្មែរ ដែលយួននៅហាណូយ<>បាន<ជ្រើសរើសយកទៅ>បណ្ដុះបណ្ដាលបំពាក់បំប៉ន<មុនឆ្នាំ១៩៤០ ឬឆ្នាំ៤៥។ ក្រោយមក អ្នកទាំងអស់នោះត្រូវបានគេអនុញ្ញាតឲ្យត្រឡប់មកវិញ ប៉ុន្តែអ្នកខ្លះបានក្លាយ>ជាលេខា<តំបន់>និងអនុលេខា<តំបន់។> គឺគេបានពង្រាយអ្នកទាំងអស់នោះទៅទូទាំងប្រទេសនៅពេលនោះ។" អ៊ីចឹងគឺថាតើលោក<នឹកឃើញអំពីអ្វីដែល>លោក<បាន>ឆ្លើយ<ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា អំពី>អ្នកទាំងនោះ <ដែលលោក>ថា តាហាណូយ <នោះទេ>?

**ឆ៖** បាទ ខ្ញុំសូមអរគុណ។ រឿងនេះខ្ញុំនឹកឃើញត្រូវហើយ។ គឺនឹកឃើញហើយក៏ចង់ទឹកភ្នែកដោយអាណិតគាត់ពេក។ នៅ ខ្ញុំគ្រប់គ្រងនៅអនុប្រធានមន្ទីរពិការតំបន់តាកែវ រហូតបាយទឹកអីៗគាត់ឃ្លានបង្អែមអ៊ីចឹង ក៏គាត់អត់មានជួបប្រពន្ធទៀតទេ ព្រោះវាភាគខាងជើងនោះ អត់មានតួនាទីទេ។ រហូតគេឲ្យឡើងទៅ គណៈតំបន់គេ មិនដឹងឈ្មោះអីទេ មកពេលហ្នឹង ប៉ុនដឹងប្រធានមន្ទីរពិការខ្ញុំ យ៉ាហ្នឹងគេប្រាប់ឲ្យជូនគាត់ទៅ។ ខ្ញុំជូនត្រឹមជាប់ត្រង់ហ្នឹង គេថាឲ្យឈប់គាត់ត្រង់ហ្នឹងទៅ។ គាត់លើកដៃសំពះ លាដៃខ្ញុំ យកកាំភ្លើងខ្លីកា៥៩ របស់គាត់ហ្នឹង "សឿន ឯងយកទុកចុះ! បងត្រឹមហ្នឹងហើយ ជីវិត

បងបានប៉ុណ្ណឹងទេ"។ អាហ្នឹង ខ្ញុំចាំហើយ នឹកអាណិតស្រឡាញ់ដូចបងបង្កើត។ ខ្ញុំនឹកច្បាស់រឿងរបស់ខ្ញុំហើយនិងគាត់។

[០៩:២៣:២៤]

**ស៖** មនុស្សម្នាក់ដែលលោកនិយាយអំពីគាត់នេះហ្នឹង តើគេអ្នកណា -- មានអ្នកណាម្នាក់បញ្ជាលោក ឬក៏ឲ្យលោកទៅចាប់ខ្លួនគាត់ហ្នឹង<ហើយសម្លាប់ចោល>ដែរឬទេ?

**ឆ៖** ខ្ញុំមិនដឹងថាអ្នកណាទេ ប៉ុន្តែប្រធានមន្ទីរពិការខ្ញុំ គេប្រាប់ខ្ញុំឲ្យនាំគាត់មកកន្លែងចំណុចត្រង់ណាដែលត្រូវខ្ញុំទៅជួប ទៅចាំគាត់ត្រង់ហ្នឹងទៅ ហើយឲ្យគេនៅចាំគាត់ហ្នឹងទៅ ខ្ញុំក៏ត្រឡប់ពីមកកន្លែងខ្ញុំវិញមក អត់ដឹងថាអ្នកណាអ្នកណីទៅទៀត លែងដឹងត្រឹមហ្នឹងហើយ។ បើគាត់ឲ្យកាំភ្លើងខ្លីមកខ្ញុំដែលគាត់កាន់កន្លងមកហ្នឹង ហុចឲ្យមកខ្ញុំទៅ។ ខ្ញុំក៏លាគាត់ចប់ត្រឹមហ្នឹងទៅ។

**ស៖** ប៉ុន្តែសំណួររបស់ខ្ញុំថាតើមានអ្នកណាម្នាក់បញ្ជា ឬណែនាំឲ្យលោកទៅចាប់ខ្លួនគាត់ ហើយយកទៅ ដើម្បីយកទៅសម្លាប់ដែរឬទេ?

**ឆ៖** អត់ទេ អត់មានបញ្ជាមកខ្ញុំ ហើយខ្ញុំទៅកាប់ទៅសម្លាប់អីទេ។ ខ្ញុំគ្រាន់តែនៅជាមួយគ្នាឯប្រធានមន្ទីរខ្ញុំ ព្រោះខ្ញុំអនុ គេឲ្យនាំគាត់ទៅអាកន្លែងមួយហ្នឹង ជិតហ្នឹងគេដាក់ទៅឡានម៉េចទេ ខ្ញុំបានត្រឹមហ្នឹង ក៏លាគ្នាត្រឹមហ្នឹងទៅ។ រឿងខ្ញុំចាប់ ក៏អត់ទៅ គេគ្រាន់តែជូនគាត់ពេលនោះ ទៅដល់ត្រឹមហ្នឹងទេ ប្រធានមន្ទីរគេបញ្ជាខ្ញុំ បានត្រឹមហ្នឹង។

[០៩:២៥:២៤]

**ស៖** អ៊ីចឹងខ្ញុំអានអ្វីដែលលោកបាននិយាយនៅក្នុងបទសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងឯកសារដដែល ដែលខ្ញុំបានយោងពីខាងដើម។ លោកឆ្លើយថា៖ "ខ្ញុំបានជួបពួកគាត់ម្នាក់ គឺតាហាណូយ ហើយគេបានបញ្ជាឲ្យខ្ញុំចាប់ខ្លួនគាត់ ហើយនិងសម្លាប់គាត់។ ខ្ញុំនិយាយថា ខ្ញុំពិបាកចាប់ខ្លួនគាត់ ដោយសារអី ខ្ញុំធ្លាប់ដេករស់នៅជាមួយគាត់។ <មុនពេលគាត់ត្រូវបានចាប់ខ្លួន គាត់យំ ហើយគាត់និយាយពាក្យថាគ្នាថា "គេនឹងសម្លាប់ខ្ញុំហើយ" ខ្ញុំមិនអាចធ្វើអ្វីទាំងអស់ដើម្បីជួយបាន>ទេ។" <លោកដើមបណ្តឹងរដ្ឋប្បវេណី នៅទីនេះលោកបាននិយាយថា គេបានស្នើសុំឲ្យលោកចាប់ និងសម្លាប់គាត់>។ <> តើក្នុងសម្តីដែលលោកឆ្លើយទៅមជ្ឈមណ្ឌលឯកសារកម្ពុជា ពិតជាត្រឹមត្រូវអ៊ីចឹងដែរ ឬយ៉ាងម៉េច?

**ឆ៖** ដូចខ្ញុំបញ្ជាក់អំមិញអ៊ីចឹង អត់ ដឹងថា ខ្ញុំមិនបានចាប់គាត់ទេ គេគ្រាន់តែយកគាត់ទៅកន្លែងគេដែលបញ្ជារបស់គណៈតំបន់ទេ ដែលគេទៅ*(ឮមិនច្បាស់)*ត្រង់ណា ទៅដាក់ត្រង់ណា សម្លាប់កន្លែង

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01364508



ណា លែងដឹងហើយ ខ្ញុំដឹងតែៗប៉ុណ្ណឹង ដែលគាត់លាខ្ញុំត្រឹមហ្នឹង ហើយយកកាំភ្លើងខ្លីយកមកឲ្យខ្ញុំ ហើយខ្ញុំយកទៅឲ្យប្រធានខ្ញុំទៅ។ ខ្ញុំដឹងតែប៉ុណ្ណឹង។

[០៩:២៦:៥៥]

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី តើលោកស្គាល់អ្នកណាដែលឈ្មោះ កង ចាប ដែរឬទេ? គាត់ធ្វើអ្វីកាលនោះ?

**ឆ៖** ខ្ញុំដូចជាប្រហាក់ប្រហែល ប៉ុន្តែមិនដែលនិយាយស្តីអីគ្នា ខ្ញុំនឹកឃើញ ប៉ុន្តែនឹកក៏ដូចមិននឹកដែរ ព្រោះថាគេសុទ្ធតែអ្នកថ្នាក់ខ្ពស់ ខ្ញុំមិនអាចទាក់ទងនិយាយគ្នាអីទេ។ ដូច ប៉ុន្តែដឹងឮឈ្មោះហ្នឹងប្រហាក់ប្រហែល ឥឡូវនឹកទៅឃើញទៅ។

**ស៖** បាទ។ លោកដើមបណ្តឹងរដ្ឋប្បវេណី តើលោកប្រាកដថាអីចឹងទេ? លោកប្រាកដជាមិនដឹងអ្វីច្រើនពី កង ចាប ប្រាកដអីចឹង ឬដូចម្តេច?

**ឆ៖** បាទ អត់ៗដឹងមែនហ្នឹង។ គ្រាន់តែដឹងស្គាល់ឈ្មោះ មិនដែលនិយាយរកគ្នាផង គាត់នៅមន្ទីរភូមិភាគនៅជាប់ ធ្វើជាមួយ តាម៉ុក អីហ្នឹង ហើយខ្ញុំអាចក់អាចែមហ្នឹង វាអត់សូវដឹងទេ គ្រាន់តែស្គាល់ ឮគេថា ឈ្មោះនេះ ឈ្មោះនោះអី ធ្លាប់ឃើញមុខ មិនដែលនិយាយគ្នាផងហ្នឹង។

[០៩:២៨:៣០]

**ស៖** បាទ លោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំនឹងអានរំឭកការចងចាំ គឺឯកសារមជ្ឈមណ្ឌលកម្ពុជា ERN អង់គ្លេស 00753883, ខ្មែរ 00059386, បារាំង 00796632*(ស៊ីក)*។ "សំណួរ៖ តើ កង ចាប ជាអនុរបស់ តាម៉ុក ឬ? លោកឆ្លើយថា៖ <ទេ>។ គាត់ជាវេជ្ជបណ្ឌិត គាត់ទទួលការបណ្តុះបណ្តាលមកពីវៀតណាម<ខាងជើង> ហើយជាចារកម្ម ឬក៏ជាគិញវៀតណាម។" នៅខាងក្រោមបន្តិចនេះ លោកនិយាយថា៖ "ដូចខ្ញុំនិយាយខាងលើ <> តាចាប ជាលេខាភូមិភាគឧត្តរ។ <>គាត់<ជាលេខា>តំបន់៣៥។ <សួរ៖ តំបន់៣៥? លោកឆ្លើយថា៖> អូ! គាត់មិនមែនជាពេទ្យទេ ខ្ញុំច្រឡំទេ។" លោកឆ្លើយអីចឹង។ តើខ្ញុំអានប៉ុណ្ណេះ លោកនឹកឃើញពីអ្វីដែលលោកបាននិយាយ ឬក៏លោកចងចាំទេ?

**ឆ៖** ខ្ញុំមិនប្រាកដ ក្រោយយូរពេកហើយ ប៉ុន្តែរឿងឈ្មោះហ្នឹង ខ្ញុំគ្រាន់តែដឹងថាឮ ឈ្មោះ កង ចាប ទៅនៅផ្លាស់ឯណា ទៅណាហ្នឹង ក៏ខ្ញុំភ្លេចបាត់អស់ហើយ ប៉ុន្តែគាត់ហ្នឹង ខ្ញុំមិនមែនជាអ្នកអនុអីអ្នកភូមិភាគទេ។ តាមដែលខ្ញុំមើលដឹង គាត់ហ្នឹងនៅខាងពេទ្យទេ តាមដែលខ្ញុំនឹកឃើញ។

[០៩:៣០:១៤]

**សះ** ប៉ុន្តែលោកនិយាយថា គាត់ទទួលការបណ្តុះបណ្តាលនៅវៀតណាម<ខាងជើង> ហើយក៏ជាគិញវៀតណាម។ <ហេតុអ្វីបានជាលោកនិយាយអីចឹង?> តើលោកមានប្រភពដំណឹង ព័ត៌មានមកពីណានិយាយថា <កង ចាប ទទួលការបណ្តុះបណ្តាលពីវៀតណាមខាងជើង និង>ជាចារកម្ម ឬក៏គិញវៀតណាម<>នោះ?

**ផះ** រឿងពាក្យថា "ចារកម្ម" ឬក៏ "គិញ"អីនេះ ខ្ញុំអត់បាននិយាយទេ ព្រោះក្នុងចិត្តក៏ខ្ញុំមិនបាននិយាយដែរ មិនដឹងគេចារកម្ម គេគិញអីរបស់ពីណា បើនិយាយថា ចាប់ពួកតាហាណូយ ភាគខាងជើងអី អាហ្នឹងបាននិយាយតែប៉ុណ្ណឹង អារឿងអីផ្សេងទៀត ដូចអត់មាននិយាយទេខ្ញុំ។

**សះ** ប៉ុន្តែលោក<មិន>បាន<និយាយថា លោកបានឮទេ។ លោកពិតជាបាន>ឆ្លើយទៅមជ្ឈមណ្ឌលឯកសារកម្ពុជាថា គាត់ជាគិញវៀតណាមខាងជើង។ ហើយខ្ញុំសួរថាតើលោកបានព័ត៌មាននេះមកពីណា លោកដឹងដោយវិធីណា ដែលលោកបានឆ្លើយបែបនេះកើត?

**ផះ** មិនបាននិយាយពេលនោះទេ ខ្ញុំអត់ ដូចថាអត់ដឹងតែម្តង ខ្ញុំបាទបើនិយាយប្រាជ្ញព្រោកគ្នាលេង ថានិយាយពីរឿងពួកខាងជើងអាហ្នឹង តាហាណូយ អាហ្នឹងនិយាយ អាផ្សេងទៀតហ្នឹង ខ្ញុំអត់បានដឹងទេ ក៏អត់បាននិយាយទៀតផង។

[០៩:៣២:០៥]

**សះ** នៅក្នុងសំណួរដដែល <អ្នក>សម្ភាសន៍គេសួរលោកអំពី តាម៉ុក។ តើលោកចាំទេថាតាម៉ុកគាត់មានតំណែងជាអ្វី តើលក្ខណៈសម្បត្តិ ឬក៏ តាម៉ុក ជាមនុស្សបែបម៉េចដែរ?

**ផះ** រឿងតាម៉ុក នោះខ្ញុំមិនដឹងប្រវត្តិពីតូចដល់ធំឯណាទេ ខ្ញុំទើបឃើញគាត់ ហើយគាត់ៗទូទៅក្នុងម៉ាភូមិភាគ គាត់ចុះឡើងដែរ មិនមែនប្រាកដប្រជា។ ខ្ញុំគ្រាន់តែឃើញ ស្គាល់ ព្រោះអាងយើងកូនចៅរបស់គាត់ ក្រោមភូមិភាគនិរតី។ តែឃើញគាត់ទៅ គាត់អេះអុញៗទៅ រួចបាត់អីចឹងទៅ រកប្រាកដថាសួរចង់ដឹងពីស្អីទេ អត់បាន។ ដូចថាបងប្អូនមិត្តភក្តិស្គាល់រាល់នេះទេ រឿងខ្ញុំហើយនិងតាម៉ុក នោះ។

**សះ** *(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ មេធាវីការពារក្តី សូមលោកជួយ ERN ឲ្យផ្តល់លេខ ERN ជា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ភាសាខ្មែរផងនៅផ្នែកសម្អាសជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹង។ អំមិញហ្នឹង យើងស្ដាប់អត់ឮ ERN ជាភាសាខ្មែរទេ។

**លោក វ៉ិចទ័រ កូប៉េះ**

ខ្ញុំមិនទាន់បានឲ្យផ្ដល់លេខ ERN នៅឡើយទេ ខ្ញុំរៀបនឹងឲ្យឥឡូវនេះឯង។

**<លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖>**

គឺ ERN ពាក់ព័ន្ធនឹង កង ចាប។

**<លោក វ៉ិចទ័រ កូប៉េះ>**

បាទ គឺខ្ញុំនឹងផ្ដល់ជូន គឺ <00753883> ជាភាសាអង់គ្លេស, បារាំង <00796632>, ខ្មែរ 00059386។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី ឥឡូវយើងត្រឡប់ទៅនិយាយអំពី តាម៉ុក បន្តទៅទៀត។ សំណួរខ្ញុំសួរថាតើ តាម៉ុក ជាមនុស្សរបៀបម៉េចដែរ? តើ តាម៉ុក ជាមនុស្សតឹងរ៉ឹង ឬក៏អត់ទេ?

**លោក សេង សឿន៖**

**ឆ៖** ចំណុចទាំងនេះ ខ្ញុំមិននឹងបរិយាយកើតទេ ព្រោះមិនដឹងគាត់របៀបណាអីណា បើឃើញតែមនុស្សរបៀបធម្មតា ហើយគេមេ មានតួនាទីរបស់គាត់ធ្វើប្រធានភូមិភាគនិរតី អាហ្នឹងដឹងតែប៉ុណ្ណោះ ឲ្យខ្ញុំវិនិច្ឆ័យថា មនុស្សបែបណា អីបែបណា ខ្ញុំមិនចេះវិនិច្ឆ័យលើរឿងគាត់ហ្នឹងទេ។

[០៩:៣៥:១០]

**ស៖** លោកពិតជាមិនអាចឆ្លើយបានទេ? ខ្ញុំសូមយោងទៅចម្លើយរបស់លោកឆ្លើយជូនមជ្ឈ-មណ្ឌលឯកសារកម្ពុជា គឺ 00753889, ខ្មែរ 00059393, បារាំង 00756638 ដល់ 39។ បាទ ខ្មែរក៏ដល់ 94 ដែរ។ “សួរ៖ ខ្ញុំឮសួរថា តាម៉ុក ជាមនុស្សតឹងតែងណាស់។ ហើយលោកឆ្លើយ៖ មិនជាតឹងតែងប៉ុន្មានទេ។ គាត់ប្រើពាក្យកាចបន្តិចពេលដែលគាត់និយាយ។ នៅពេលដែលគាត់ទៅពេទ្យ គាត់ប្រាប់ឲ្យបុគ្គលិកពេទ្យហ្នឹង គឺថាសម្អុតឲ្យធ្វើម៉េច ឲ្យមើលថែទាំអ្នកជំងឺ។ ហើយគាត់សួរអ្នកជំងឺថាតើមានអីហូបចុកដែរ? ជួនកាលអ្នកជំងឺបានរាយការណ៍ប្រាប់គាត់ថា ចំណីអាហារនៅមន្ទីរពេទ្យមិនល្អទេ។ ហើយតាម៉ុក ក៏បានសួររកប្រធានមន្ទីរពេទ្យ ហើយសួរថា ហេតុអ្វីបានជាអ្នកជំងឺគ្មានអីស៊ីអីចឹង? ហើយគាត់ក៏បានបញ្ជាឲ្យគេផ្ដល់សាច់គោ សាច់ជ្រូក ឲ្យផ្ដល់មកឲ្យអ្នកជំងឺភ្លាម។ ក៏ប៉ុន្តែបុគ្គលិកមន្ទីរ

ពេទ្យនុ៎ងក៏មិនល្អដែរ ពេលខ្លះបីថ្ងៃក្រោយមក គេលែងផ្ដល់ចំណីអាហារឲ្យយើងទៀតហើយ។ ក្នុងអំឡុងពេលបីថ្ងៃនេះ គឺថាមានសាច់គោ សាច់ជ្រូក ជាច្រើន ក៏ប៉ុន្តែដល់ តាម៉ុក ទៅវិញ យើងហូបដូចធម្មតា។" ហើយក្រោយមកលោកនិយាយអំពីម្រាមដៃតាម៉ុក ថាម្រាមដៃតាម៉ុក វែងស្អាត ប៉ុន្តែថាម្រាមដៃហ្នឹងគឺថាមិនធំៗទេ។ ដូច្នេះហាក់បីដូចជាលោកស្គាល់ តាម៉ុក ច្បាស់ណាស់ មិនអ៊ីចឹងលោកដើមបណ្ដឹងរដ្ឋប្បវេណី?

[០៩:៣៧:០៩]

**ឆ៖** កាលដែលខ្ញុំថាស្គាល់ច្បាស់ហ្នឹង ពេលដែលខ្ញុំរបួស ដល់របួសបាក់ជើងហ្នឹងហើយ ដែលពេលហ្នឹងចំពេលគាត់មកមើលកន្លែងមន្ទីរពេទ្យហ្នឹង បានគាត់ណែនាំបុគ្គលិកពេទ្យឲ្យថែទាំអ្នករបួសអ្នកជំងឺហ្នឹង បានខ្ញុំដឹងតែប៉ុណ្ណឹង។ ដល់ពិតប្រាកដថា ប្រវត្តិសាស្ត្រអីគាត់ អត់ចាំទេ។

**សៈ** នៅក្នុងកិច្ចសម្ភាសន៍នេះ ខាងក្រោយបន្តិច គឺថាលោកបានជួបគាត់នៅក្នុងឆ្នាំ១៩៧៦។ តើលោកមាននៅចាំរឿងរ៉ាវអំពីតាម៉ុក ហើយនិងនាឡិការបស់គាត់ដែរឬទេ គឺនាឡិកាដែលគាត់តែងតែពាក់ហ្នឹងណា៎?

**ឆ៖** អាហ្នឹងពាក្យគេនិយាយតៗទេ ឲ្យដែលយកជាការពិតអត់ទេ។ បើនិយាយឲ្យគាត់សុំឲ្យអ្នកណា សុំបានមុន ដល់អត់ព្រមយកចេញអី មកសុំមកទៀត អ៊ីចឹងដោះពីអាមុននឹងឲ្យទៅអាអ្នកក្រោយហើយ។ អាហ្នឹងជារឿងនិយាយលេងតៗ ការពិតដែលគាត់ច្រើនធ្វើតែអ៊ីចឹង ជាមួយអ្នកដែលសុំនាឡិកាហ្នឹង។

[០៩:៣៨:៤០]

**សៈ** វាមិនជារឿងគួរឲ្យភ្ញាក់ផ្អើលខ្លាំងក្លាណានោះទេ។ <ប៉ុន្តែគឺការជឿជាក់ទៅលើលោក។ ដូច្នេះហើយ> ខ្ញុំ<នឹង>ដកស្រង់ចម្លើយរបស់លោក ឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជាស្ដីអំពីនាឡិការបស់ តាម៉ុក។ ERN នេះ គឺដូចគ្នាទេ ខាងក្រោមនេះបន្តិច "សួរ៖ ដូច្នេះ តាម៉ុក គឺថាជាមនុស្សចិត្តល្អ? ហើយលោកឆ្លើយថា៖ បើសិនណាជាយើងសុំនាឡិការបស់គាត់ គាត់ដោះនាឡិកា<ពីដៃ> ហើយឲ្យមកយើងតែម្ដង ប៉ុន្តែយើងត្រូវយកនាឡិកាហ្នឹងហើយ ដើរចេញ<>ទៅ<ឲ្យលឿន> បើសិនណាយើងជាយើងនៅកន្លែងហ្នឹង គឺថា ហើយមានអ្នកណាសុំនាឡិកាដែរ គឺថាគាត់នឹងយកនាឡិកានោះពីយើងមកវិញ ហើយឲ្យទៅអ្នកដែលសុំក្រោយគេហ្នឹងហើយ។ ខ្ញុំបានប្រាប់ទៅគាត់ថា ខ្ញុំអត់មាននាឡិកាមើលម៉ោងទេ។ ហើយគាត់ឆ្លើយថា អេ! មិនអីទេ អ្នកឯងអាចយកអានេះបាន គឺជានាឡិកា<ម៉ាក អូមេ-

ហ្កា។> នាឡិកាមួយល្បីឈ្មោះ។ គាត់ថា គឺយកទៅ អ្អែងយកទៅ! ហើយនៅពេលដែលខ្ញុំទទួលនាឡិកាហើយ <ខ្ញុំ>នៅ<>ឈរនៅកន្លែងនុំង<ដដែល ហើយបន្ទាប់មក> មានគេម្នាក់មកសុំនាឡិកាពីគាត់ដែរ ហើយគាត់ថា យកនាឡិកាពីអាម្នាក់នេះទៅ!" បញ្ចប់ការដកស្រង់។

ដូច្នេះ លោកដើមបណ្ដឹងរដ្ឋប្បវេណីរឿងនេះ វាមិនសំខាន់ទេ ក៏ប៉ុន្តែវាហាក់ថា លោកបានសុំនាឡិកាពីគាត់ដោយផ្ទាល់តែម្ដង។ ត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទៗ និយាយជាមួយពិត មិនភូតភរទេបាទ។

[០៩:៤០:៣១]

**ស៖** ខ្ញុំសួរ<អំពី>កម្មាភិបាលជាន់ខ្ពស់ពីរនាក់ទៀត។ តើលោកស្គាល់កម្មាភិបាល<>ជាន់ខ្ពស់ពីរនាក់នេះឈ្មោះ រស់ ញឹម និង សោ ភឹម ដែរឬទេ?

**ឆ៖** អត់ដែលឃើញមុខទេ ឮតែឈ្មោះ សុទ្ធតែគណៈភូមិភាគអ៊ីចឹង អត់ដែលឃើញទេ។

**ស៖** តើលោកបានឮអំពីពួកគាត់នេះអ្វីខ្លះដែរ?

**ឆ៖** អាហ្នឹងវាដូចឆ្ងាយពីគ្នាបំផុតណាស់ បាទ ភូមិភាគមួយទៅភូមិភាគមួយ ខ្ញុំកូនចៅក៏មិនអាចដឹង អាចស្គាល់ទេ។

**ស៖** តើលោកដឹងថាពួកគាត់ជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិមបក្ស ឬក៏គណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

**ឆ៖** ខ្ញុំអត់បានស្គាល់ច្បាស់ទេ បើគិតសម័យនោះ ឮតាមវ៉ាដ្យូគេប្រកាសឈ្មោះអី ភូមិភាគអីៗ តែឲ្យដឹងស្អីៗ អត់ដឹងទាំងអស់ទេ ខ្ញុំ រឿងគេពីរនាក់ បីនាក់ហ្នឹង។

[០៩:៤២:២០]

**ស៖** ខ្ញុំសូមដកស្រង់ចម្លើយរបស់លោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងឯកសារដដែលហ្នឹង ខ្ញុំមាន ERN តែជាភាសាអង់គ្លេសទេ។ ខ្ញុំនឹងផ្ដល់ ERN ជាភាសាខ្មែរ <និងភាសាបារាំងនៅពេល>ក្រោយ។ <ERN ជាភាសា>អង់គ្លេស 00753820។ លោកបានឆ្លើយថា៖ "សមាជិកពេញសិទ្ធិគឺមានតែ វន វ៉េត, សោ ភឹម និង រស់ ញឹម។ ចំណែកឯ ខៀវ សំផន, សុន សេន និង តាម៉ុក គឺជាសមាជិកបម្រុងទេ។ សំណួរ៖ ចុះបើ អៀង សារី វិញ? អៀង សារី ក៏ជាសមាជិកពេញសិទ្ធិដែរ។ អៀង សារី ពិតជាសមាជិកពេញសិទ្ធិមែន? បាទ ពេញសិទ្ធិ។ <តើមានអ្នកណាផ្សេងទៀតទេ?> ចុះកែ ពក វិញ? លោកឆ្លើយថា៖ អត់ទេ បងពក គឺថាជាអនុលេខាភូមិភាគទេ។" ហើយក្រោយមក លោក

និយាយអំពី កុយ ធួន។ លោកដើមបណ្ដឹងរដ្ឋប្បវេណីធ្វើយ៉ាងដូចម្ដេចទើបលោកអាចដឹងថា អ្នកទាំងពីរ គឺ សោ ភឹម និង រស់ ញឹម គឺជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្ស<កុម្មុយនីស្តកម្ពុជា ឬ>ក៏ជាសមាជិកគណៈអចិន្ត្រៃយ៍<>។ ម៉េចបានលោកដឹង?

[០៩:៤៣:៤៨]

**ឆ៖** គាត់រឿងនេះដែលខ្ញុំបាននឹកៗក្នុងខ្លួនខ្ញុំ នេះខ្ញុំរឿងទាំងអស់នេះ ដែលខ្ញុំដឹងហ្នឹងនេះ ការដំណាលរបស់ បងពក ទេភូមិភាគនេះទេ អង្កាល់ហ្នឹងបានឡើងភ្នំដងរែកទៅ បានជួបគាត់រហូតចុះមកប្រចាំ ធ្វើការងារនៅក្រចេះហ្នឹង។ បានខ្ញុំដឹងរឿងមក បាននិយាយរឿង គាត់និយាយប្រាប់មក បានខ្ញុំដឹងព្រោះខ្ញុំដឹងអ្វីៗទាំងឡាយនេះ។ អារឿងសមាជិកបក្សកុម្មុយនីស្តកម្ពុជាណាណើអីហ្នឹង គឺខ្ញុំដឹងតាម បងពក –កែ ពក– ហ្នឹងទេដែលណាហ្នឹង ខ្ញុំមិនដែលជួបមុខផងហ្នឹង ឮគេថាទៅបាទ ឲ្យឃើញស្គាល់ៗតែម្ដង អត់ឃើញទេ។ ហ្នឹងដូចជម្រាប។

**ស៖** ដូច្នេះ តើ កែ ពក ឬដែលប្រាប់លោកក្រោយ<ថ្ងៃទី០៧ ខែមករា> ឆ្នាំ១៩៧៩ថា ទាំង សោ ភឹម និង រស់ ញឹម គឺជាសមាជិកគណៈ<អចិន្ត្រៃយ៍>បក្សកុម្មុយនីស្តកម្ពុជា។ ត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ខ្ញុំនិយាយនេះ គឺសំអាង បងពក ទេ កែ ពក ហ្នឹងគាត់ដំណើរប្រាប់ខ្ញុំ ហើយខ្ញុំក៏និយាយចាំទៅ ជួបគ្នានៅខាងអ្នកទៅកត់ត្រាសួរខ្ញុំ សម្ភាសពីខ្ញុំ។ អាហ្នឹងរឿងពិត។

[០៩:៤៥:២០]

**ស៖** បញ្ហាដែលខ្ញុំសួរលោកសំណួរនេះ ពីព្រោះថាមានមនុស្សតិចតួចណាស់ដែលដឹងថា រស់ ញឹម គឺជាសមាជិកគណៈអចិន្ត្រៃយ៍។ អ៊ីចឹងហើយយើងខ្ញុំចង់ដឹងថា តើលោកជាដើមបណ្ដឹងរដ្ឋប្បវេណីដឹងរឿងនេះដោយសារអ្វី។ ឥឡូវខ្ញុំបន្តទៅមុខទៅទៀតចុះ។ ឥឡូវបន្តអ្វីដែលលោកបានឆ្លើយនិយាយអំពីជម្លោះប្រដាប់អាវុធរវាងវៀតណាមនិងកម្ពុជាប្រជាធិបតេយ្យ តើលោកមានអ្វីខ្លះអាចជម្រាបជូនអង្គជំនុំជម្រះបានក្នុងអំពីជម្លោះរវាងប្រទេសទាំងពីរនេះ?

**ឆ៖** ខ្ញុំមិនដឹងជម្រាបថាយ៉ាងម៉េចទេ ព្រោះភារកិច្ចធ្វើកងទ័ព គឺការពារទឹកដី រំដោះទឹកដី។ កាលសម័យនោះវាទាក់ទិននឹងរឿងទាហានខ្មែររបស់សម័យ លន់ នល់ រួចនិងយួននៅព្រំដែន កាលហ្នឹងអាធីវគី។ ខ្ញុំបានដឹងប៉ុណ្ណឹង អត់មានរឿងអីវាខុសពីហ្នឹងប្លែកទៀតទេ ហើយក៏មិនដឹងថាដើម្បីអីទេ បើអាហ្នឹងគេច្បាំងៗគ្នាម៉ាពេញប្រទេសហើយ ចេះតែទៅហ្នឹងគេហ្នឹងឯងទៅអារឿងខ្ញុំ ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** ឥឡូវខ្ញុំសូមសួរលោកឲ្យច្បាស់លាស់តែម្ដង តើវាមានបញ្ហាអ្វីពាក់ព័ន្ធទៅនឹងព្រំដែនរវាង

កម្ពុជាប្រជាធិបតេយ្យ និងប្រទេសវៀតណាម តើលោកអាចឆ្លើយបានទេ?

[០៩:៤៧:១២]

**ឆ៖** ខ្ញុំបែបមិនបានទេ ព្រោះខ្ញុំអត់ចេះ គេហៅថាអ្នកផែនទី។ ខ្ញុំដឹងថាគេឲ្យទៅប្រចាំការរ៉ៃនៅព្រំដែនជាមួយយួនស្រុកកោះអណ្តែតហ្នឹង ដឹងថាការពារ បើវាចូលមកដីត្រៀមកម្លាំងបាញ់ទៅបាញ់មកហ្នឹងឲ្យវា ពេលនោះវាចូលជ្រៅហើយ ដប់ ម្ភៃគីឡូម៉ែត្រហើយ ពួកខ្ញុំមេបញ្ជាការចេះដាក់ទិសដៅទៅៗ កុំឲ្យគេចូលតាមចិត្តនោះ។ អាហ្នឹងជាភារកិច្ចរបស់ខ្ញុំបានត្រឹមប៉ុណ្ណឹង។

**ស៖** តើលោកផ្ទាល់មានបានចូលរួមពាក់ព័ន្ធនៅក្នុងការ ផែនការដាក់មីន ហើយនិង<បោះបង្គោលព្រំដែន>ដោយមានដំឡើងទង់ជ័យកម្ពុជាប្រជាធិបតេយ្យផងនោះដែរឬទេ?

**ឆ៖** អារឿងហ្នឹងខ្ញុំដឹងសម័យដែលខ្ញុំនៅប្រចាំការហ្នឹង ប៉ុន្តែខ្ញុំអត់បាននឹងទៅដាក់មីន ដកទង់ជ័យនោះទេ។ ប៉ុន្តែក្នុងកងរបស់ខ្ញុំគេដូចថា ក្រុមគេផ្សេង ខ្ញុំមួយក្រុមហ្នឹងផ្សេង។ គេអ្នកទៅដាក់ទង់ជ័យហ្នឹង ហើយនិងដាក់មីនមើលទៅ ដាក់ដកទង់ជ័យមួយសាទៅវាដក ដាក់ម្តងទៀត ដាក់មីនកៃ។ អ៊ីចឹងដកទង់ជ័យទៅផ្ទុះងាប់ អាហ្នឹងខ្ញុំគ្រាន់តែដឹង អ្នកនៅអង្គភាពជាមួយ តែខ្ញុំមិនបានទៅធ្វើផ្ទាល់ដែរទេ។

**ស៖** បើខ្ញុំព្យាយាមជួយរំឭកដល់ការចងចាំរបស់លោកម្តងទៀត។ ចម្លើយរបស់លោក ERN អង់គ្លេស 00753891, ខ្មែរ 00059396, បារាំង 00756641។ សំណួរពីអ្នកសម្ភាសមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាគឺដូចសួរដូចតទៅ៖ "សួរ៖ ហេតុអ្វីបានជា<គេប្រាប់ឲ្យ>លោកវាយប្រយុទ្ធជាមួយនឹងយួន? តើវាបញ្ហាអ្វីរវាងកម្ពុជា និងយួន? ឆ្លើយ៖ បញ្ហាគឺយួនបានចូលឈ្លានពានមកក្នុងព្រំប្រទល់របស់យើង។ ពួកវាបានដក<បង្គោល>ព្រំដែន<ដែលសល់តាំងពីសម័យបារាំង។> ខ្ញុំបានគោរពតាមបញ្ជា<ឲ្យបោះបង្គោលព្រំដែន>ដោយមានដាក់ទាំងទង់ជាតិកម្ពុជាផង។ ហើយពួកគេបានយក<បង្គោល>នោះចេញ ហើយនិងបានដកទង់ជាតិជ័យចេញ។ <យើងបន្តបោះបង្គោលព្រំដែន> ហើយពួកគេនៅតែបន្ត<ដកវាចេញ>នេះ។ ហើយក្រោយមកយើងបានដាក់បង្កប់មីននៅទីនោះ។ ពួកគេបានមកដក<បង្គោល>នោះចេញ ហើយមីនក៏ផ្ទុះទៅ ហើយស្លាប់ សម្លាប់ពួកវាបីទៅបួននាក់។ ហើយយើងក៏មានផែនការបង្កប់មីនបន្ថែមទៀត។ សួរ៖ ថាតើទង់ជ័យនោះជាទង់ជ័យពណ៌ក្រហម? <ឆ្លើយ៖> គឺជាទង់ជាតិរបស់ប្រទេសយើងតែម្តង។ <សួរ៖ តើ>ទងជាតិនេះ គឺថាមាន<ប្រាសាទអង្គរ ហើយ>ជុំវិញដោយពណ៌ក្រហម<មែនទេ? ឆ្លើយ៖ ត្រឹមត្រូវ គឺទង់នោះហើយ> ហើយក៏មានក្លួរស្រូវ និងកណ្តៀវ

មួយផង។” ហើយ<មានបន្តមក>ខាងក្រោមបន្តិច<ទៀត។ តើ>លោកនឹកឃើញថាទេថា លោកបានឆ្លើយចំណុចទាំងអស់នេះ ទៅប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា លោកដើមបណ្ដឹងរដ្ឋប្បវេណី?

[០៩:៥១:០៥]

**ឆ៖** បាទ ខ្ញុំនឹកឃើញ រឿងរ៉ាវនេះ ខ្ញុំចាំបាន។ គ្រាន់តែខ្ញុំមិនជាអ្នកធ្វើផ្ទាល់ដៃ តែនៅអង្គភាពជាមួយខ្ញុំ អ្នកដែលដាក់មីន ដាក់ដងទង់ជ័យអីហ្នឹង។ ហ្នឹងត្រង់ផ្ទាល់ដៃ ទៅចាត់ទៅអីហ្នឹង អត់បានទេ។ អាហ្នឹងសុំជម្រាបអាហ្នឹងរឿងខ្ញុំ។

**ស៖** ខ្ញុំចាប់អារម្មណ៍ឃ្លារបស់លោកមួយឃ្លាដែលលោកថា “បញ្ហាហ្នឹងគឺពួកយួនហ្នឹងវាឈ្លានពានចូលមកក្នុងទឹកដីយើង”។ តើលោកបញ្ជាក់ឲ្យបានលម្អិតបន្តិចបានទេ តើកងទ័ពវៀតណាមតែងតែចាប់ផ្ដើមឈ្លានពានចូល ឆ្លងចូលមកព្រំដែនយើងអ៊ីចឹងមែនទេ?

**ឆ៖** វា កាលខ្ញុំនៅអត់ទាន់ពិការ នៅព្រំដែនហ្នឹង វាធ្វើរាល់ថ្ងៃហ្នឹងណ៎ា។ វាមិនជាសាច់ទ័ពធំដុំទេ កងទ័ព ប៉ុនកាំភ្លើងគ្រប់ដៃ រកត្រីរាល់ថ្ងៃ ចូលម្ដុំស្រុកកោះអណ្ដែតហ្នឹង ម្ដុំមានប្រាសាទ អាហ្នឹងគេហៅ ប្រាសាទអីទេ នៅស្រុកកោះអណ្ដែតម្ដុំហ្នឹង កាលដែលខ្ញុំនៅប្រចាំការហ្នឹង។

**ស៖** ខ្ញុំយល់ហើយ តែខ្ញុំបញ្ជាក់ឲ្យបានច្បាស់លាស់ថា យើងកំពុងតែនិយាយរឿងតែមួយ។ គេបានសួរលោកអំពីអំឡុងពេលមួយ ហើយហាក់បីដូចជាថាលោកនេះបានឆ្លើយថា ព្រឹត្តិការណ៍នេះកើតឡើងក្នុងឆ្នាំ៧៦ ឬក៏៧៧។ ដូច្នេះ ការឈ្លានពានចូលពីសំណាក់ពួកយួនចូលមកក្នុងព្រំដែនរបស់យើង ហើយដកបង្គោលព្រំដែននេះ គឺតើការដកបង្គោលព្រំដែននេះ ដក<ក្រោយថ្ងៃ១៧ មេសា> ឆ្នាំ១៩៧៥ ឬក៏មុនទេ?

[០៩:៥៣:២១]

**ឆ៖** ដាក់ហ្នឹង ខ្ញុំប្រចាំការនៅពេលហ្នឹង មុន១៧ មេសា កាលហ្នឹង។ សម័យៗនោះគេហៅពួកទាហាន លន់ នល់ គ្រប់គ្រង។ មុខសញ្ញាខ្ញុំទៅស្រុកកោះអណ្ដែតហ្នឹងទៅ ព្រំដែនខាងណោះទេ។ សាច់ទ័ពរបស់សម័យខ្មែរក្រហមហ្នឹង វ៉ៃសម-ទាហាន ជាមួយលន់នល់ នៅម្ដុំខាងក្រុងតាកែវនោះ ស្រុកកំណើតខ្ញុំ។

**ស៖** ខ្ញុំសួរតាមរបៀបផ្សេងវិញ។ កងទ័ពវៀតណាមដែលតែងតែចូលឈ្លានពានមកនោះ តើពួកគេជាកងទ័ពកុម្មុយនីស្ត ឬក៏ជាវៀតកុង ឬក៏ជាកងទ័ពដែលមកពីវៀតណាមខាងត្បូង ជាពួកអាធីវនោះ ឬក៏យ៉ាងណា?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ គឺពួកធីវគី។

**ស៖** តើលោកដឹងថា ការឈ្លានពានចូលមកនេះ កើតមានឡើងនៅក្រោយឆ្នាំ១៩៧៥ នោះដែរឬទេ? លោកមានដឹងថាវៀតណាមចូលឈ្លានពានបែបនេះក្រោយ៧៥ទៀតទេ?

**ឆ៖** រឿងហ្នឹងខ្ញុំ ដែលថាពាក្យថា "ឮគេថា" ក៏ខ្ញុំពិការហើយ មិនអាចតាមដានអីល្អិតល្អន់ទេ។

**ស៖** ខ្ញុំសួរពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ដែលលោកបានរៀបរាប់ពីម្សិលមិញ ការសម្លាប់មនុស្ស ១០នាក់នៅកោះគរ។ តើអ្នកណាជាអ្នកបញ្ជាឲ្យសម្លាប់ប្រជាជនទាំងនេះ? តើអ្នកណាជាអ្នកបញ្ជាឲ្យសម្លាប់មនុស្សទាំង១០នាក់នេះ?

[០៩:៥៥:៥២]

**ឆ៖** ពាក្យនេះ ដូចជាឲ្យខ្ញុំតាំងពីម្សិលរួចហើយនេះ ថា គណៈស្រុកតើជាអ្នកបញ្ជាឲ្យអានេះប្រធានគុកនៅកោះគរនេះទេ អ្នកបញ្ជា ជាអ្នកផ្ទាល់ដៃ ឯបញ្ជា។ បើខ្ញុំដឹងត្រឹមអាដែងគណៈស្រុកឈ្មោះបងផុន ទេ។ ឯខាងលើបញ្ជាតៗមកគ្នា ក៏ខ្ញុំមិនដឹងដែរ គ្រាន់តែប៉ុណ្ណឹង។

**ស៖** សំណួររបស់ខ្ញុំសួរថា លោកឆ្លើយថាអ៊ីចេះ លោកបានឃើញដោយផ្ទាល់ភ្នែក គឺថាអ្នកដែលបញ្ជាឲ្យសម្លាប់<មនុស្សនោះ គឺឈ្មោះ ជាម> ឬក៏ជា អ្នកណាដែលជាអ្នកបញ្ជាឲ្យសម្លាប់ហ្នឹង ជាម ឬក៏អ្នកណា?

**ឆ៖** ខ្ញុំមិននៅចាំបានទេ ព្រោះវាមានបញ្ជាតៗ ហើយមានកងអ្នកចាំដូចថា ក្នុង១០នាក់អ៊ីចឹងមានឈរចាំវាយចងដៃមុខអស់ហើយហ្នឹង អាហ្នឹងដែលខ្ញុំបានទៅសុំគេមើលម្តងហ្នឹង។ ឯអ្នកបញ្ជាពីលើមក គឺខ្ញុំដឹងថាគណៈស្រុកហើយ។ គណៈស្រុក គេមកបញ្ជាមានមេប្រធានប៉ុស្តិ៍ អ៊ូរ៉ែ! គុកហ្នឹងទេ វាមិនមែនអ្នក ពេលសម្លាប់ហ្នឹង គឺមានកូនចៅរបស់គេខាងចាំរ៉ៃនឹងដំបងហ្នឹង ដែលខ្ញុំបានទៅឃើញមកដល់ហើយ សុំគេមើល គេមិនឲ្យមើលទេ តែសម្លុតគេ បានឃើញម្តងហ្នឹង បានដឹងរឿង។

[០៩:៥៧:៥២]

**ស៖** ប្រហែលជាសំណួរខ្ញុំមិនច្បាស់ហើយមើលទៅ។ លោកបានឆ្លើយថា លោកបានឃើញដោយផ្ទាល់ភ្នែកអំពីការសម្លាប់នេះ គឺថាគេសម្លាប់នៅនឹងមុខលោកតែម្តង។ តើអ្នកណាជាអ្នកបញ្ជាឲ្យអ្នកទាំងនោះបាញ់សម្លាប់ ឬក៏សម្លាប់អ្នកទាំងនោះ។ តើ ជាម ឬក៏ជាអ្នកណា?

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយ។ សូមអញ្ជើញ លោកព្រះរាជអាជ្ញា!

**លោក ខេល លីសាក់៖**

បាទ លោកប្រធាន ខ្ញុំសូមជំទាស់នឹងការតាំងសំណួរនេះ គឺថាសួរដដែលៗបីដងហើយ។ ហើយសាក្សីបានប្រាប់ថា គាត់បានឆ្លើយរួចមកហើយ គឺបញ្ជាហ្នឹងបញ្ជាដាក់មកពីថ្នាក់លើ ហើយគឺ -- គណៈកម្មាធិការស្រុកជាអ្នកបញ្ជាឲ្យសម្លាប់។ <គាត់បានឆ្លើយជាច្រើនដងហើយ។> ហើយមេធាវីការពារក្ដីមិនពេញចិត្តនឹងចម្លើយដែលដើមបណ្ដឹងរដ្ឋប្បវេណីឆ្លើយ ចេះតែសួរតទៅទៀត។

[០៩:៥៨:៥៨]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនបានសួរអំពីរចនាសម្ព័ន្ធនៃការបញ្ជា ឬក៏ឋានានុក្រមបញ្ជាពីថ្នាក់លើមកក្រោមទេ។ ខ្ញុំគ្រាន់តែសួរថា តើអ្នកណាជាអ្នកបញ្ជាដោយផ្ទាល់មាត់ឲ្យសម្លាប់មនុស្សទាំងអស់នេះ។ <ចំណុចទាំងពីរនេះគឺខុសគ្នាដាច់តែម្ដង។> ខ្ញុំអត់ទាន់បានសួរថា បញ្ជាហ្នឹងមកពីថ្នាក់លើ មកក្រោមអីចឹងនៅឡើយទេ។ សំណួរខ្ញុំសួរថាតើមានបុគ្គលណាម្នាក់មានវត្តមានដោយផ្ទាល់ខ្លួន បញ្ជាដោយផ្ទាល់មាត់ឲ្យសម្លាប់អ្នកទាំង<១០នាក់>នេះដែរឬទេ។ សំណួរនេះ មិនទាន់បានសួរនៅឡើយទេ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីបន្តសំណួរ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ដូច្នេះលោកដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំសួរថា បើសិនជាលោកបានឃើញ តើលោកបាន -- តើបុគ្គលដែលលោកបានឃើញហ្នឹងជាអ្នកណា ដែលបញ្ជាទៅឲ្យ<>សម្លាប់ ឬក៏បញ្ជាកងទ័ព<>ឲ្យសម្លាប់ប្រជាជនទាំង<១០នាក់>នោះៗ? <តើអ្នកនោះជាអ្នកណា?>

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយ។ សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ខេល លីសាក់៖**

ឥឡូវហ្នឹងគាត់សួរសំណួរ<>ផ្សេង<ក្រៅពីអ្វីដែលគាត់និយាយថា គាត់ចង់សួរនោះ>។ បើគាត់ចង់សួរថា តើមានអ្នកណាម្នាក់នៅទីនោះបញ្ជាដោយផ្ទាល់មាត់<ទេ អីចឹងគឺអាចសួរបាន។> ឥឡូវហ្នឹងគាត់<កំពុងតែ>ប្រាប់<សាក្សី>ថា មានអ្នកណា ពិតជាមានអ្នក<ណា>ម្នាក់នៅទីនោះបញ្ជាហើយ។ <តើអ្នកនោះជាអ្នកណា?> ដូច្នេះ មេធាវីគួរតែសួរសំណួរតាមរបៀបផ្សេងមួយពីនេះ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១០:០០:៤១]

**សួរដោយចៅក្រម ក្លូឌា ហ្វេនស៍៖**

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី នៅពេលដែលលោកមានវត្តមាននៅទីនោះ ហើយបានឃើញការកាប់សម្លាប់នេះ តើលោកមានបានឮអ្នកណាម្នាក់និយាយថា "នែ! សម្លាប់អ្នកទាំង១០នេះចោលទៅ"។ លោកមានបានឮទេ?

**លោក សេង សឿន៖**

**ឆ៖** សំណួរហ្នឹងដូចជាពិបាក ដូចថាដដែល ខ្ញុំគិតចុះឡើង។ ពេលនោះដែលខ្ញុំបានទៅឃើញនឹងភ្នែក។

[១០:០១:១៥]

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី សូមស្ដាប់ខ្ញុំ ហើយស្ដាប់ដោយយកចិត្តទុកដាក់។ លោកបានឃើញគេសម្លាប់មនុស្ស១០នាក់ តើពិតឬទេ?

**ឆ៖** បាទ ពិត។

**ស៖** នៅពេលលោកនៅទីនោះ តើលោកមានឮសូរអ្នកណាម្នាក់និយាយចេញមកផ្ទាល់មាត់ទេថា "នែ! សម្លាប់អ្នកទាំង១០នេះចោលទៅ" លោកមានបានឮទេ?

**ឆ៖** ដូចអត់ទេ។

[១០:០១:៥៧]

**ស៖** ដូច្នេះសូមបញ្ជាក់ម្ដងទៀត។ នៅពេលលោកនៅទីនោះ លោកមិនបានស្ដាប់ឮអ្នកណាម្នាក់បញ្ជាឱ្យអ្នកសម្លាប់ សម្លាប់ប្រជាជនទាំង១០នាក់ទេ។ អាហ្នឹងបើខ្ញុំស្ដាប់មិនច្រឡំ អ៊ីចឹងមែនទេ?

**ឆ៖** លែងគិតពីរឿងអីទេ ពេលហ្នឹង ខ្ញុំទៅលួចមើលគេ ឈរមើលគេ ពេលគេសម្លាប់មនុស្ស១០នាក់ហ្នឹងអត់ឮគេថាម៉េចទៀត ខ្ញុំប៉ុណ្ណឹងក៏ថយចេញមក អត់មានឮថាអ្នកណាអីបញ្ជាថាម៉េចអីទៀតទេ ដូចអត់មានពាក្យអ្នកបញ្ជា ថែមក្រោយទៀតទេ ដូចអត់មានទេ បាទ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អរគុណ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** អ៊ីចឹង សំណួរបន្ទាប់របស់ខ្ញុំ ដើមបណ្ដឹងរដ្ឋប្បវេណីថា តើអ្នកណាជាអ្នកសម្លាប់ជនរង

គ្រោះទាំង១០នាក់ហ្នឹង? តើអ្នកសម្លាប់ហ្នឹងជាពួកអ្នកណា?

**លោក សេង សឿន៖**

**ឆ៖** ដូចខ្ញុំបានជម្រាបហើយថា មេគេអាប្រធានគុកកោះគរហ្នឹង គេអ្នកបញ្ជា អាកូនចៅទេអ្នកបាញ់មួយប្រាវទៅ ងាប់ទាំង១០នាក់ហ្នឹងទៅ។ អាបញ្ជាការ អាប្រធានគុកហ្នឹងវាមិនមែនអ្នកវៃផ្ទាល់ដៃវាអ្នកគ្រាន់តែបញ្ជាតើ។

[១០:០៣:៣០]

**ស៖** ឥឡូវនេះ យើងដល់ចំណុចនេះហើយ តើលោកដឹងដោយរបៀបណាថា ប្រធានកោះគរហ្នឹងទេ ជាអ្នកបញ្ជាឲ្យ<កូនចៅគាត់>បាញ់សម្លាប់អ្នកទាំង<១០នាក់>ហ្នឹង?

**ឆ៖** ហ៊ឺ! ដូចជាឆ្ងល់ដែរនេះ! ខ្ញុំបានជម្រាបហើយថា អាប្រធានគុកកោះគរហ្នឹងជាអ្នកបញ្ជាឲ្យអាកូនចៅវាហ្នឹងសម្លាប់មួយប្រាវហ្នឹង១០នាក់ ដែលខ្ញុំឃើញហ្នឹង ហើយមានពីណាទៀត។

**ស៖** ខ្ញុំចង់ឲ្យលោករៀបរាប់ប្រាប់អង្គជំនុំជម្រះថា តើៗអ្នកបញ្ជាហ្នឹង គេបញ្ជាទៅយោធាហ្នឹងបញ្ជា<ឲ្យសម្លាប់ប្រជាជនទាំងនោះ>ដោយរបៀបម៉េច? ជាការបញ្ជាផ្ទាល់មាត់ ឬក៏ជាការបញ្ជាសរសេរលើក្រដាសស្នាម ឬក៏លោកបានឮបញ្ជាហ្នឹង? <ខ្ញុំចង់រកឲ្យឃើញថា តើអ្វីឲ្យប្រាកដដែលលោកនិយាយថា លោកបានឃើញដោយផ្ទាល់ភ្នែកនោះ។>

**ឆ៖** ខ្ញុំសូមបញ្ជាក់ម្តងហើយម្តងទៀត ការប្រមូលកម្លាំងមកដល់កោះគរ រួចបានសម្លាប់។ ដូចខ្ញុំបានជម្រាបហើយថា ត្រឹមថ្នាក់ស្រុកបញ្ជាឲ្យមេឃុំគ្រប់ឃុំ ដែលមានជនជាតិសុទ្ធៗ ចិន និង យួន ប្រមូលមកដាក់កោះគរឲ្យ អា-- ភ្លេចឈ្មោះហើយ ប្រធានគុកកោះគរហ្នឹង គេកត់ត្រាឈ្មោះទុកទៅ រួចរាយការណ៍មកស្រុក ហើយគេនឹងសម្លាប់។ អានេះគឺជាអ្នកបញ្ជារបស់ថ្នាក់ស្រុក ឯអ្នកបន្ទាប់គឺអាប្រធានគុក ឯអ្នកបាញ់ឲ្យងាប់ប្រាវតែម្តង អាហ្នឹងមានកូនចៅវាមួយក្រុម ឬ១០ក្រុម -- ២០នាក់អីចឹងបន្តបន្ទាប់ហ្នឹង ចែកវេនអីចឹងទៅ។

[១០:០៥:៥៦]

**ស៖** លោកបានរៀបរាប់អំពីវិធីជាទូទៅ។ ឥឡូវនេះយើងឈានមួយជំហានមួយទៀត តើលោកបានវត្តមាននៅទីនោះទេ នៅពេលដែលប្រធានកោះគរហ្នឹងបានទទួលបញ្ជានោះ? តើលោកនៅទីនោះនៅក្នុង<បន្ទប់របស់គាត់ឬ? តើលោកនៅទីនោះ>ទេនៅពេលដែលប្រធាន<កោះគរ>នោះបានទទួលការណែនាំនោះ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ដែលខ្ញុំបានឃើញត្រឹមប៉ុណ្ណឹងទេ ចប់ត្រឹមហ្នឹង រឿងខ្ញុំដែលអង្កាល់ទៅមើលកោះគរពេលនោះ។

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី<> លោក<និយាយ>ថា គ្រាន់តែទៅកោះគរទៅចង់មើលដោយមិនមានកិច្ចការអី។ អ៊ីចឹងខ្ញុំចង់ដឹងតទៅទៀត <ថាតើអ្វីដែលលោកបានដឹង បានឃើញពិតប្រាកដនោះ។ ខ្ញុំសូមសួរបញ្ជាក់ពី>ឈ្មោះមនុស្ស<ឱ្យច្បាស់។> លោក<និយាយ>ថា <ប្រធានគុកកោះគរទទួលបានបញ្ជាពីគណៈស្រុក។> ខ្ញុំសួរថា តើអ្នកណានៅថ្នាក់ស្រុកហ្នឹងនៅគណៈស្រុកជាអ្នកបញ្ជាទៅប្រធាននៅកោះគរនោះ? តើ<នោះគឺឈ្មោះ> ជាម ដែលយើងនិយាយពីខាងដើមហ្នឹងឬ<>?

**ឆ៖** ខ្ញុំបានជម្រាបម្តងហើយម្តងទៀតថា គណៈស្រុក ឈ្មោះ សៅ ផុន បញ្ជាទៅអាប្រធានកោះគរជាអ្នកសម្លាប់ ឯគណៈឃុំអ្នកតាមឃុំដឹងយកទៅ។ ដូចខ្ញុំបានជម្រាបច្រើនដងហើយតើ។

[១០:០៨:០៦]

**ស៖** បាទ អ៊ីចឹងតើលោក<អាច>ពន្យល់មកខ្ញុំ<បានទេ>ថា ហេតុអីបាននៅក្នុងបទសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាលោកនិយាយខុសពីនេះទៅវិញ? នៅក្នុង ERN 00753898, ខ្មែរ 00059 404, បារាំង 00756648 ខ្ញុំដកស្រង់សម្តីលោកម្តងទៀត៖ "នៅកោះគរហ្នឹងគឺគួរឱ្យរន្ធត់ណាស់។ សំណួរ៖ តើអ្នកណាជាប្រធាន? លោកឆ្លើយថា នៅពេលនោះ អាជាម ជាប្រធាន។ <ប៉ុន្តែ> ក្រោយមក ខ្ញុំចាប់ខ្លួនគាត់។" ហើយបន្តទៅទៀតនិយាយពីរឿងចម្លើយសារភាពជាដើមនោះ។ អ៊ីចឹងខ្ញុំសួរលោកថា តើ ជាម ហ្នឹងជាអ្នកទទួលខុសត្រូវក្នុងការសម្លាប់អ្នកទាំងនោះ ឬក៏ សៅ ផុន ជាអ្នកទទួលខុសត្រូវក្នុងការសម្លាប់អ្នកទាំងនោះៗ? <ក្នុងចំណោមអ្នកទាំងពីរហ្នឹង តើនរណាមួយ?>

[១០:០៩:០៦]

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយ។ សូមអញ្ជើញលោកព្រះរាជអាជ្ញា។

**លោក ឌេល លីសាក់៖**

សំណួរពីមុនហ្នឹង គឺថា តើអ្នកណាជាគណៈស្រុក ជាអ្នកចេញបញ្ជាទៅមន្ទីរសន្តិសុខ? គាត់ឆ្លើយ -- ដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយហើយ។ ហើយមេធាវី<ក្រោកឡើងនិយាយ>ថា <ដើមបណ្តឹងរដ្ឋប្បវេណី>ឆ្លើយផ្សេងពីនេះនៅក្នុងបទសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា។ ហើយ<មេធាវីបានអានឱ្យស្តាប់>ថាអ្នកណាជាអ្នកទទួលខុសត្រូវនៅ<មន្ទីរសន្តិសុខ>កោះគរ <នេះ>ជាបញ្ហាផ្សេង។

ហើយឥឡូវនេះមេធាវីសួរថា តើអ្នកណាជាអ្នកទទួលខុសត្រូវ ប្រធានមន្ទីរសន្តិសុខ ឬក៏គណៈស្រុកជាអ្នកទទួលខុសត្រូវ។ អ៊ីចឹង<នេះមិនមែនជាសំណួរដើម្បីឲ្យ>ដើមបណ្តឹងរដ្ឋប្បវេណី<>ឆ្លើយ<នោះ>ទេ។ គួរតែសួរសំណួរជាក់លាក់ផ្សេងពីនេះបាទ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ប្រសិនបើយើងអានខ្លឹមសារក្នុងបរិបទទាំងស្រុង នៃចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះ<លោកនឹងឃើញថា> គាត់និយាយអំពីហេតុការណ៍ជាក់លាក់នេះ ហើយគាត់ថាគាត់បានឃើញហេតុការណ៍នោះដោយផ្ទាល់ភ្នែក។ ហើយ<បន្ទាប់មក គេសួរ>គាត់បញ្ជាក់ថា<៖“តើក្មេងៗ>ត្រូវបានគេសម្លាប់<ទេ?” គាត់ឆ្លើយថា៖ “គេសម្លាប់ទាំងអស់” ហើយគាត់បន្តទៀតថា៖ “នៅកោះគរ>ហ្នឹងគឺឃោរឃៅ គឺគួរឲ្យរន្ធត់” ហើយគេសួរថា៖ “អ្នកណាជា<ទទួលខុសត្រូវនៅទីនោះនៅពេលនោះ?”> ហើយគាត់ថា៖ “ប្រធាននៅទីនោះគឺ អាជាម”។ បាទ អ៊ីចឹងគឺថា គំនិតមួយដែលសហព្រះរាជអាជ្ញាលើកឡើងហ្នឹងវាមិនផ្ទុះបញ្ច្រាំងពីគំនិតដែលខ្ញុំចង់បានទេ។ អ៊ីចឹងខ្ញុំសួរដើមបណ្តឹងម្តងទៀត។ ថាតើៗអ្នកណាជាអ្នកទទួលខុសត្រូវ<>នៅកោះគរ <ហើយនរណាជាអ្នកទទួលខុសត្រូវក្នុងការសម្លាប់ប្រជាជនទាំង១០នាក់នោះ>? ជាម ឬក៏ សៅ ផុន <ឬក៏ទាំងពីរនាក់ជាអ្នកទទួលខុសត្រូវ? តើនរណា>?

[១០:១១:០៧]

**លោក សេង សឿន៖**

**ឆ៖** ដូចបានជម្រាប សៅ ផុន គណៈស្រុកជាអ្នកបញ្ជាឲ្យប្រធានកោះគរចាត់តាំង ដែលយកមកដល់ហើយ អ្នកទៅយក ទៅសម្លាប់ហ្នឹងយកសម្លាប់។ ពេលសម្លាប់ផ្ទាល់ទៀត គឺកូនចៅរបស់អាជាម ហ្នឹងទេ។ ដូចបានជម្រាបច្រើនដងដែរ។

**ស៖** អ៊ីចឹងប្រធានគុកកោះគរ ជាម អ៊ីចឹងអ្នេស! ដែលតាមលោកយល់នោះ?

**ឆ៖** បាទៗ។

**លោក វ៉ិចទ័រ កូប៉េ៖**

ឥឡូវនេះខ្ញុំយល់ ហើយ<មុននឹង>ខ្ញុំសួរសំណួរបន្ថែមពី ជាម នោះគឺថា តើជាពេលសមស្របដើម្បីសម្រាក ឬនៅលោកប្រធានពេលព្រឹកនេះ?

**ប្រធានអង្គជំនុំ៖**

មេធាវីឥឡូវដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទី គិតចាប់ពីពេល

នេះតទៅ។

សូមអញ្ជើញសម្រាក!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១២ នាទី ដល់ម៉ោង ១០:៣០ នាទី)*

[១០:៣០:០៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

សូមអញ្ជើញលោកមេធាវី នួន ជា ឡើងបន្តសំណួរ។

**លោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី យើងទើបតែដឹងនិងរកឃើញថា ជាម គឺជាមេគុកកោះគរ។ ឥឡូវខ្ញុំសួរអ្វីដែលលោកឆ្លើយពាក់ព័ន្ធទៅនឹង ជាម ពាក់ព័ន្ធទៅនឹងការចាប់ខ្លួន គឺចម្លើយរបស់លោក E3/5643, ERN អង់គ្លេស 00753898, ខ្មែរ 00059404, បារាំង 00756648។ នេះគឺអ្វីដែលលោកបានឆ្លើយ៖ "ខ្ញុំបានចាប់ខ្លួនអាជាម។ សួរ៖ ថាតើគាត់បានធ្វើអ្វីខុស? លោកឆ្លើយដូចតទៅនេះ៖ វាបាន<ប្រឌិតចម្លើយ>សារភាព។ វា<គ្រាន់តែសរសេរថា បុគ្គលម្នាក់នេះ មានទំនាក់ទំនងជាមួយបុគ្គលម្នាក់នោះ ប៉ុន្តែ> ក្រោយពីការស៊ើបអង្កេតយើងបានរកឃើញថា វាបានចាប់ខ្លួនមនុស្សជាច្រើន។ ដូច្នេះអ៊ីចឹង វាក៏ត្រូវបានគេចាប់ខ្លួន។ បាទ វាយំ ហើយខ្ញុំឆ្លើយថានេះគឺជាបាបកម្មអ្នកឯងហើយ។ វាគិតថា ខ្ញុំហ្នឹងនិយាយលេងហើយ។ <ខ្ញុំប្រាប់វាថា នៅឲ្យស្ងៀម> ខ្ញុំមិនទាន់បានដកកាំភ្លើងចេញពីចង្កេះខ្ញុំនៅឡើយទេ។ យើងមានគ្នាពីរនាក់។ អ្នកឯងឈរនៅឲ្យស្ងៀម។ យើងចងអ្នកឯង។ ហើយគាត់បានសួរមកខ្ញុំថា តើ<>ម៉េចបានជាអ្នកឯងចង<ខ្ញុំ>? អ្នកឯងធ្វើលេងឬម៉េច? ថាអត់ទេ គឺជារឿងតឹងតែង។ ហើយគឺវាមិនឲ្យខ្ញុំចងវាទេ ក៏ប៉ុន្តែខ្ញុំមានកាំភ្លើង។ ហើយវាសួរខ្ញុំថាម៉េចធ្វើអ៊ីចឹង? ខ្ញុំថានេះគឺថាជោគវាសនាអ្នកឯងមកដល់ហើយ។ យើងបានដាក់វាចូលទៅក្នុងឡាន ហើយវាចាប់ផ្ដើមស្រែកយំឮៗ ហើយយើងបាននាំខ្លួនវាទៅកាន់កោះ<តាង>។" បញ្ចប់ការដកស្រង់។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លោកដើមបណ្ដឹងរដ្ឋប្បវេណី លោកនឹកឃើញទេថា លោកបានឆ្លើយជូនទៅអ្នកស៊ើបអង្កេតមជ្ឈមណ្ឌលឯកសារកម្ពុជាយ៉ាងដូច្នេះ?

[១០:៣២:៤៧]

**លោក សេង សឿន៖**

**ឆ៖** ខ្ញុំបាននិយាយមែន តែមិនបាននិយាយដូចវែងអន្លាយអ៊ីចេះទេ។ ពេលខ្ញុំភ្លង់ទៅ អត់បាននិយាយអីទេជាមួយវាថាវែងឆ្ងាយទេ។ គ្រាន់វាសួរដែរថា អញខុសអី? ខ្ញុំប្រាប់វិញថា ហ្នឹងហើយ រឿងអ្នែង។ អត់ប្រាកដទេពន្លើសនូវចម្លើយ ឲ្យគេងាប់ដោយសារអ្នែងគរគោកគរដី។ អញមិនដឹងទេវើយ។ អានេះខ្ញុំបាននិយាយមែន ឯខុសពីនេះ ខ្ញុំដូចអត់ដឹងអីទេបាទ។

**ស៖** ក្រោយពីលោកបានឃើញការសម្លាប់មនុស្ស១០នាក់រួចមក តើរយៈពេលប៉ុន្មានក្រោយពីការសម្លាប់ហ្នឹង ទើបបានលោកចាប់ខ្លួន ជាម នេះ?

**ឆ៖** ខ្ញុំនៅចាំ ដែលគេ ខ្ញុំទៅឃើញសម្លាប់ហ្នឹង អាសេត -- អានេះ វាអត់ទាន់ចាប់វាទេ វានៅគ្រប់គ្រងគុកហ្នឹងដែរ។

**ស៖** ខ្ញុំយល់ហើយចំណុចនេះ ពីព្រោះលោកបានឆ្លើយថា គាត់គឺជាអ្នកទទួលខុសត្រូវមើលខុសត្រូវនៅគុកកោះគរ នៅពេលដែលគេសម្លាប់មនុស្ស១០នាក់នោះ។ តែសំណួរខ្ញុំសួរថាតើវាមានរយៈពេលប៉ុន្មាន ក្រោយពេលគេសម្លាប់មនុស្សទាំង១០នាក់នេះ ទើបបានលោកចាប់ខ្លួន ជាម នេះ?

**ឆ៖** ដូចខ្ញុំបានជម្រាបហើយថា ភ្លេចពេលវេលាហើយ ប៉ុន្តែពេលនោះដែលខ្ញុំទៅឃើញគេសម្លាប់អ្នក១០នាក់ដែលខ្ញុំឃើញនោះ ក្រោយមកហ្នឹងមិនដល់ពីរខែទេ ប្រហែលជា១០ថ្ងៃអីហ្នឹង ខ្ញុំតាមខ្ញុំ ប៉ុន្តែដូចខ្ញុំបានជម្រាបហើយថា វាមិនចាំមិន ពេលវេលាអីទេ ប៉ុន្តែគ្រាន់តែដឹងថា រយៈពេលនេះមិនឆ្ងាយប៉ុន្មានទេ ពីខ្ញុំទៅឃើញគេសម្លាប់ ហើយក្រោយមក អាប្រធានកោះគរហ្នឹងទៅ បងផុន ឲ្យ ហើយអាហ្នឹង ហើយនិងខ្ញុំចាប់ចងវាដាក់ឡានទៅកោះធំទៅ។

[១០:៣៥:៤៤]

**ស៖** តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេថា ការចាប់ខ្លួន ជាម នេះ វាមានជាប់ពាក់ព័ន្ធទៅនឹងការសម្លាប់មនុស្សទាំង១០នាក់នោះដែរទេ ឬនិយាយម្យ៉ាងទៀតថា តើ ជាម ត្រូវបានចាប់ខ្លួនដោយសារតែ ជាម នេះបានចូលរួមពាក់ព័ន្ធក្នុងការសម្លាប់មនុស្សទាំង១០នាក់នេះឬ?

**ឆ៖** អត់ទេ។ អ្នកសម្លាប់អីនេះ ជារឿងគេកាប់ជនជាតិផ្សេងដោយឡែក តែតាមខ្ញុំដឹង អាជាម

វាប្រធានគុកហ្នឹង រឿងផ្សេង ជារឿងពន្លឺសចម្លើយទៅ អត់មានរឿងទាក់ទិននេះទេ ១០នាក់ ២០នាក់អី ផ្សេងៗនៅកោះគរហ្នឹងទេ។

**ស៖** សំណួរមួយទៀត គឺថាតើហេតុម៉េចបានជាលោកអាចឆ្លើយថា អ្នកដែលគេសម្លាប់ទាំង ១០នាក់ដែលត្រូវបានគេសម្លាប់ទាំង១០នាក់នេះ គឺជាជនជាតិវៀតណាម ឬក៏ជាជនជាតិចិន? <តើលោកដឹងដោយរបៀបណា?> តើលោកស្គាល់ឈ្មោះរបស់ពួកគេទេ? តើលោកដឹងថា អ្នកទាំង១០នាក់នោះមកពីឃុំណាដែរ? តើលោកដឹងដោយរបៀបណា?

[១០:៣៧:១៦]

**ឆ៖** ខ្ញុំអត់បានដឹងនិយាយថា មកហ្នឹងជាជនជាតិអី នៅឃុំណា ខ្ញុំអត់ដឹងទេ ឃើញតែគេបញ្ជូនមកដាក់កន្លែងគេៗត្រូវសម្លាប់ហ្នឹង ព្រោះពេលហ្នឹងវាចាម ក៏ដូចជាយួន ដូចជាចិនអីហ្នឹង វានិយាយខ្មែរច្បាស់ចែសហើយ អ្នកណាមកជាជនជាតិអី ជនអី ប្រាកដប្រជាទេ ខ្ញុំគ្រាន់តែដឹងទេ គ្រាន់តែឃើញមនុស្ស មិននិយាយរកគ្នាផង លួចទៅមើលគេទេ អាហ្នឹងដែលខ្ញុំឃើញប៉ុណ្ណឹង។

**ស៖** ចុះហេតុដូចម្តេចបានជាលោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយលោកបានលើកឡើងម្តងហើយម្តងទៀតពីម្សិលមិញនៅទីនេះថា មនុស្សទាំង១០នាក់ហ្នឹង សូមដកស្រង់៖ "គឺជាជនជាតិវៀតណាម ឬក៏ជនជាតិចិន" បញ្ចប់ការដកស្រង់។ បើលោកមិនដឹងទេ ហេតុអីបានជាលោកឆ្លើយអ៊ីចឹងប្រាប់ទៅមជ្ឈមណ្ឌលឯកសារកម្ពុជា?

**ឆ៖** ខ្ញុំអត់បាននិយាយ ឬគេភរ។ ពេលនោះ ខ្ញុំឃើញពេលគេត្រូវសម្លាប់ ដែលខ្ញុំទៅឈរមើលហ្នឹង វាអត់ឃើញមានចិន ឬក៏យួនឯណាផងទេ មិនដឹងជាជនជាតិអីប្រាកដប្រជាទេ គ្រាន់តែទៅឈរមើលហ្នឹង អត់ប៉ានអះអាងជាមួយអង្គការណា ក៏ខ្ញុំមិនដែលនិយាយដែរ នេះរឿងរបស់ខ្ញុំ។

[១០:៣៩:២០]

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី បាទ ចំណុចនេះវាមានលក្ខណៈពិសេស <ដោយសារថា> សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានការខ្វះខាតក្នុងការផ្តល់យោបល់ទៅលោកថា លោកគឺថាមិនអាចឆ្លើយដាក់កំហុសលើខ្លួនឯងបានទេ។ ប៉ុន្តែខ្ញុំប្រាប់លោកនៅពេលនេះ គឺថា <អ្វីដែលខ្ញុំប្រុងនឹងសួរលោក គឺថាលោកមិនចាំបាច់ឆ្លើយទេ។> តើខ្លួនលោកផ្ទាល់នេះចូលរួមពាក់ព័ន្ធក្នុងការសម្លាប់មនុស្សទាំង១០នាក់នេះទេ? ឧទាហរណ៍ដូចជាលោកជាអ្នករៀបចំបញ្ជីឈ្មោះ ដែលក្រោយមកលោកក៏បានបញ្ជូនបញ្ជីឈ្មោះនេះទៅឲ្យគណៈកម្មាធិការស្រុក។ តើលោកមានចូលរួមពាក់ព័ន្ធក្នុងការ

សម្លាប់មនុស្សទាំង១០នាក់នេះទេ?

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីកុំទាន់អាលឆ្លើយ! សូមអញ្ជើញមេធាវីដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមធ្វើការកត់សម្គាល់មួយ ហើយអង្គជំនុំជម្រះជាអ្នកសម្រេចថាតើគួរតែឲ្យគាត់សួរ ឬក៏មិនសួរសំណួរនេះ។ តើមេធាវីដឹងយ៉ាងម៉េចបាននូវអ្វីដែលយើងនិយាយ អ្វីដែលយើងបានពិភាក្សាគ្នាជាមួយដើមបណ្តឹងរដ្ឋប្បវេណីនោះ សូមគាត់កុំឲ្យនិយាយបែបហ្នឹងអំពីអ្វីដែលកើតឡើងនៅពេលដែលយើងជួបកូនក្តីរបស់យើងនោះ។ <យើងមិនបានប៉ាន់ស្មានទេ នៅពេលដែលគាត់ជួបជាមួយ នួន ជា នោះ។ ដូច្នេះ>ការលើកឡើងរបស់គាត់ហ្នឹងគឺជាវាហួសហេតុហើយ។ គាត់គិតតែពីកូនក្តីគាត់ទៅ យើងក៏យើងគិតពីកូនក្តីយើងដែរ។

[១០:៤១:១០]

**លោក វិចទ័រ កូប៉េ៖**

បើអ៊ីចឹងខ្ញុំ<សូមផ្ទេរ>ការភ្ញាក់ផ្អើល<របស់ខ្ញុំ ពីមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅអង្គជំនុំជម្រះវិញ។ ខ្ញុំសង្កេតឃើញថា> បុគ្គល<គ្រប់ៗគ្នាដែលអាច>ឆ្លើយទម្លាក់កំហុសខ្លួនឯងទោះបីជាកម្មាភិបាលជាន់ទាបក្តី <គឺមានមេធាវីប្រឹក្សានៅជាមួយ។> ខ្ញុំគ្រាន់តែឆ្ងល់ថា ហេតុអីបានជាដើមបណ្តឹងរដ្ឋប្បវេណីនេះមិនទទួលបានការផ្តល់យោបល់យ៉ាងដូច្នេះ។ អ៊ីចឹងឯងបានជាខ្ញុំប្រាប់ទៅគាត់ថាចម្លើយណាទម្លាក់កំហុសលើខ្លួនឯង គាត់មិនបាច់ឆ្លើយ ប៉ុន្តែខ្ញុំសួរថាតើខ្លួនគាត់ផ្ទាល់ហ្នឹងមានពាក់ព័ន្ធក្នុងការសម្លាប់មនុស្សទាំង១០នាក់នេះដែរឬក៏អត់ទេ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

លោក លោកស្រីចៅក្រម មតិយោបល់ដែលលើកឡើងដោយមេធាវីការពារក្តីគឺមិនត្រឹមត្រូវនោះ<ទេ។> មិនមែនជាគាត់ ជាអ្នកផ្តល់ប្រឹក្សាមកដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះទេ ឬក៏ដល់សាក្សីណានោះទេ។ <ប្រសិនបើ>ដើមបណ្តឹងរដ្ឋប្បវេណី <ចង់បាន>មេធាវី <ពិតណាស់ គាត់មានមេធាវីនៅទីនេះ>ដើម្បីប្រឹក្សាយោបល់ជាមួយនឹងគាត់។ <>គាត់បានជួបនឹងមេធាវី<នោះរួចហើយ>។ នេះជាវិធី

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មួយក្នុងការបំភិតបំភ័យ។ <គាត់គួរតែសួរសំណួររបស់គាត់ ហើយគាត់គួរតែឈប់លេងល្បែង>នៅក្នុងបន្ទប់សវនាការនេះ <ដោយព្យាយាមបំភិតបំភ័យដល់បុគ្គលដែលមកផ្តល់សក្ខីកម្មនៅទីនេះ>។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** បាទ បើយ៉ាងដូច្នេះទេ លោកដើមបណ្តឹងរដ្ឋប្បវេណីសូមឆ្លើយមកសំណួរខ្ញុំតែម្តង។ លោកដើមបណ្តឹងរដ្ឋប្បវេណី តើលោកមានជាប់ពាក់ព័ន្ធក្នុងការសម្លាប់មនុស្សទាំង១០នាក់នោះទេ? ដូចជាលោក ថាតើលោកមានបានរៀបចំបញ្ជីឈ្មោះអ្នកទាំង១០នោះដែរឬទេ? <តើលោកមានតួនាទីណាមួយក្នុងការសម្លាប់មនុស្សទាំង១០នាក់នោះទេ?>

[១០:៤៣:០៦]

**លោក សេង សឿន៖**

**ឆ៖** ខ្ញុំមិនបានទទួលផែនការអីទេ បញ្ជីឈ្មោះដែលគេធ្វើតាមឃុំមក គេឲ្យខ្ញុំមកទុកមិនទាំងមើលទេ ខ្ញុំគ្រាន់តែប៉ុណ្ណឹងទេ ឯដល់ពេលនោះ ខ្ញុំនឹកឃើញ ក៏ទៅលេងមើល ចង់ដឹង តើគេធ្វើសម្លាប់របៀបម៉េច បានគេបាញ់សម្លាប់របៀបណា។ បានខ្ញុំមិនដឹងហ្នឹង បានឃើញគេពេលហ្នឹងម្តង អត់មានទៅប៉ានជិតទេ គ្រាន់តែអើតជំហានជា១០ម៉ែត្រ ថាមិនដល់ទេ ប្រហែល៨-៩ម៉ែត្រពីគេត្រូវសម្លាប់ហ្នឹង។ បានតែប៉ុណ្ណឹងទេ ខ្ញុំក៏ត្រឡប់មកកន្លែងវិញមក។

**ស៖** លោកមិនមែនគ្រាន់តែជាមនុស្សម្នាក់លួចមើលតាមគុម្ពោតព្រៃ តាមប្រហោងជញ្ជាំងអីទេ លោកគឺជាអ្នក<ចាប់ខ្លួនអ្នកដែល>ទទួលខុសត្រូវ<នោះនៅ>១០ថ្ងៃក្រោយមក។ <ដូច្នេះលោកមិនមែនជាអ្នកឈរមើលដែលមិនដឹងអីនោះទេ។> តើអ៊ីចឹងមែនទេ?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមទោស លោកមេធាវី លោកកំពុងធ្វើសេចក្តីសន្និដ្ឋានហើយ។

**លោក វ៉ិចទ័រ កូប៉េះ**

បាទ សូមផ្តល់ពេលវេលាមកឲ្យខ្ញុំ។

[១០:៤៤:៣៩]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<វាជាសំណួរ។ យើងនឹងអនុញ្ញាតឲ្យ>លោក<>សួរ<>សំណួរ<ដូចដែលលោកបាននិយាយអ៊ីចឹង។ ហើយយើងទាញសេចក្តីសន្និដ្ឋាន។ យើង>កំពុង<>ចូលរួម<នៅក្នុង>កិច្ចដំណើរការនីតិវិធី

<ដូចគ្នា>។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី តើលោកមិនចូលរួមពាក់ព័ន្ធក្នុងការសម្លាប់មនុស្ស<>ទេឬ <ដោយសារថា>លោក<មានអំណាច>ចាប់<អ្នកដែលទទួលខុសត្រូវ>នេះ?

**លោក សេង សឿន៖**

**ឆ៖** ខ្ញុំមិនដឹងឆ្លើយថាម៉េចទៀតទេនេះ។ ខ្ញុំពេលនោះ ខ្ញុំទៅឈរមើលគេទេ ខ្ញុំមិនមែនទៅចូលរួមចាត់ចែងអានេះត្រូវបាញ់ អានេះត្រូវអីណាអីទេ អត់ទេ។ ពាក្យថា "ចូលរួម" គឺអ្នកជួយបាញ់គ្នាអីតើ ហើយខ្ញុំគ្រាន់តែឈរមើល ខ្ញុំគ្រាន់តែចង់ដឹង ដូចបានជម្រាបលោកមេធាវី។

**ស៖** មិនថ្វីទេលោកដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំចូលទៅប្រធានបទថ្មីមួយទៀត គឺការចោទប្រកាន់ទៅលើគោលនយោបាយថា មានគោលនយោបាយសម្លាប់អតីតមន្ត្រីរដ្ឋការរបប លន់ នល់។ ម្សិលមិញលោកក៏បានឆ្លើយ <ហើយ>នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោក <លោក>ថា មន្ត្រីមកពីរបបមុនៗ គឺថាមិនទុកជីវិតឲ្យរស់រានមានជីវិតទេ ត្រូវតែកម្ទេចចោល។ ហើយលោកថា នេះរឿងនេះ គឺលោកបានដឹងហ្នឹងគឺតាមរយៈការរៀនសូត្រ។ សំណួររបស់ខ្ញុំ សួរទៅលោកថា តើលោកឮគោលនយោបាយនេះចេញពីវគ្គសិក្សារៀនសូត្រនេះ នៅក្នុងឆ្នាំណាដែរ?

[១០:៤៦:៣៣]

**ឆ៖** អរគុណ។ សំណួរនេះខ្ញុំសូមឆ្លើយថា ដូចវាហួសពេលហើយ ចម្លើយសូមបញ្ជាក់។ បន្ទាប់ពីនោះមកដល់ឥឡូវ គិតទៅ តាមដែលខ្ញុំដឹងរៀនសូត្រហ្នឹង ចិត ឆ្នាំទីប៉ុន្មានហើយ ៧២, ៧៣ ឬ៧៤អីហ្នឹង។ អ៊ីចឹងបានថា វាហួសពេលដែលខ្ញុំចងចាំបាត់ទៅហើយ ហើយគណៈស្រុក គណៈតំបន់ហ្នឹង ខ្ញុំលែងឃើញ លែងដឹងឈ្មោះអីទៀតហើយ។ ក្នុងខ្លួនខ្ញុំវង្វេងវង្វាន់ទៅហើយ។

**ស៖** ខ្ញុំយល់ហើយថា រយៈពេលនោះ គឺវាយូរយារណាស់មកហើយ ក៏ប៉ុន្តែវាមានសារៈសំខាន់ណាស់ដែលលោកត្រូវតែជម្រាបជូនទៅតុលាការ<ថាតើវាកើតឡើងនៅពេលណា ព្រោះថា បើសិនជាវាកើតឡើងនៅមុនឆ្នាំ១៩៧៥ អ៊ីចឹង>ការសម្លាប់<ទាហាន>របបសាធារណរដ្ឋខ្មែរ<> វាត្រឹមត្រូវពីព្រោះថាសង្គ្រាមកំពុងតែកើតមាន។ <ដូច្នេះ សំណួរខ្ញុំសួរថា តើលោកបានឮថាទាហានពីរបបចាស់មិនអាចទុកបានទេនោះ> តើវាមុនឆ្នាំ១៩៧៥ ឬក៏ក្រោយ ១៧ មេសា ១៩៧៥ទេ?

**ឆ៖** បាទ ខ្ញុំដឹងថា ក្រោយ ១៧មេសា។

**ស៖** បាទ ល្អហើយ។ អ៊ីចឹងសំណួររបស់ខ្ញុំសួរថា តើលោកបានរៀនសូត្រហ្នឹង នៅក្នុងឆ្នាំណា នៅក្នុងឆ្នាំ១៩៧៥<ភ្លាមៗក្រោយរំដោះ> ឬក៏ក្នុងឆ្នាំក្រោយៗបន្ទាប់មកទៀត?

[១០:៤៨:៣៦]

**ឆ៖** អាហ្នឹងខ្ញុំមិនប្រាកដទេ ព្រោះក្រោយ ១៧មេសា ហ្នឹង ខ្ញុំបានរៀននយោបាយតែម្តងហ្នឹង តាមគេហៅ "វគ្គនយោបាយ"។ អានោះអង្គភាពខ្ញុំកងវរសេនាតូចរបស់ខេត្តតាកែវ កន្លែងដែលខ្ញុំនៅបញ្ជាការអង្គភាពខ្ញុំ គេបើកវគ្គរៀនសូត្រ អារឿងដឹងថា ត្រូវបោសសម្អាតអីៗហ្នឹង។ ខ្ញុំដឹងប៉ុណ្ណឹង។

**ស៖** លោកគឺជាកម្មាភិបាលម្នាក់មកពីភូមិភាគនិរតី ដូច្នេះវាមានសារៈសំខាន់ណាស់ ដែលខ្ញុំត្រូវតែសួរអំពីកាលប្បវត្តិនេះឲ្យបានច្បាស់លាស់ តាមលំដាប់លំដោយ។ តើវា<ភ្លាមៗ>ក្រោយឆ្នាំ ១៩៧៥ ឬក៏ប៉ុន្មានខែក្រោយឆ្នាំ១៩៧៥ ឬក៏ប៉ុន្មានឆ្នាំក្រោយ១៩៧៥ ដែលលោកបានរៀនសូត្រពីគោលនយោបាយនេះ?

**ឆ៖** កាលហ្នឹងខ្ញុំរៀនសូត្រនៅអង្គភាពទ័ពដែលខ្ញុំរស់នៅ រួចពីក្រោយហ្នឹង ខ្ញុំពិការទៅ ដឹងតែត្រឹមហ្នឹងទេ លែងដឹងពេលវេលាអីទៀតហើយ។

**ស៖** បើខ្ញុំនៅសល់ពេលវេលា ខ្ញុំនឹងមកសួរអំពីកាលប្បវត្តិនេះឡើងវិញ។ តើអ្នកណាដែលជាអ្នកឡើងថ្លែង ឬក៏និយាយថា អតីតអ្នករដ្ឋការរបប លន់ នល់ <រួមទាំងទាហាន>ហ្នឹងគឺថាមិនទុកជីវិតឲ្យរស់ទេ។ អ្នកណាអ្នកនិយាយរឿងនេះ?

[១០:៥០:៥៥]

**ឆ៖** ពេលនោះគេ ហៅថា "វគ្គ" មិនមែនជាសាលាទេ។ វគ្គ គឺបានតែបីថ្ងៃទេ បើសាលាបើកពី ៧ ទៅ ១០ថ្ងៃទេ។ ឯខ្ញុំគេបើកវគ្គនយោបាយខ្លីៗ ដើម្បីអប់រំថ្នាក់ដឹកនាំបន្តបន្ទាប់មក ពីរឿងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។ គឺអង្គភាពខ្ញុំ គេមានតួនាទីគ្រប់គ្រងបើកវគ្គនយោបាយហ្នឹង ឈ្មោះ បាវ គេអ្នក ជាអង្គភាពបញ្ជាការស្នងការវរសេនាតូចរបស់ខ្ញុំ។

**ស៖** សំណួររបស់ខ្ញុំសួរថា <តើនរណាជាអ្នកនិយាយនោះ?> តើមេបញ្ជាការកងវរសេនាតូចរបស់លោកឬ ដែលជាអ្នកឡើងនិយាយ<ថា អតីតអ្នករដ្ឋការ និងទាហាន មិនអាចទុកបានទេ?> ហើយបើសិនណាជាៗមេបញ្ជាការរបស់លោកមែននោះ តើគាត់ឈ្មោះអី?

**ឆ៖** ខ្ញុំបានជម្រាបហើយតើ គេហៅ "វគ្គនយោបាយ" មិនមែនគេថ្លែងការណ៍ទេ បើកវគ្គរៀនសូត្រឲ្យកម្មាភិបាលខាងក្រោម។ ហើយខ្ញុំបានជម្រាបហើយថា អ្នកបើកវគ្គអប់រំរៀនសូត្រពួកខ្ញុំពេល

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

នោះ គឺបញ្ហាការកងវរសេនាតូចរបស់ខ្ញុំ ឈ្មោះ បាវ។

[១០:៥២:៣៩]

**ស៖** <ហើយតើចេញមកពីណា? តើ>លោកដឹង<ទេ> តើ បាវ បានទទួលការណែនាំនេះមកពីខាងណាដែរទាក់ទងទៅនឹងជោគវាសនានៃអតីតមន្ត្រីរដ្ឋការរបប លន់ នល់? តើលោក<ដឹងទេ ថាតើគាត់និយាយដោយខ្លួនឯង ឬក៏គាត់>ធ្វើតាមបញ្ជា<គេ>?

**ឆ៖** ហ្នឹងពាក្យថា ខ្ញុំលែងដឹងត្រឹមហ្នឹងហើយ ព្រោះខ្ញុំក្រោមការអប់រំរបស់ បាវ ឯក្រោមពី បាវ ទៅ ពេលនោះគ្រាន់ដឹងថា គណៈតំបន់មិនដឹងពីណាទៀត ខ្ញុំដូចថា វាចប់ត្រឹមហ្នឹងដែរ។

**ស៖** វាមានសារៈសំខាន់ណាស់ក្នុងការស្វែងយល់ដែលថា តើ បាវ នេះនិយាយសម្រាប់តែខ្លួនឯង ឬក៏យ៉ាងណា ពីព្រោះយើងមានសក្ខីកម្មច្រើនណាស់នៅក្នុងតុលាការយើងនេះ ដែលយើងបានទទួលចម្លើយពីកម្មាភិបាលថ្នាក់ស្រុកដូចជា ពេជ្រ ជឹម, សៅ វ៉ាន់ ដែលនិយាយថា នៅ -- យ៉ាងហោចណាស់ក៏នៅភូមិភាគនិរតីនេះ គឺថាមិនត្រូវប៉ះពាល់ទាហានណាចាប់ពីស័ក្តិ៥ចុះមកនោះទេ។ លោកមានលោក១មានឮអំពីបញ្ហានេះទេ?

[១០:៥៤:១២]

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយ! សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

ខ្ញុំសូមជំទាស់ចំពោះអ្វីដែលមេធាវីបានលើកឡើងនូវសំណួរនេះ។ <គាត់បានប្រាប់ទៅ>សាក្សី<ថាមនុស្សគ្រប់គ្នា>និយាយយ៉ាងដូច្នេះ។ <មាន>សាក្សី<តែពីរនាក់ប៉ុណ្ណោះ ក្នុងចំណោមសាក្សី១០០នាក់ ដែលនិយាយបែបនេះ ចំណែកអ្នក>ខ្លះនិយាយផ្ទុយពីនេះ។ ក៏មេធាវីអាចលើកយកសក្ខីកម្មរបស់អ្នកណាម្នាក់យកមកសួរ ប៉ុន្តែមិនអាចឲ្យគាត់ឆ្លើយជាតំណាងយ៉ាងដូច្នេះបានទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនដឹងថា ខ្ញុំនិយាយ<ថា>មនុស្សគ្រប់រូប រាល់ៗរូបនោះទេ។ ខ្ញុំគ្រាន់និយាយថា លេខាស្រុកឈ្មោះ ពេជ្រ ជឹម ក៏បានឆ្លើយនៅចំពោះមុខតុលាការ <ហើយនិយាយរឿងដូចគ្នានេះ។ យើង>មាន សៅ វ៉ាន់ ក៏ជាកម្មាភិបាលថ្នាក់ស្រុក យើងមាន ប្រាក់ យុត ដែលបាននិយាយដូចគ្នា គឺជាកម្មាភិបាលថ្នាក់ខ្ពស់មកពីភូមិភាគនិរតី<បាននិយាយថា អត់មានគោលនយោបាយបែបនោះទេ>។ ហើយ ឌុច នេះ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ក៏<មិន>ដឹងអំពីគោលនយោបាយបែបនេះដែរ។ ដូច្នេះ នាពេលនេះ យើងមិនត្រូវការលើកឡើង<> ជាក់លាក់<ទេ ព្រោះយើងទាំងអស់គ្នាបានស្ដាប់សក្ខីកម្ម ដែល>អាននូវសម្រង់ពីសាក្សីទាំងអស់នេះ <ហើយ>។

[១០:៥៥:៣៧]

**លោក ខេល លីសាក់៖**

ខ្ញុំមិនយល់ស្របទេ។ ការអនុវត្តនៅទីនេះ ពេលណាយើងសួរផ្ទាញ់ទៅអ្នកណាម្នាក់ត្រូវតែលើកយកចម្លើយមុននោះយកមកសួរ។ <គាត់មិនគួរកំណត់អត្តចរិតទេ ព្រោះថាគាត់កំណត់អត្តចរិតភស្តុតាងមិនត្រឹមត្រូវ ហើយ>ខ្ញុំមិនចូលនិយាយលម្អិតទេ ប៉ុន្តែដោយសារតែមេធាវីគាត់លើកឈ្មោះទាំងនោះមកអ៊ីចឹងគាត់ត្រូវតែយកឯកសារដែលពាក់ព័ន្ធនឹងបុគ្គលទាំងនោះដែលតុលាការប្រើប្រាស់នេះ យកមកសាកសួរ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ត្រឹមត្រូវហើយ បើសិនណាជាលោកត្រូវការសួរតតាំង<ដោយប្រើសក្ខីកម្ម> គឺលោកត្រូវ<ប្រាប់លេខយោង>។

**សួរដោយលោក វិចទ័រ កូប៉េ៖**

**ស៖** យ៉ាងណាក៏ដោយខ្ញុំនឹងបន្តទៅមុខទៅទៀតចុះ។ លោកដើមបណ្ដឹងរដ្ឋប្បវេណី តើលោកធ្លាប់ឮមានការណែនាំថា មិនត្រូវប៉ះពាល់ទាហានណាដែលមានឋានន្តរសក្ដិ ចាប់ពីសក្ដិក្រោមស័ក្ដិ៥មកនោះទេ។ លោកធ្លាប់ឮការណែនាំបែបនេះទេ?

**លោក សេង សឿន៖**

**ឆ៖** បាទ អត់បានទេ បានដឹង បានឮអីទេ។

**ស៖** តើ បាវ ជាមេបញ្ជាការវរសេនាតូចនេះ បាននិយាយអំពីអតីតមន្ត្រីរដ្ឋការនៃរបបចាស់ហ្នឹង គាត់និយាយនៅត្រង់កន្លែងណា? តើគាត់និយាយនៅក្នុងវគ្គរៀនសូត្រ <នៅកន្លែងណា>?

[១០:៥៧:១០]

**ឆ៖** ខ្ញុំរកនិយាយមិនត្រូវប្រាកដប្រជាទេ អ្នកនយោបាយដែលខ្ញុំរៀនសូត្រ បងបាវ បើកវគ្គទៅគេបើកនិយាយទូទៅថា អតីតដែលចេញពីសម័យ លន់ នល់ អាហ្នឹងគេត្រូវបោសសម្អាតគាស់ផែនការរបស់បក្សកុម្មុយនីស្តកម្ពុជាទៅ។ ដូច្នេះ គេស្ដាប់ចងចាំតាមពាក្យតែប៉ុណ្ណឹងទេ ឯយ៉ាងម៉េច

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទៀត គឺមិនដឹងដែរទេ។

**សៈ** អ៊ីចឹង<>លោកមិនចាំថា គាត់និយាយនៅកន្លែងណាទេ តើគាត់និយាយនៅក្នុងភូមិណា ឃុំណា ស្រុកណា តំបន់ណា កន្លែងណាមួយ លោកមិនចាំទេឬ?

**ផៈ** អត់មាននិយាយនៅភូមិណា ឃុំណាទេ។ នៅអង្គភាពកងវរសេនាតូច ដែលខ្ញុំរស់ៗនៅហ្នឹង។ បាវ ហ្នឹងគេជាស្នងការនគរបាលកងវរសេនាតូចហ្នឹង គេបើកវគ្គអប់រំរៀនសូត្រ តែប៉ុណ្ណឹងតើ។

**សៈ** ខ្ញុំយល់ហើយ <ថាវាជា>វរសេនាតូចរបស់លោក <ក៏ប៉ុន្តែតើលោកនៅឯណា?> អ៊ីចឹងតើលោកឮឲ្យជាក់លាក់ហ្នឹង គឺនៅត្រង់កន្លែងណាដែលវរសេនាតូចរបស់លោកឈរជើងហ្នឹង?

**ផៈ** ហ្នឹងលែងស្គាល់បាត់ហើយ មិនដឹងភូមិអី កន្លែងអី មិនដឹងទីបញ្ជាការរបស់វរសេនាតូចមិនដឹងកន្លែងអី វាភ្លេចអស់ហើយខ្ញុំ ពីនុង់មកឥឡូវ ត្រូវមកឈឺទៀត លែងដឹងហ្នង។

[១០:៥៩:១៥]

**សៈ** តែយ៉ាងហោចណាស់លោកក៏អាចឆ្លើយប្រាប់ថា <>វរសេនាតូចរបស់លោកហ្នឹង ស្ថិតនៅក្នុងស្រុកណា តំបន់ណាដែរ។ តើលោកអាចឆ្លើយបានទេ?

**ផៈ** ត្រង់ហ្នឹងខ្ញុំឆ្លើយបាន ព្រោះពីរថ្ងៃហ្នឹងខ្ញុំអង្គុយនឹកហ្នឹងដឹងហើយ នៅស្រុកកោះអណ្ដែត។ កន្លែងពួកខ្ញុំជិតព្រំដែនខ្មែរ-យួន ហ្នឹងស្រុកកោះអណ្ដែត។

**សៈ** ខ្ញុំសូមបន្តទៅមុខទៀតចុះ ដោយសារខ្ញុំនៅសល់ពេលតែបីបួននាទីទៀតទេ លោកដើមបណ្ដឹងរដ្ឋប្បវេណី។ នេះគឺជាអ្វីដែលឆ្លើយគឺ E3/409 សំណួរចម្លើយលេខ៤៤ ក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោក។ លោកបាននិយាយអំពីគោលការណ៍មួយ គោលនយោបាយមួយថា អតីតទាហានរបប លន់ នល់ ត្រូវតែកម្ទេចចោល។ ហើយលោកក៏ឆ្លើយថា ប្រជាជនត្រូវគេចាត់ជាពីរប្រភេទគឺមានប្រជាជុំថ្មី និងប្រជាជនមូលដ្ឋាន។ ហើយលោកបន្តទៅនិយាយទៀត សុំដកស្រង់៖ "ប្រជាជនថ្មីហ្នឹងត្រូវតែកម្ទេចចោល" បញ្ចប់ការដកស្រង់។ តើលោកមានបាននិយាយថាអ៊ីចឹងទេថា ប្រជាជនថ្មីហ្នឹងត្រូវតែកម្ទេចចោល?

[១១:០០:៥៣]

**ផៈ** ខ្ញុំមិនមែនថា ភ្លេចភ្លាំងអីទេ ពាក្យហ្នឹងគឺ ខ្ញុំអត់ដែលនិយាយផង រឿងអ៊ីចឹងៗអី។

**សៈ** អ៊ីចឹងគឺមិនមានគោលនយោបាយដើម្បីកម្ទេចប្រជាជនថ្មីទេ? តើអ៊ីចឹងត្រឹមត្រូវឬ?

**ផៈ** ខ្ញុំដូចជាមិនបាននិយាយអីទេ រឿងការងារអ៊ីចឹង ក្រោយពី ១៧មេសា ទៅ ដូចថាលែង

01364532



ក្តាប់បានរឿងអីទៀតទេ ខ្ញុំដូចបានជម្រាបហើយ ក្លាយទៅជាជនពិការរបស់ជាតិទឹកដីទៅ ចប់តែត្រឹមហ្នឹង រឿងខ្ញុំ។

**ស៖** ប្រធានបទមួយចុងក្រោយ គឺយើងត្រឡប់ទៅរកបញ្ហាដែលថាប្រជាជនវៀតណាម ហើយនិងប្រជាជនដែលមានដើមកំណើតជាចិន។ អ្វីដែលខ្ញុំមិនយល់ថា ហេតុអ្វីក៏ប្រជាជនដែលមានដើមកំណើតចិនត្រូវគេសម្លាប់ដែរនោះ មូលហេតុអ្វី? លោកដឹងទេ?

**ឆ៖** ខ្ញុំគ្រាន់តែដឹង ហើយគ្រាន់ឮគេសម្លាប់មួយសាហ្នឹង ដែលឲ្យខ្ញុំសួរ ឲ្យខ្ញុំថាហេតុអី ដឹងអីខ្ញុំម៉េចដឹង ព្រោះគេអ្នកបញ្ជា គេថ្នាក់គេឯណាឯណីមកតតប ខ្ញុំអាចក់អាចែម ទៅដឹងអីផែនការបក្សកុម្មុយនីស្តនោះ។ ខ្ញុំដឹងតែប៉ុណ្ណឹង។

[១១:០២:៥៩]

**ស៖** ខ្ញុំយល់។ ឥឡូវនេះយើងមិននិយាយអំពីការសម្លាប់មនុស្ស១០នាក់នោះទេ។ ប៉ុន្តែនៅក្នុងបទសម្ភាសន៍ទៅមជ្ឈមណ្ឌលឯកសារកម្ពុជា អង់គ្លេស <00753855>, ខ្មែរ 00059350, បារាំង 00796598*(ស៊ីក)* លោកបាននិយាយថា សុំដកស្រង់៖ “គឺមានផែនការកម្ទេចជនជាតិចិន និងជនជាតិវៀតណាម”។ តើហេតុអ្វីក៏មានផែនការកម្ទេចជនជាតិចិន<>?

**ឆ៖** ទេ ពាក្យនេះដូចខ្ញុំឆ្លើយហើយតើ។ ខ្ញុំអត់ដឹងផង ឲ្យខ្ញុំឆ្លើយថាម៉េច?

**ស៖** អ៊ីចឹងលោកមិនដឹងពីផែនការដើម្បីកម្ទេចជនជាតិចិនទេ។ ហើយខ្ញុំយល់ថា លោកក៏មិនដឹងពីផែនការដើម្បីសម្លាប់ជនជាតិវៀតណាម។ តើអ៊ីចឹងឬយ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកព្រះរាជអាជ្ញា!

[១១:០៤:២៣]

**លោក ឌេល លីសាក់៖**

នេះមិនមែនជាខ្លឹមសារអ្វីដែលដើមបណ្តឹងនិយាយទេ។ គាត់សួរអំពីមូលហេតុ <មិនសួរអំពីផែនការទេ។> ហើយគាត់<បានសួរថា មូលហេតុអ្វីបានគេសម្លាប់ ហើយ>ដើមបណ្តឹងឆ្លើយថាមិនដឹងពីមូលហេតុទេ <ថាហេតុអីបានជាមាន>ផែនការ<សម្លាប់ទាំងជនជាតិចិននោះ>។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ មិនបញ្ហាទេ ខ្ញុំនឹងសម្រួលសួរដេញដោលទៀត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីឲ្យខ្ញុំយល់ច្បាស់គឺថា លោកមិនដឹងពីមូលហេតុជាពិសេស ជាការកម្ទេចជនជាតិចិននោះទេ។ អ៊ីចឹងថាតើមានគោលនយោបាយអ្វី ដើម្បីសម្លាប់ជនជាតិចិនដែរឬទេ?

**លោក សេង សឿន៖**

**ឆ៖** ខ្ញុំដូចតែបានរួច ឆ្លើយរួចហើយថា ផែនការស្អីៗទាំងអស់ហ្នឹង គឺខ្ញុំមិនដឹងទេ។ ខ្ញុំកូនចៅគេតើ មិនមែនជាខ្ញុំមេដឹកនាំសំខាន់ឯណា អ៊ីចឹងខ្ញុំអត់ដឹងទេ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះ សូមជម្រាបសួរមេធាវីការពារលោក នួន ជា តើលោកមានបាននិយាយគ្នាជាមួយលោកមេធាវី ខៀវ សំផន ពីពេលវេលាហើយឬនៅ?

[១១:០៥:៥៥]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសុំឆ្លើយ។ ខ្ញុំបានប្រាប់លោកមេធាវី កូប៉េ ថាយើងត្រូវការរយៈពេលតែពី១៥ទៅ២០នាទីទេ ដើម្បីសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ អ៊ីចឹងយើងអាចបញ្ចប់មុនអាហារថ្ងៃត្រង់ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី សូមអញ្ជើញលោកមេធាវីការពារលោក នួន ជា បន្តសំណួរ។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធាន ខ្ញុំប្រើពេលតែពីរបីនាទីទៀតទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី តើលោកដឹងដែរឬទេថា មានជំនាញការចិននៅក្នុងកងទ័ពបដិវត្តន៍កម្ពុជា <នៅក្នុង>កម្ពុជាប្រជាធិបតេយ្យ រវាងពីឆ្នាំ១៩៧៥ ដល់១៩៧៩?

[១១:០៦:៤៩]

**លោក សេង សឿន៖**

**ឆ៖** ចម្លើយហ្នឹងមួយទៀតហើយ ដែលខ្ញុំលែងដឹងហើយ។ ដូចខ្ញុំបានជម្រាបហើយ ក្លាយជន

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អតីយុទ្ធជនពិការហើយ លែងដឹងអស់ហើយ។

**ស៖** គឺចំណុចមួយចុងក្រោយ មុននឹងផ្តល់វេទិកាទៅមេធាវីការពារក្តីលោក ខៀវ សំផន។ អ៊ីចឹងម្សិលមិញ <គេបានសួរលោកអំពី>ពាក្យស្លោកដែលនិយាយថា គឺមិនឱ្យមានពូជសាសន៍ផ្សេងទៀតក្រៅពីខ្មែរទេនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយខ្ញុំ<ជឿថា លោក>និយាយថា ម្នាក់ៗគ្រប់គ្នាដឹងពីរឿងពាក្យស្លោកនេះ។ តើលោកបានឮ លោកបានអានពាក្យស្លោកនេះនៅឯណា? តើលោកបានអាន ខ្លឹមសារនេះនៅក្នុងទស្សនាវដ្តីទង់បដិវត្ត ឬក៏នៅក្នុងឯកសារអ្វី?

**ឆ៖** ហ្នឹង រឿងលោកសួរខ្ញុំ អាហ្នឹងហួសពី លែងៗតែម្តងហើយ បានន័យថា ចប់ហើយ ចប់ទៀតរឿងអស់ហ្នឹង រឿងខ្ញុំ។

[១១:០៨:១៩]

**ស៖** អ៊ីចឹង គឺថាមិនមានពាក្យស្លោកបែបហ្នឹងទេ ដែលថាពាក្យស្លោកនោះ ថាមិនឱ្យមានពូជសាសន៍អ្វីក្រៅពីខ្មែរ។ អ៊ីចឹងមិនមានពាក្យស្លោកហ្នឹងទេ តាមអ្វីដែលលោកដឹងនោះ?

**ឆ៖** ដូចបានជម្រាបហើយថា ចាប់ពីនុ៎ងមកដល់ពេលនេះទៀត រឿងខ្ញុំ ហួសពេលហើយ លែងដឹង លែងស្តាប់អី វង្វេងវង្វាន់ខ្លួនឯងបាត់អស់ហើយ។ នេះបានរស់បានមួយវាប៉ុណ្ណឹង ហៅថាគ្រាន់ហើយ ហ្នឹងដើម្បីតាំងពីនោះមក គេហៅថាបម្រើជាតិ ទឹកដីរហូតឥឡូវ គឺថាបានដឹង ពីមុនលែងដឹងសោះ ជិតដូចថា ប្អូនឆ្កួតបាត់ហើយខ្ញុំ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនប្រាកដថាត្រឹមត្រូវ ឬក៏អីម៉េចទេ ចម្លើយរបស់លោក ប៉ុន្តែខ្ញុំសូមបញ្ចប់ការតាំងសំណួររបស់ខ្ញុំ លោកប្រធាន បាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ខៀវ សំផន មានសំណួរលើដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

[១១:០៩:៣២]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** សូមអរគុណលោកប្រធាន ជម្រាបសួរភាគីទាំងអស់។ ជម្រាបសួរ លោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន អ៊ីចឹងខ្ញុំចោទសំណួរលោកហ្នឹងមួយចំនួនក្នុងឋានៈជាមេធាវី។ ខ្ញុំសួរខ្លីៗទេ។ ខ្ញុំសូមត្រឡប់មក ចូលមកនិយាយអំពី

មុខងាររបស់លោក តួនាទីរបស់លោកនៅក្នុងការរៀបចំពិធីរៀបការ។ លោកនិយាយកាលពីម្សិលមិញនៅម៉ោងក្រោយ<០៩:៥៥:៥២ វិ>នាទី លោកនិយាយបានដូចតទៅនេះ គេសួរសំណួរលោកនោះគឺថា "តើលោករៀបចំពិធីរៀបការនេះយ៉ាងដូចម្តេចដែរ? លោកឆ្លើយ៖ ខ្ញុំគ្រាន់តែគោរពតាមបញ្ជារបស់លេខាស្រុកដែលឲ្យខ្ញុំធ្វើ<តាម។> ខ្ញុំត្រូវតែស្រង់ប្រវត្តិរូបរបស់កងចល័តទាំងអស់ទាំងបុរសទាំងស្ត្រីរួចមក ខ្ញុំត្រូវសម្រេចថាត្រូវរៀបការអ្នកណាជាមួយអ្នកណា។ ខ្ញុំគ្រាន់តែធ្វើតាមបញ្ជារបស់គណៈស្រុកតែប៉ុណ្ណោះ មិនមែនជាសេចក្តីសម្រេចរបស់ខ្ញុំទេ។" សូមបញ្ចប់ការដកស្រង់។ អ៊ីចឹងសំណួរទី១របស់ខ្ញុំ ខ្ញុំចង់ដឹងថា តើលោកគ្រាន់តែជាអ្នកទទួលបន្ទុកក្នុងការរៀបចំពិធីរៀបការនេះរវាងអ្នកនៅធ្វើកងចល័តផ្សេងៗ ហើយនិងកងនារីទេ ឬក៏លោកទទួលបន្ទុកក្នុងការរៀបចំពិធីរៀបការនេះនៅតាមឃុំ ឬក៏តាមភូមិដែរ?

**លោក សេង សឿន៖**

**ឆ៖** ខ្ញុំទទួលទិសការងារពីលេខាស្រុក កងចល័តដែលត្រូវមានអាយុរៀបការ បងលេខាស្រុកគាត់ឲ្យខ្ញុំយកបញ្ជីពីកងចល័តខាងប្រុសខាងស្រី យកមកឲ្យខ្ញុំអ្នកផ្គូរផ្គង ហើយដល់ថ្ងៃហើយបានគាត់អ្នកប្រកាសទទួលស្គាល់។ មានភារកិច្ចតែប៉ុណ្ណឹងទេខ្ញុំ។

[១១:១១:០៥]

**ស៖** បាទ សំណួរខ្ញុំអម្បាញ់មិញប្រហែលជាមិនសូវច្បាស់ ខ្ញុំដឹង យល់ពីចំណុចនេះហើយ ក៏ប៉ុន្តែសំណួររបស់ខ្ញុំនោះ ខ្ញុំចង់សួរថា តើលោកទទួលបន្ទុកការរៀបការតែនៅក្នុងកងចល័តទេ ឬក៏លោកក៏ទទួលសិទ្ធិក្នុងការរៀបចំពិធីរៀបការនេះនៅតាមឃុំ<និងសហករណ៍>អីដែរ?

**ឆ៖** ខ្ញុំទទួលតែពីរដងហ្នឹងនៅកងចល័តស្រុក ឯតាមឃុំគេក្នុងស្រុកស្អាងហ្នឹង ខ្ញុំអត់ដឹងទេ អត់ដែលជាអ្នកទៅរៀបការឲ្យគេទេ។

**ស៖** អ៊ីចឹងបើខ្ញុំយល់មិនច្រឡំទេ នៅក្នុងថ្នាក់ឃុំនេះ ខ្ញុំនឹងឆ្លើយ -- នឹងអានអ្វីដែលលោកបានឆ្លើយ គឺនៅថ្ងៃទី២៩ សីហា នៅម៉ោង១១:១៣នាទី លោកបានឆ្លើយដូចតទៅនេះ៖ "គឺមេឃុំជាអ្នករៀបចំពិធីរៀបការនោះនៅតាម<នៅតាមឃុំ និងនៅតាម>សហករណ៍របស់ខ្លួន"។ តើក្នុងកម្រិតឃុំនេះ គឺមេឃុំហ្នឹងហើយជាអ្នកទទួលបន្ទុករៀបចំពិធីរៀបការនេះ ហើយលោកហ្នឹងក្នុងឋានៈលោកដែលធ្វើការនៅគណៈស្រុកហ្នឹង គឺលោកមិនចូល<ពាក់ព័ន្ធក្នុង>ពិធីរៀបការនៅតាមឃុំទេ អ៊ីចឹងឬក៏យ៉ាងម៉េច?

**ធ៖** បាទៗជារឿងពិតបាទ។

**ស៖** ខ្ញុំសូមឱ្យលោកបំភ្លឺនេះ ពីព្រោះថាយើងបានស្ដាប់ចម្លើយរបស់មេស្រុកបារាយណ៍ សវនាការថ្ងៃទី២២ សីហា កន្លងទៅនេះ ឈ្មោះ ទេព ប៉ូច <[2-TCW-850]> ហើយគាត់ ទេព ប៉ូច នេះគាត់បានពន្យល់អំពីតួនាទីរបស់គណៈស្រុកទាក់ទងទៅនឹងពិធីរៀបអាពាហ៍ពិពាហ៍ កាលនោះមុនម៉ោង ១៥:១៦:៤២ គាត់បាននិយាយថា "ប្រធានសហករណ៍នោះមកស្រុក ហើយគាត់បង្ហាញសំណើមក ហើយក្រោយមកគណៈស្រុកជាអ្នកសម្រេច ហើយចេញសេចក្ដីសម្រេចនោះជាលាយលក្ខណ៍អក្សរ"។ សូមបញ្ចប់ការដក ស្រង់។ អ៊ីចឹងសំណួរខ្ញុំៗចង់ដឹងថាតើទាក់ទងទៅនឹងស្រុកស្អាងរបស់លោកនេះ តើមេឃុំ ឬក៏ប្រធានសហករណ៍នោះ គាត់យកសំណើមក ហើយដែលឱ្យស្រុកនេះសម្រេច ឬក៏ខាងស្រុកនេះមិនមានសិទ្ធិអំណាចអីទៅពិនិត្យមើលលើសំណើ ឬក៏សេចក្ដីសម្រេចនៅតាមសហករណ៍ ឬក៏តាមឃុំនុំងទេ?

[១១:១៥:២៥]

**ធ៖** ខ្ញុំសូមបញ្ជាក់ថា ពេលនោះគេមិនដែល ព្រោះសិទ្ធិប្រគល់ឱ្យតាមឃុំមួយៗអស់ហើយ។ អ៊ីចឹងឃុំមួយៗត្រូវជ្រើសរើស និងរៀបការឱ្យយុវជន យុវនារីរបស់ឃុំ តាមឃុំរៀងខ្លួន។ បើឯនៅស្រុកជុំវិញរបស់សាលាស្រុកហ្នឹង គឺពិសេសមានច្រើនណាស់ មានកងចល័ត ដល់អ៊ីចឹងវាមានខាងប្រុស និងខាងស្រី បានកើតមានជារៀបការឱ្យកងចល័តប្រុសស្រីហ្នឹង មកនៅមន្ទីរស្រុកស្អាង អាហ្នឹងដែលបានខ្ញុំចូលរួមបានពីរដងដែរ។

**ស៖** បើអ៊ីចឹងតាមចម្លើយរបស់លោកហ្នឹង គឺថាឃុំទាំងអស់មានឯករាជ្យភាពរបស់ខ្លួន ហើយរៀបចំពិធីរៀបការនេះតាមចិត្តរបស់ខ្លួន នៅថ្នាក់សហករណ៍របស់ខ្លួនហ្នឹង។ ឥឡូវនេះ ខ្ញុំសូមចាប់អារម្មណ៍ទៅលើដំណើរការដែលគេធ្វើនៅថ្នាក់ស្រុក។ លោកបានឆ្លើយថា <គឺលោក ក្នុងឋានៈលោកជា>អនុលេខាស្រុកហ្នឹង មើលបញ្ជីហើយ និងរៀបចំពិធីរៀបការ។ អ៊ីចឹងសំណួរខ្ញុំ ខ្ញុំចង់ដឹងថា នៅពេលដែល<គេប្រគល់>បញ្ជីហ្នឹង<ឱ្យលោក> តើ<លោកមានបានស្នើសុំ>បញ្ជីទាំងអស់ហ្នឹងផ្អែកទៅលើសំណើរបស់ប្រធានកងចល័តដែរឬទេ ឬក៏ថាពេលដែលគេឱ្យបញ្ជីមួយមកលោកមក ហើយគេសួរថា តើបុគ្គលនេះអាចរៀបការជាមួយបុគ្គលរូបនេះបានដែរឬទេ ហើយក្រោយមកបានថ្នាក់ស្រុកហ្នឹងចេញសេចក្ដីសម្រេច ឬក៏យ៉ាងណា?

[១១:១៧:៣៧]

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា រឿងនេះវរសេនា -- នែ! កងចល័តទាំងពីរផ្នែកហ្នឹង ចល័តខាងនារី ខាងបុរសហ្នឹង តាមផែនការគណៈស្រុកថា ឲ្យជ្រើសរើសការហ្នឹងយកប៉ុន្មានថា ២០ ឬ៣០គូ ឲ្យប្រាកដអីចឹងទៅ ហើយថា ហើយ ឥឡូវយកបានយកបាន ២៥សហ្នឹង ២៥គូ។ អីចឹងកងចល័តទាំងសងខាងហ្នឹង គេយកចំនួនរៀងខ្លួន យកប្រាប់មកឲ្យបងផុន – បងផុន ប្រាប់មកខ្ញុំថា អ្នែងធ្វើអីចេះ ផ្គុំគូទៅ ក្នុងឃុំជាមួយគ្នា ហើយអាយុបង ប្រុសនុំងបង៣ឆ្នាំ ឬ៥ឆ្នាំទៅតាមអញ្ចេទៅ។ អាហ្នឹង ខ្ញុំធ្វើតាមតែប៉ុណ្ណឹង។

**ស៖** តើនៅក្នុងនីតិវិធីហ្នឹង ថានៅពេលណាមួយនោះ តើលោកមានធានាថា<>អនាគត<គូស្វាមី>ភរិយាហ្នឹង <>គាត់យល់ស្រប<នឹងគ្នាទេ> ឬក៏<ថា ទើបតែនៅថ្ងៃរៀបការទេ ដែលលោកបានទទួល>ការយល់ស្របពី<>អនាគត<គូស្វាមី>ភរិយាហ្នឹង?

**ឆ៖** ខ្ញុំអត់ដែលនិយាយទេ។ ការរួច ការហើយហ្នឹង តាមឃុំៗហ្នឹងគេដឹកទៅបាត់ហើយ ខ្ញុំមិនដឹងទៅសួរនាំអីណាផង អាហ្នឹង។

[១១:១៩:៣០]

**ស៖** ខ្ញុំគិតថា ប្រហែលជាមានបញ្ហាបកប្រែហើយ សំណួរខ្ញុំអម្បាញ់មិញនេះ ខ្ញុំសួរម្តងទៀតបែបតាមផ្លូវផ្សេងម្តង។ លោកបាននិយាយអំពីរបៀបការដោយបានប្រាប់ថា គឺផុន ហ្នឹងជាអ្នកប្រាប់ទៅ<អនាគតគូ>សាមីជន<ភរិយា>ទាំងអស់ហ្នឹងថា បើសិនជាគាត់មិនចង់រៀបការទេ គាត់អាច <ប្រាប់យើង ហើយ>ចេញបាន។ ក៏ប៉ុន្តែតើនៅថ្ងៃណាមួយផ្សេងទៀតនោះ លោកក្នុងឋានៈលោកជាអនុលេខាស្រុកនោះ តើលោកមានចាត់ការណាមួយ ដើម្បីឲ្យដឹងថា តើអ្នកដែលនឹងរៀបការជាមួយគ្នាហ្នឹងគាត់យល់ស្របនឹងគ្នាហើយ ឬក៏ទាល់តែប្រធានកងទាំងអស់ហ្នឹង កងចល័តហ្នឹងគេកំណត់តែម្តងត្រូវតែរៀបការជាមួយអ្នកណាអ្នកណីអីចឹង។ តើត្រូវឲ្យមានសាមីជនហ្នឹងគេត្រូវស្របគ្នា ឬមិនស្របគ្នា?

**ឆ៖** តាមខ្ញុំស្តាប់សំណួរនេះគឺថា ដូចខ្ញុំឆ្លើយថា ពេល បងផុន គណៈស្រុកគាត់ប្រកាសគ្រប់គូដែលផ្គុំផ្គួចហើយហ្នឹងឲ្យ ដូចថាប្រកាសទទួលស្គាល់អីចឹង ប៉ុន្តែមុនរួចពីហ្នឹងគាត់ឆ្លើយថា គូទាំងអស់អ្នកណាទាំងអស់ ទាំងខាងស្រី ខាងប្រុសទេ មានសិទ្ធិបើមិនស្រឡាញ់ ស្រីក៏ដោយ ប្រុសក៏ដោយ ត្រូវក្រោកចេញ អត់មានបង្ខំអីទៀតទេ បើកសិទ្ធិ។ ហ្នឹងខ្ញុំជម្រាបប៉ុណ្ណឹងឲ្យដាក់ធានាអីម៉េចទៀត ខ្ញុំដូចអត់មាននិយាយអីទេ។

[១១:២១:៣២]

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សៈ** អំមិញសំណួរខ្ញុំហ្នឹងគឺ ខ្ញុំចង់ -- ឥឡូវខ្ញុំយល់ចម្លើយលោកហើយ ក៏ប៉ុន្តែគឺថានៅថ្ងៃរៀបការហ្នឹងតែម្តងហ្នឹងបានគេសួរថា តើយល់ព្រម ឬមិនយល់ព្រម។ ក្នុងឋានៈលោកជាអនុលេខាស្រុកហ្នឹង គឺលោកមិនបានយកព័ត៌មានទាំងអស់ហ្នឹងឱ្យដឹងពីមុនមក ដឹងថាតើសាមីជនហ្នឹងគេយល់ព្រមរៀបការជាមួយគ្នាអី ឬអត់ជាមុនហ្នឹងទេ លោកអត់បានធ្វើអ៊ីចឹងទេ ដល់ថ្ងៃរៀបការហ្នឹងបានដឹងតែម្តងឬក៏យ៉ាងម៉េច?

**ឆៈ** និយាយថា អត់ទាំងដឹងទេ អស់ទាំងគ្នាហ្នឹង ខាងកង ខាងស្រីទាំងខាងប្រុសហ្នឹង។ ដល់ថ្ងៃហ្នឹង ខាងប្រុសមេៗហ្នឹងគេហៅទៅ ខាងស្រីដូចមេៗខាងនេះ ហៅយកមករៀបការទៅមិនដឹងទាំងអស់តែម្តងហ្នឹង នេះខ្ញុំក៏យល់ឆ្លើយសំណួរហ្នឹង។

**សៈ** អ៊ីចឹងដើម្បីឱ្យយល់ច្បាស់ គឺថាលោកនោះលោកមិន -- លោកធ្វើសេចក្តីសម្រេច ក៏ប៉ុន្តែលោកមិនបានចាត់វិធានការណាមួយដើម្បីប្រាប់គេឱ្យដឹងមុនថា អ្នកឯងនឹងជិតរៀបការហើយបន្តិចទៀតនេះ <ឬក៏ឱ្យមានការ>គេយល់ព្រម<ពីពួកគេមុនពេល>រៀបការនឹងគ្នា ឬអត់នោះទេ លោកមិនបានធ្វើការងារហ្នឹងទេ អ៊ីចឹងមែនទេ?

**ឆៈ** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

[១១:២៣:២០]

**សៈ** ខ្ញុំអត់បានស្តាប់ឮចម្លើយ។ ខ្ញុំឮអំមិញដូចគាត់ថា "បាទ" ប៉ុន្តែ សូមឱ្យបញ្ជាក់ម្តងទៀតព្រោះយើងអត់បានឮការបកប្រែចេញទៅជាភាសាបារាំង។

**ឆៈ** បាទ ដែលលោកសួរខ្ញុំ ខ្ញុំបានឆ្លើយថា "បាទ ត្រឹមត្រូវហើយ"។

**សៈ** ឥឡូវខ្ញុំសូមត្រឡប់មកនិយាយដោយខ្លីទេ ពីផ្នែកមួយនៃចម្លើយរបស់លោកនៅចំពោះមុខមជ្ឈមណ្ឌលឯកសារកម្ពុជាដែល<>ព្រះរាជអាជ្ញា<បានអានជូនលោកស្តាប់ពី>ម្សិលមិញ។ ខ្ញុំសូមអានម្តងទៀត ហើយសំណួរដែលខ្ញុំសួរហ្នឹង ខ្ញុំសួរខុសពីសំណួររបស់ព្រះរាជអាជ្ញា។ លោកប្រធាន គឺឯកសារ E3/5643, ERN ជាភាសាបារាំងគឺ 00756607, ជាភាសាអង់គ្លេស គឺ 00753864, ជាភាសាខ្មែរគឺ 00059360 ហើយបន្តទៅទំព័របន្ទាប់ហ្នឹងមួយទំព័រទៀត ទាំងបារាំង<ក៏បន្តទៅទំព័របន្ទាប់មួយទៀតដែរ>។ អ៊ីចឹងខ្ញុំសួរលោក<ចង់ដឹង>ថាតើ<>របាយការណ៍<នោះគេមានផ្ញើ>ទៅថ្នាក់លើទេ។ លោកឆ្លើយថា៖ មិនមានរបាយការណ៍ណាទេ។" សំណួរគេសួរមួយទៀត "តើ<មិនមានបញ្ជូនរបាយការណ៍>ទៅដល់មជ្ឈិមទេឬ? ចម្លើយថា៖ ទេ មិនៗទៅដល់ថ្នាក់ឃុំផង ពួកនេះសុទ្ធតែពួក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អាក្រក់ ល្បិចច្រើន ពេលវាស្អប់អ្នកណាម្នាក់ ពេលវាខឹងសម្បានឹងអ្នកណាម្នាក់ ពេលវាគុំកួននឹងអ្នកណាម្នាក់ហ្នឹង គឺពេលហ្នឹងវាបំភ្លៃការពិតហើយ គឺថាមានៗសង្គមមួយ ក៏ប៉ុន្តែច្បាប់វាមានតែទៅលើក្រដាសសៀវភៅទេ គឺអនាធិបតេយ្យទាំងស្រុងតែម្តង។ ហើយវាអាស្រ័យលើបុគ្គលដែលមានអំណាចតែប៉ុននុង ឧទាហរណ៍ដូចជាមេភូមិ មេឃុំ អីជាដើមនេះ។ ហើយពួកគេធ្វើអីក៏បានដែរ មិនមានអ្នកណាតាមដានពួកគេទេ មិនមានអ្នកណាត្រួតត្រាលើពួកគេទេ។ ពួកគេហ្នឹង <មិនញញើតក្នុងការ>ធ្វើរបាយការណ៍<> ថា<បាន>សម្លាប់អ្នកនេះអ្នកនោះដោយចោទថាជាខ្មាំង ឬក៏បានប្រព្រឹត្តកំហុសអីជាដើម។" សូមបញ្ចប់ការដកស្រង់។

[១១:២៦:១១]

អ៊ីចឹងនៅពេលដែលសហព្រះរាជអាជ្ញាចោទសំណួរទៅលោកទាក់ទងនឹងប្រធានបទនេះ លោកបានឆ្លើយថា លោកបាននិយាយទៅតាមបទពិសោធន៍របស់លោក។ អ៊ីចឹងសំណួររបស់ខ្ញុំចង់ដឹងថា តើនៅស្រុកស្អាងនេះរបស់លោកហ្នឹង ដែលលោកធ្វើជា<>អនុលេខាស្រុកនោះ តើលោកមានករណីមេភូមិមេឃុំអីនោះដែលបំភ្លៃការពិត ហើយរំលោភសិទ្ធិអំណាចខ្លួនឯង ដោយចោទប្រកាន់គេថា គេជាខ្មាំងជាអីជាដើមនេះ? បើសិនជាលោកចាំ តើលោកចាំថា ចាំឈ្មោះភូមិ ឈ្មោះឃុំណាទេ ដែលករណីហ្នឹងបានកើតឡើងហ្នឹង?

**ឆ៖** ខ្ញុំដូចអត់ជួបប្រទះនឹងរឿងនេះទេបាទ។

**ស៖** លោកថាអត់បានជួបហេតុការណ៍ហ្នឹងទេ។ អ៊ីចឹងហេតុអីបានជាពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជាសម្ភាសលោកនោះ កាលនោះលោកនិយាយអ៊ីចឹង។ អ៊ីចឹងខ្ញុំសួរលោកថា តើលោកនិយាយអ៊ីចឹងហ្នឹង ដោយមានមូលដ្ឋានបង្អែកណាដែរ មានអ្វីជាបង្អែកដែរ?

**ឆ៖** បើៗនិយាយតាមរបៀបហ្នឹង គឺថា គឺការងារហ្នឹងវាដូចជាទូទៅហើយនៅស្រុកខ្មែរក្នុងរបបហ្នឹង កម្ពុជាប្រជាធិបតេយ្យ ដូចគេនិយាយតៗគ្នា។

**ស៖** អ៊ីចឹងខ្ញុំយល់ហើយ។ អ៊ីចឹងពេលលោកនិយាយថាគេនិយាយតៗគ្នាទាំងអស់ហ្នឹង តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ ថាលោកបានឮហ្នឹងនៅពេលណាដែរ ហើយលោកមានករណីនៅស្រុកលោកហ្នឹងដែលស្រុកដែលលោកធ្វើការហ្នឹង លោកមានករណីជាក់លាក់ណាទេ?

[១១:២៨:២៦]

**ឆ៖** ខ្ញុំដូចជាថាជាក់លាក់ក៏វាមិនដឹង ឬក៏ជាក់លាក់ក៏មិនហ៊ានថា ព្រោះវាការនិយាយ មិនបាន

01364540



នៅចងចាំ យូរពេកក៏ថាបាន ថាខ្ញុំភ្លេចភ្លាំងចុះក៏ថាបាន អានេះខ្ញុំដូចជាចប់សេចក្តីត្រឹមហ្នឹងដែរ។

**ស៖** អម្បាញ់មិញនេះ លោកនៅពេលលោកឆ្លើយសំណួរទៅក្រុមមេធាវី នួន ជា លោកបានលើកឈ្មោះ ជាម។ ដោយលោកនិយាយថា លោកបានចាប់គាត់នោះ ពីព្រោះគាត់ហ្នឹង គាត់បានចោទប្រកាន់គេខុស ចោទប្រកាន់ទៅលើអ្នកដែលគ្មានកំហុស។ តើនេះជាឧទាហរណ៍មួយដែលៗធ្វើឱ្យលោកហ្នឹងនិយាយទៅប្រាប់ទៅមជ្ឈមណ្ឌលឯកសារកម្ពុជាយ៉ាងដូច្នេះ ឬក៏យ៉ាងម៉េច ប្រាប់ថាអ្នកខ្លះហ្នឹងចោទប្រកាន់គេទទឹងទទែងទៅ ដើម្បីចាប់គេអ៊ីចឹង?

**ឆ៖** ពាក្យហ្នឹងខ្ញុំនិយាយអ៊ីចេះទេ ចោទប្រកាន់គេទេ តែ បងផុន ឱ្យខ្ញុំពីរនាក់ អាសាន មួយទៀត គាត់ចាប់ចងអាមេគុកហ្នឹងថា ហេតុមូលហេតុដែលត្រូវចាប់វានេះ គេហៅថាបំភ្លៃចម្លើយ មិនមែនថានេះ ពាក្យតែប៉ុណ្ណឹង ដែលត្រូវចាប់វាហ្នឹង។ ចាប់បំភ្លៃ របាយការណ៍ដែលចេះតែសរសេរៗហ្នឹងអានេះ ចោទអានោះ ដែលគេនិយាយខ្លីថា "បំភ្លៃ"។ មានពាក្យតែប៉ុណ្ណឹងទេ ខ្ញុំ។

[១១:៣០:១៩]

**ស៖** ខ្ញុំដឹងថា ឥឡូវដល់ពេលសម្រាកហើយ លោកប្រធាន។ សំណួរចុងក្រោយរបស់ខ្ញុំ ៗចោទសំណួរទាំងអស់នេះពីព្រោះថា នេះមិនមែនជាផ្នែក<តែមួយគត់>ដែលលោកបានឆ្លើយទៅមជ្ឈមណ្ឌលឯកសារកម្ពុជាទេ គឺថាមានផ្នែកមួយទៀតដែលខ្ញុំចង់ឱ្យលោកពន្យល់ដែរ គឺនៅឯកសារដដែល គឺឯក-សារ E3/5643, ERN ជាភាសាបារាំងគឺ 00756650, ជាភាសាអង់គ្លេសគឺ 00753899, ERN ជាភាសាខ្មែរគឺ 00059406។ បាទ សំណួរគេសួរលោកដូចតទៅនេះ កាលនោះគេកំពុងនិយាយអំពីតុលាការខ្មែរក្រហម អ៊ីចឹងគាត់និយាយថា "តុលាការហ្នឹងកាត់ទោសតែអ្នកដឹកនាំជាន់ខ្ពស់ តើចំពោះលោកនេះ តើត្រូវកាត់តែអ្នកដឹកនាំជាន់ខ្ពស់ ឬក៏កាត់ទោសអ្នកថ្នាក់ក្រោមៗដែរ?" <ហើយចម្លើយរបស់លោកដូចតទៅ៖> "ខ្ញុំចង់ឱ្យគេកាត់ទោសអ្នកនៅកម្រិតក្រោមផងដែរ ដឹកនាំជាន់ទាបផងដែរ ពីព្រោះថាពួកនេះឯងដែលធ្វើឱ្យបំភ្លៃការពិត ហើយធ្វើឱ្យមាគ៌ាបក្សហ្នឹងរលាយ។" តើលោកអាចពន្យល់តុលាការបានដែរឬទេ ពេលដែលលោកនិយាយថា ពួកអ្នកដឹកនាំថ្នាក់ក្រោមនេះហើយ ដែលធ្វើឱ្យមាគ៌ាបក្សហ្នឹងរលាយ?

**ឆ៖** ខ្ញុំថា បាននិយាយ ឬមិនបានទេ អារឿងពាក្យហ្នឹង។ ដូចគេថានិយាយតៗព្រោកប្រាជ្ញតគ្នាព្រោះច្រើននិយាយតែអ៊ីចឹង អ្នកនៅបម្រើការគេឆ្នាំ៧០ហ្នឹងរហូតដល់ឥឡូវដែលមានជីវិតរស់នៅរាល់ថ្ងៃហ្នឹង នាំគ្នានិយាយតែអ៊ីចឹងដែរពាក្យហ្នឹង។ ពួកអាខាងលើហ្នឹងមិនសូវដឹងអីប៉ុន្មាន អាបងៗក្រោមៗទេ

ច្រើននិយាយថាអ៊ីចឹង បាទ។

[១១:៣២:៤០]

**ស៖** លោកនិយាយពីឆ្នាំ<១៩៧០>។ ខ្ញុំនិយាយពីឆ្នាំ៧៥ ដល់ ៧៩។ តើលោកអាចបញ្ជាក់បានដែរឬទេ ថាតើលោកបានឮពាក្យពេចន៍ទាំងអស់ហ្នឹងចន្លោះឆ្នាំ១៩៧៥ ដល់ ៧៩ ដែលគេថាមាគ៌ាបក្សហ្នឹងរលាយ ឬក៏ប្រាសចាកនៅថ្នាក់ក្រោមហ្នឹងមិនបានអនុវត្តតាមមាគ៌ាដែលបក្សចេញនោះទេ។ តើលោកមានឮគេនិយាយអ៊ីចឹងទេ នៅចន្លោះឆ្នាំ១៩៧៥ ដល់ ៧៩?

**ឆ៖** បាទ ពាក្យហ្នឹងគឺចាប់ពីក្រោយ១៧ មេសា មករហូត ទើបតែ១៧ មេសា បានដឹងមកទៅឮពាក្យហ្នឹង។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ឥឡូវខ្ញុំអស់ពេលវេលាហើយ។ ខ្ញុំអាចឈប់ពេលនេះបាន តែបើសិនពេលស្រស់ស្រូបអាហារថ្ងៃត្រង់ហើយៗ លោកប្រធានអនុញ្ញាតឲ្យ ខ្ញុំសុំប្រាំនាទីទៀត ដើម្បីសុំការបំភ្លឺពីគាត់ឲ្យបានលម្អិតជាងហ្នឹង លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីបន្តសំណួរបន្ថែមទៀតដែលនៅ៥នាទីទៀត។ សូមអញ្ជើញ!

[១១:៣៤:១៥]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** សូមអរគុណលោកប្រធាន។ លោកដើមបណ្ដឹងរដ្ឋប្បវេណី លោកទើបតែនឹងនិយាយតាមរយៈការបកប្រែជាភាសាបារាំង ខ្ញុំឮថាក្រោយពី ១៧ មេសា ៧៥ លោកបានឮពាក្យផ្សេងទៀត។ អ៊ីចឹងចម្លើយហ្នឹង ខ្ញុំស្ដាប់ទៅអត់ច្បាស់ទេ ទៅជាភាសាបារាំងហ្នឹង។ តើលោកអាចបញ្ជាក់បានទេ សំណួរខ្ញុំសួរអម្បាញ់មិញគឺសួរថា តើ<លោកបានឮប្រជាជន>រិះគន់<ចំពោះការ>អនុវត្តគោលនយោបាយបក្ស<ដែរទេ> ការអ្វីដែលខ្ញុំនិយាយនេះ គឺវាមានទំនាក់ទំនងទៅនឹងចម្លើយដែលលោកបានឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជាពីមុនមក?

**លោក សេង សឿន៖**

**ឆ៖** ខ្ញុំដូចជាមិនមែនស្រមើស្រមៃទេ ប៉ុន្តែពាក្យថា បណ្ដាលមកពីអ្នកដឹកនាំខាងក្រោមៗហ្នឹងដែលចាប់សម្លាប់ថ្នាក់ត្រឹមមេក្រុម មេភូមិអី អាចមានសិទ្ធិសម្លាប់គេបាន។ ក្នុងសម័យនោះ ខាងថ្នាក់

លើដូចមនុស្សខ្វាក់អ៊ីចឹង។ មិនដឹងថាហ្នឹង ខ្ញុំបាន ដូចថាមិនមែននិយាយឲ្យសម្រេចនៅឯណាទេ ខ្ញុំតែងតែប្រាជគ្នាឯងអី មិត្តភក្ដិជួបជុំទៅ និយាយពីរឿងការពិតដែលខ្ញុំបាននិយាយនេះ តែមិនមែនជាផ្លូវការអីឲ្យគេដឹងទេ ហ្នឹង ព្រោកប្រាជ្ញគ្នាលេងតើពាក្យហ្នឹង បាទ។

[១១:៣៦:០៥]

**ស៖** នេះ គឺជាការនិយាយលេងសើចហ្នឹង គួរឲ្យអស់សំណើចដែរ។ តែអ៊ីចឹងខ្ញុំចង់សួរលោកថា តើលោកបាននិយាយលេងហ្នឹងជាមួយអ្នកណាដែរ?

**ឆ៖** អ៊ូ! លែងដឹងហើយមិនដឹងជាមួយអ្នកណាៗទេ កាលនោះធំអីជាងរឿងត្រូវស្រាហើយចេះតែបែកបញ្ហាទៅ ដល់អ៊ីចឹងលែងដឹងឯណាឯណីខ្លះ បាទ។

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន ឥឡូវខ្ញុំសួរចប់ហើយ លោកប្រធាន។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។

លោក សេង សឿន ក្នុងឋានៈលោកជាដើមបណ្ដឹងរដ្ឋប្បវេណីចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការ ស្ដាប់អំពីរឿងហេតុទំនាក់ទំនងទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ទៅលើជនជាប់ចោទទាំងពីររូប លោក នួន ជា និង ខៀវ សំផន ដែលបានប៉ះពាល់ចំពោះលោកនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ មករា ឆ្នាំ១៩៧៩។ និងអំពីស្ថានភាពព្យសនកម្ម គឺការខូចខាតដែលកើតមានឡើងចំពោះលោក ជាអាទិ៍ការខូចខាតខាងរូបកាយ សម្ភារៈ ឬក៏ផ្លូវចិត្ត ហើយជាផលប៉ះពាល់ ផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋព្យសនកម្មផ្ទាល់ខ្លួន និងបានកើតមានឡើងពិតប្រាកដរហូតដល់បច្ចុប្បន្ននេះ ដែលនាំឲ្យលោកតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីប្ដឹងទាមទារសំណង និងជាសម្ព័ហភាពពីជនជាប់ចោទ។ បើសិនជាលោកមានបំណងដូច្នេះ គឺលោកអាចថ្លែងរៀបរាប់ពីស្ថានភាពទុក្ខសោកវេទនា និងព្យសនកម្មចំពោះមុខអង្គជំនុំជម្រះបាន ឬអាចតាំងសំណួរទៅជនជាប់ចោទតាមរយៈអង្គជំនុំជម្រះ។

[១១:៣៧:៥៥]

**លោក សេង សឿន៖**

ខ្ញុំសូមគោរពអង្គតុលាការជាទីគោរព។ ខ្ញុំមិនមានអីវែងឆ្ងាយទេ តែគ្រាន់តែសុំសំណូមពរខាង

តុលាការ ខ្ញុំសូមជម្រាបថា ដំណើរជីវិតរបស់ខ្ញុំដូចថាឆ្អែតហើយ តាំងពីឆ្នាំ៧០ មកដល់ពេលនេះ បម្រើជាតិរហូតពិការខ្លួន។ ឯងាកទៅបងប្អូនជីដូនៗ ឪពុកមាធំអី គេសម្លាប់ មិនមែនសម្លាប់ចោលទេ យកមកពីនេះៗសម្លាប់តែម្តងហើយ វាហួសនឹងនិយាយ មិនដឹងថាម៉េចទៀត។ ឯខ្លួនខ្ញុំទៀត ពិការហើយលទ្ធផលចុងក្រោយ បើនិយាយទៅថាឆ្អែតវាលែងព្រុសទៅហើយ។ នេះដំណើរជីវិតរបស់ខ្ញុំ វាមិនដឹងថ្លែងទៅប្រាប់តុលាការថាម៉េចទៀតទេ ខ្ញុំដូចអស់ ទៅសុំទៅឲ្យតុលាការជួយរកយុត្តិធម៌ឲ្យខ្ញុំផង ដើរមើលដំណើរជីវិតរបស់ខ្ញុំ បាទ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ សវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី សេង សឿន ដល់ទីបញ្ចប់ហើយ អង្គជំនុំជម្រះ អរគុណលោក ដែលបានចំណាយពេលវេលាមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី។ លោកអាចត្រឡប់ទៅវិញបានហើយ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងបុគ្គលិកអ្នកគាំពារអង្គភាពសាក្សី និងអ្នកជំនាញ ក្នុងការជូនដើមបណ្តឹងរូបនេះ វិលត្រឡប់ទៅកាន់លំនៅដ្ឋានវិញ។ ឥឡូវដល់ពេលឈប់សម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះរសៀល សូមអញ្ជើញវិលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

នៅរសៀលនេះ អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-281។ បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

សូមអញ្ជើញសម្រាក!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៤០ នាទី ដល់ម៉ោង ១៣:២៨ នាទី)*

[១៣:២៨:១៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះប្រកាសបន្តសវនាការ។

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-286 និងលោកស្រី ស៊ុន សូលីដា ជាបុគ្គលិកអង្គការ ធី.ភី.អូ អង្គុយអមដើមបណ្តឹងរដ្ឋប្បវេណីមកកាន់កន្លែងផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** ជម្រាបសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី តើលោកស្រីឈ្មោះអី?

**លោកស្រី ជា ឌៀប៖**

**ឆ៖** ខ្ញុំឈ្មោះ ជា ឌៀប។

**ស៖** លោកស្រីកើតនៅខែណា ថ្ងៃណា ឆ្នាំណា?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ស៖** លោកស្រីចាំមីក្រូហ្វូនដំណើរការចេញភ្លើងក្រហម ចាំលោកស្រីឆ្លើយ។

**ឆ៖** ខ្ញុំកើតនៅថ្ងៃទី០៧ ខែ៤ ឆ្នាំ១៩៥៤។

**ស៖** ទីកំណើតលោកស្រីនៅកន្លែងណា?

**ឆ៖** នៅភូមិប្រមាត់ដី ស្រុកចំការលើ ខេត្តកំពង់ចាម។

**ស៖** តើទីលំនៅបច្ចុប្បន្នលោកស្រីនៅឯណាដែរ?

**ឆ៖** នៅកន្លែងដដែល។

**ស៖** តើលោកស្រីប្រកបមុខរបរអ្វីដែលសព្វថ្ងៃ?

**ឆ៖** មុខរបរធ្វើស្រែចម្ការ។

**ស៖** តើឪពុកម្តាយបង្កើតលោកឈ្មោះអីដែរ?

**ឆ៖** ឪពុកខ្ញុំឈ្មោះ អ៊ុង ជា ម្តាយឈ្មោះ ផៃ ឡាយ។

[១៣:៣២:០៨]

**ស៖** តើប្តីលោកស្រីឈ្មោះអី ហើយមានកូនប៉ុន្មាននាក់?

**ឆ៖** មាន -- ប្តីខ្ញុំឈ្មោះ ស ធឿន កូនខ្ញុំមានបួននាក់។

**ស៖** អរគុណលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះកោះអញ្ជើញលោកស្រីមកផ្ដល់សក្ខីកម្មថ្ងៃនេះក្នុងឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះ ហេតុដូច្នេះ នៅចុងក្រោយបង្អស់នៃការផ្ដល់សក្ខីកម្មរបស់លោកស្រី លោកស្រីអាចមានសិទ្ធិធ្វើសេចក្ដីថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្ម មានន័យថា ផលអន្តរាយដែលកើតមានចំពោះលោកស្រីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើលោកស្រីមានបំណងធ្វើដូច្នេះ។

លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី តើលោកស្រីធ្លាប់ផ្ដល់សក្ខីកម្ម ឬក៏ផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេរយៈពេលកន្លងមក? ហើយប្រសិនបើមានធ្វើប៉ុន្មានដង? ធ្វើនៅកន្លែងណា?

**ឆ៖** ខ្ញុំជួបបានបីដង ប៉ុន្តែជួបនៅកន្លែងសាលាក្ដីតែម្ដង។

[១៣:៣៣:៣៣]

**ស៖** ហើយមុនពេលចូលមកមុខអង្គជំនុំជម្រះនេះ តើលោកបានពិនិត្យមើល ឬក៏បានអានន្ទូវកំណត់ហេតុដែលលោកស្រីបានផ្ដល់សក្ខីកម្មពីពេលមុនជាមួយអ្នកស៊ើបអង្កេត ដើម្បីរំឭកការចងចាំរបស់លោកស្រីដែរឬទេ?

**ឆ៖** ខ្ញុំបានអានរំឭកសាដើមវិញអស់ហើយ។

**ស៖** តាមសមត្ថភាពដែលលោកស្រីអាចដឹង និងចងចាំបាន តើលោកស្រីអាចបញ្ជាក់បានទេថា កំណត់ហេតុដែលស្ដាប់ចម្លើយ ដែលលោកស្រីបានអាន ដើម្បីរំឭកការចងចាំនោះ គឺពិតជាត្រឹមត្រូវសមស្របស៊ីសង្វាក់គ្នា ទៅនឹងសក្ខីកម្មដែលលោកស្រីបានផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីមុននោះដែរឬទេ?

**ឆ៖** ខ្ញុំបានពិនិត្យតាមដានទាំងអស់ហ្នឹង គឺពិតប្រាកដ ខ្ញុំមិនក្លែងបន្លំ គឺខ្ញុំឃើញប៉ុនណា ដឹងប៉ុនណា ខ្ញុំឆ្លើយប៉ុណ្ណឹង។

[១៣:៣៥:១៤]

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រី។ ក្នុងការសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ អនុវត្តតាមបញ្ញត្តិ៩១ ស្ទួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការសួរដេញដោលដើមបណ្ដឹងរូបនេះមុនភាគីដទៃទៀតនៃរឿងក្ដី។ ហើយសហមេធាវីនាំមុខ រួម

ជាមួយតំណាងសហព្រះរាជអាជ្ញាមានរយៈពេលពីរវគ្គ។ សូមអញ្ជើញមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន សូមគោរពលោកប្រធាន និងលោក លោកស្រី ចៅក្រម។ លោកប្រធានសូមអនុញ្ញាតប្រគល់វេទិកានេះជូនទៅលោកស្រីមេធាវី ស៊ីន សុវ៉ន ជាអ្នកសួរដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះលោកប្រធាន។

*(សម្រាករយៈពេលខ្លី)*

[១៣:៣៦:៣៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវី ស៊ីន សុវ៉ន អញ្ជើញ!

**លោកស្រី ស៊ីន សុវ៉ន៖**

ចាស សូមអរគុណលោកប្រធាន។ ចាស សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រី ចៅក្រម និងសូមគោរពអង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ស៊ីន សុវ៉ន៖**

**ស៖** ចាស សូមជម្រាបសួរផងដែរលោកស្រីដើមបណ្ដឹង។ ចាស ខ្ញុំឈ្មោះ ស៊ីន សុវ៉ន មេធាវីនៅអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ហើយជាមេធាវីតំណាងឲ្យដើមបណ្ដឹង។ ចាស ខ្ញុំសូមសួរសំណួរមួយចំនួនចំពោះអ្នកស្រី សូមអ្នកស្រីធ្វើការសហការ ដើម្បីឆ្លើយបញ្ជាក់ជូនអង្គជំនុំជម្រះជ្រាប ហើយសំណួររបស់ខ្ញុំហ្នឹងពាក់ព័ន្ធនឹងអង្គហេតុការរៀបការក្នុងសម័យខ្មែរក្រហម ប៉ុន្តែមុននឹងចូលអង្គហេតុរៀបការនៅសម័យខ្មែរក្រហម នាងខ្ញុំសូមជម្រាបសួរអ្នកស្រីថា មុនថ្ងៃ១៧ មេសា ៧៥ តើអ្នកស្រីរស់នៅទីណា? ភូមិអី? ឃុំអី? ស្រុកអី? ខេត្តអី?

[១៣:៣៧:៤៦]

**លោកស្រី ជា ឌៀប៖**

**ឆ៖** មុនឆ្នាំ៧៥ ក្នុងឆ្នាំ៧៤ ហ្នឹង ខ្ញុំនៅជាមួយក្រុមគ្រួសារ និងសមាជិកបងប្អូននិងម្ដាយឪពុកខ្ញុំ។ មុខរបររកស៊ីធ្វើចម្ការ ទីលំនៅនៅភូមិប្រមាត់ដី ស្រុកចំការលើ ខេត្តកំពង់ចាមដដែល។

**ស៖** ចាស សូមអរគុណ។ ចុះក្នុងពេលហ្នឹងអ្នកស្រីមានសមាជិកគ្រួសារប៉ុន្មាននាក់ដែរ អ្នកស្រី

អាចរៀបរាប់ជូនអង្គសវនាការជ្រាបបានទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយចាំមីក្រូហ្វូនដំណើរការចេញភ្លើងពណ៌ក្រហមចាំលោកស្រីឆ្លើយ។

**លោកស្រី ជា ឌៀប៖**

**ឆ៖** កាលពីមុនឆ្នាំ៧៥ យើងខ្ញុំនៅជាមួយឪពុកម្ដាយនិងក្រុមគ្រួសាររបស់យើងខ្ញុំ។ មុខរបររកស៊ីធ្វើស្រែ និងចម្ការចិញ្ចឹមជីវិត។

**សួរដោយលោកស្រី ស៊ីន សុវ៉ន៖**

**ស៖** ចុះបន្ទាប់មកទៀត តើអ្នកស្រីរស់នៅទីណាដែរ?

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវីអត់ទាន់បើកមីក្រូហ្វូនលោកស្រី។

**សួរដោយលោកស្រី ស៊ីន សុវ៉ន៖**

**ស៖** ចាស ចុះបន្ទាប់មកទៀត តើអ្នកស្រីរស់នៅក្នុងភូមិប្រមាត់ដីឬក៏ម៉េច? ចាស អ្នកស្រីសូមអ្នកស្រីជម្រាបបញ្ហាហ្នឹងមើល?

**លោកស្រី ជា ឌៀប៖**

**ឆ៖** នៅក្នុងឆ្នាំ៧៤ មិនដឹងខែប៉ុន្មានអីប៉ុន្មាន ប៉ុន្តែខ្ញុំបានចាកចេញពីក្រុមគ្រួសារខ្ញុំមកធ្វើជានារីកងទ័ព។ កងចល័តនិងកងទ័ព។

**ស៖** ចាស សូមអរគុណ។ ចាស អ្នកស្រីបានមានប្រសាសន៍ថាអ្នកស្រីចូលធ្វើជានារីកងទ័ព ខ្ញុំចង់ជម្រាបសួរថា តើអ្នកស្រីចូលធ្វើជានារីកងទ័ពហ្នឹង អ្នកស្រីចូលតាមរយៈអ្នកណាដែរអ្នកស្រី? ឈ្មោះអីដែរ? ហើយគាត់ធ្វើអីនៅឯណា?

**ឆ៖** ខ្ញុំចូលតាមរយៈមិត្តហាន និងមិត្តហៀន ជាគណៈ នៅជាគណៈកម្មាធិការស្រុកចំការលើ។

[១៣:៣៩:៥៧]

**ស៖** ចាស អ្នកស្រីចូលធ្វើនារីកងទ័ពនេះ អ្នកស្រីធ្វើជានារីកងទ័ព ឬក៏អ្នកស្រីធ្វើនៅកងចល័តអីណាមួយដែលអ្នកស្រីមានប្រសាសន៍អំមិញថា អ្នកស្រីធ្វើជានារីកងទ័ពផង ធ្វើជានារីកងចល័តផង។

តើអ្នកស្រីបញ្ជាក់កន្លែងហ្នឹងឲ្យច្បាស់មើល អ្នកស្រីធ្វើជានារីកងចល័ត ឬក៏ធ្វើជាអីផ្សេង?

**ឆ៖** នារី ខ្ញុំធ្វើជានារីកងចល័តហ្នឹង មិនហៅកងចល័ត គេថាកងទ័ពនារីស្នែង។ កងទ័ពនារីស្នែងហ្នឹង សម្រាប់សែងគ្រាប់ទៅមុខ មកវិញសែងអ្នករបួស អ្នកពលីមកក្រោយវិញ ពេលណាមានសង្គ្រាមម្ដងៗ។ ប៉ុនដល់ពេលណាដែលត្រូវឡើងវៃ ក៏ពួកខ្ញុំអាចមានជំនួយទៅជួយវៃគេដែរ នៅពេលនុ៎ង។ អាចដកកម្លាំងទៅវៃជាមួយគេដែរ។

**ស៖** ចាស សូមអរគុណ។ ក្នុងពេលដែលអ្នកស្រីធ្វើជានារីស្នែងផង ធ្វើជាកងទ័ពផង ពេលនុ៎ងអ្នកស្រីមានសមាជិកប៉ុន្មាននាក់ ហើយអ្នកណាជាអ្នកក្ដោបក្ដាប់អ្នកស្រី ជាមេអ្នកស្រីផ្ទាល់ហ្នឹង ឈ្មោះអីដែរអ្នកស្រី?

**ឆ៖** នៅក្នុងកន្លែងរបស់ខ្ញុំ គឺមានមួយវរសេនាតូច។ ក្នុងនុ៎ងមានគ្នាចំនួន៣០០នាក់ជាង ប៉ុន្តែចែកជាកង ជាកន្លែង -- មួយកងដាក់មួយកន្លែងៗ។ គឺមានបីកន្លែងពួកខ្ញុំហ្នឹង។

**ស៖** ធ្វើអីខ្លះដែរ នៅកន្លែងណាអ្នកស្រី?

**ឆ៖** នៅម្តុំ--

[១៣:៤១:៣៤]

**ប្រធានអង្គជំនុំ៖**

ឈប់ៗដើមបណ្ដឹងរដ្ឋប្បវេណី ចាំមីក្រូហ្វូនប្រតិបត្តិការសិន ចាំឆ្លើយ។

**លោកស្រី ជា ឌៀប៖**

**ឆ៖** ពួកកងទ័ពខ្ញុំ កាលពីនុ៎ងមានចំនួនបីកងធំ។ បីកងធំចែកគ្នាជាបីកន្លែង ថាបីកន្លែង។ កងខ្ញុំទី១ គឺនៅម្តុំអំពិលជ្រុំ ខាងជើងភ្នំប្រុសភ្នំស្រី ខេត្តកំពង់ចាមនេះ។ ហើយមួយកងទៀត ឯទ្រាន នៅឯកើតណោះទ្រាន មិនដឹងត្រង់ណា ខាងកើតទៀត។ ហើយមួយកងទៀត នៅតាមជួរមាត់ទន្លេ។ ខ្ញុំដឹងប៉ុណ្ណឹង។

**សួរដោយលោកស្រី ស៊ីន សុវ៉ន៖**

**ស៖** ចាស អ្នកស្រីចូលមកទីក្រុងភ្នំពេញដំបូងនៅថ្ងៃណាដែរអ្នកស្រី?

**ឆ៖** ខែ០១ ដែលពេលចាប់វៃទីក្រុង គឺខ្ញុំចូលមកនៅតាមជាយៗក្រុងទេ ដល់ពេលកងទ័ពគេវៃចូលវៃរំដោះបានទីក្រុងភ្នំពេញ បានខ្ញុំបានចូលមកដល់ដែរ។

**ស៖** ចាសអរគុណ។ អ្នកស្រីបានជម្រាបអង្គសវនាការថា អ្នកស្រីចូលមកទីក្រុងភ្នំពេញដំបូង

ក្នុងខែ០១ អ្នកស្រីចូលជាយៗក្រុង។ ពេលនោះអ្នកស្រីធ្វើអីដែរ?

**ឆ៖** គឺមកដល់ជាយក្រុងភ្នំពេញហ្នឹង ចាប់វើដំបូងគឺខ្ញុំនៅជញ្ជូនគ្រាប់ ដឹក -- ឌុបអ្នក ដឹក -- សែងអ្នករបួស និងអ្នកពលី ប៉ុនដល់ពេលចូលវើត្រពាំងកក់ ត្រពាំងព្រាយ គឺពួកយើងខ្ញុំក៏ចូលវើ រួមចំណែកជាមួយយុទ្ធជន ទ័ពយុទ្ធជនដែរ។

[១៣:៤៣:១៩]

**ស៖** ចាស ចុះបន្ទាប់ទៀតៗ នៅថ្ងៃខែណាដែលអ្នកស្រីចូលមកដល់ទីក្រុងភ្នំពេញ?

**ឆ៖** ក្នុងថ្ងៃ១៧ មេសា រួចមក ពួកខ្ញុំបានចូលមកនៅក្នុងទីក្រុងភ្នំពេញ គឺចូលក្រោយហើយទេ ថ្ងៃទី១៧ មេសា ពួកទ័ពយុទ្ធជនចូលមុន ពួកទ័ពនារីមកតាមក្រោយ មកតាមក្រោយៗទេ។

**ស៖** ចាស អរគុណ។ ចុះពេលមក អ្នកស្រីធ្វើដែរ ហើយស្នាក់នៅកន្លែងណា?

**ឆ៖** ខ្ញុំមកដំបូងចូលក្នុងទីក្រុងភ្នំពេញ គឺគេឲ្យមកសម្រាកជើង នៅខាងត្បូងវត្តភ្នំមួយរយៈ នៅតាមផ្ទះប្រជាជនវត្តភ្នំហ្នឹង ប៉ុនអត់មានប្រជាជនទេ។ ដល់មួយរយៈក្រោយមកក៏ គេបញ្ជូនពួកខ្ញុំឲ្យទៅនៅខាងត្បូងពេទ្យកាល់ម៉ែតមួយរយៈទៀត។ មួយរយៈក្រោយមក មិនដឹងប៉ុន្មានខែប៉ុន្មានថ្ងៃ មិនដឹងខែថ្ងៃទេ ប៉ុនដល់មកពួកគេដកពួកខ្ញុំហ្នឹងមួយចំនួន។ ក្នុងបីៗកងធំ គេដកទៅឃោធានៅ ទៅខាងឃោធាមួយកងធំ ដាក់មកពាណិជ្ជកម្មពួកខ្ញុំហ្នឹងមួយកងធំ ហើយមួយកងធំទៀត យកទៅកំពង់សោម ខាងស្រែអំបិល។ ខ្ញុំដឹងប៉ុណ្ណឹង។

**ស៖** ចាស អរគុណ។ ចុះកងធំរបស់អ្នកស្រី ដែលនៅខាងពាណិជ្ជកម្មនោះ អ្នកស្រីនៅភ្នំពេញ អ្នកស្រីធ្វើអីដែរ?

**ឆ៖** កងធំរបស់ខ្ញុំមកនៅទីក្រុងភ្នំពេញ គឺផ្នែកជញ្ជូនជយភណ្ឌ វើតាមផ្ទះប្រជាជន។

[១៣:៤៥:០៧]

**ស៖** ចាសសូមអរគុណ។ សូមអ្នកស្រីបញ្ជាក់ឲ្យច្បាស់ពាក្យថា “ជយភណ្ឌ”។ ជយភណ្ឌ ហ្នឹង អ្នកស្រីអត់ យកជយភណ្ឌ យកពីកន្លែងណាទៅកន្លែងណា ហើយជយភណ្ឌហ្នឹងមានរបស់អីខ្លះ? សូមអ្នកស្រីជម្រាបអង្គសវនាការឲ្យបានជ្រាប។

**ឆ៖** នៅថ្ងៃមួយ ពេលខ្ញុំរៀបចំជយភណ្ឌហ្នឹង គឺពួកខាងខ្ញុំហ្នឹង មានមួយចំនួនធំទៅដឹកប្រាក់សុទ្ធតែគ្រឿងប្រាក់ទាំងអស់។ ដឹក ដល់ខ្ញុំសួរថា “ដឹកពីណាមក? ថាដឹកពីក្នុងវាំង” ប៉ុនខ្ញុំផ្ទាល់អត់បានទៅទេ ខ្ញុំបាននៅរៀបកន្លែង។ គេដឹកមកដល់ហើយ បានខ្ញុំបានជួយរៀបគេ។ ហើយរៀបកន្លែងដែល

រៀបហ្នឹង គឺនៅម្តុំផ្សារចាស់ខាងជើងផ្សារចាស់ ផ្ទះធំមួយហ្នឹង ហើយខាងកើតរោងចក្រជីបតុងពីសង្គម រោងចក្រស្បែកជើងជីបតុងពីសង្គម។ ហើយរូបចម្លាក់ហ្នឹងមានរូបគ្រប់មុខទាំងអស់ មានរូបសត្វស្អីៗសព្វមុខរឿង រូបអប្សរាៗ ប៉ុនៗមនុស្សធំហ្នឹង។ ច្រើនណាស់ យកមកដាក់ឡើងពេញមួយផ្ទះនុំង សុទ្ធតែអប្សរា ហើយនិងសុទ្ធតែគ្រឿងប្រាក់ទាំងអស់។

**ស៖** ចាសអរគុណអ្នកស្រីចាស។ ក្នុងពេលដែលអ្នកស្រីមកធ្វើការទីក្រុងភ្នំពេញ តើអ្នកស្រីដែលធ្លាប់បានជួបថ្នាក់ដឹកនាំណាខ្លះដែរអ្នកស្រី?

**ឆ៖** ពេលខ្ញុំមកធ្វើការនៅទីក្រុងភ្នំពេញ ខ្ញុំបានជួបអ្នកដឹកនាំ។ ថ្ងៃមួយ ស្តេច សុផាណាវង្ស មកពីប្រទេសឡាវ មកដាក់ទូតនៅប្រទេសខ្មែរ។ ពេលនោះខ្ញុំឃើញអ្នកទៅទទួលមានតាំងពី តាប៉ែន នុត, អៀង សារី, អៀង ធីរិទ្ធ ហើយនិងថ្នាក់ដឹកលើ -- ថ្នាក់លើច្រើនទៀត ប៉ុនខ្ញុំមិនបានៗមើលអស់ទេ ប៉ុនដឹងអ្នកណាខ្លះទៀត ខ្ញុំមិនដឹងទេ ខ្ញុំដឹងប៉ុណ្ណឹង។

[១៣:៤៧:០២]

**ស៖** ចាសអរគុណ។ អ៊ីចឹងលោកតា ខៀវ សំផន អ្នកស្រីដែលបានជួបគាត់ទេ?

**ឆ៖** ដែលជួប។ លោកតា ខៀវ សំផន ខ្ញុំបានជួបគាត់នៅវត្ត នៅកន្លែងវត្តឧណ្ណាលោម គឺគាត់បើកសន្និបាត។ គាត់បើកសិទ្ធិទាំងអស់ហៅនារីយុទ្ធជនទៅរៀននៅវត្តឧណ្ណាលោម។ ហ្នឹងខ្ញុំបានជួបគាត់នៅកន្លែងហ្នឹងម្តង។ ហើយម្តងក្រោយទៀត ខ្ញុំបានជួបគាត់ស្តាតបុរីកីឡា ហ្នឹងថ្ងៃដែលកាត់ទោស ហ៊ូ នឹម, ហ៊ូ យន់ ខ្ញុំក៏បានចូលរួមដែរ គាត់ជាទីប្រឹក្សានៅកន្លែងនុំង។ ដល់ពេលខ្ញុំទៅហ្នឹង គាត់ហៅពួកនីរសារ ហ៊ូ នឹម, ហ៊ូ យន់ មកសួរចម្លើយ។ ដល់ថ្ងៃហ្នឹងក៏ខ្ញុំមិនបាននៅចប់ចុងចប់ដើមដែរ ព្រោះដល់ពេលនីរសារ ហ៊ូ នឹម, ហ៊ូ យន់ ឆ្លើយអ៊ីចឹងទៅមួយរយ:ទៅ ខ្ញុំក៏គ្រុនញាក់ទៅគេយកខ្ញុំមកដេកពេទ្យទៅ។ ខ្ញុំក៏បានតែត្រឹមនុំង អត់បានតទៅទៀតទេ ហ្នឹងបានជួបគាត់ត្រឹមហ្នឹងទៀតហ្នឹង ហ្នឹង តាខៀវ សំផន ផ្ទាល់ហ្មង ប៉ុនជំនាន់ហ្នឹងខ្ញុំហៅគាត់ថា អ៊ំៗ។

**ស៖** ចាស អរគុណ។ អ្នកស្រីបានជម្រាបអង្គសវនាការអម្បាញ់មិញថា អ្នកស្រីបានជួបលោកតា ខៀវ សំផន ពីរដង។ ម្តងគឺជួបនៅពេលប្រជុំនៅវត្តឧណ្ណាលោម។ អ៊ីចឹងខ្ញុំចង់ជម្រាបសួរអ្នកស្រីថា ក្នុងពេលដែលគាត់ធ្វើប្រជុំនៅវត្តឧណ្ណាលោម តើគាត់ប្រជុំនិយាយអំពីអីដែរអ្នកស្រី? សូមអ្នកស្រីរៀបរាប់បន្តិចមើល។

[១៣:៤៨:៣២]

**ឆ៖** គាត់និយាយថា "សូមស្នើសមមិត្តនារីយុទ្ធជនទាំងអស់ប្រឹងធ្វើការជូនរដ្ឋ ហើយយុទ្ធជនដែលយុទ្ធជននារីដែលមានអាយុពី ១៩ឆ្នាំឡើងទៅ ឲ្យតាមកម្មាភិបាល តាមមុខក្រសួងទាំងអស់ឲ្យរៀបចំឲ្យមានគ្រួសារទៅ" គាត់ថាអ៊ីចឹង កុំទុកឲ្យនៅច្រើនពេក។

**ស៖** ចាស អរគុណ។ ដែលគាត់មានប្រសាសន៍ថា យុវជន យុវនារី រៀបចំឲ្យមានគ្រួសារទាំងអស់ហ្នឹង គាត់មានបាននិយាយថា យុវជន យុវនារី ចាប់ពីអាយុប៉ុន្មានត្រូវរៀបការ ហើយអ្នកដែលរៀបការហ្នឹង លុះត្រាថាអ្នកទាំងនុំង ដូចថាមានការស្រឡាញ់គ្នា ស្ម័គ្រចិត្ត អត់មានការចាប់បង្ខំអីៗ។ គាត់មាននិយាយបញ្ហាហ្នឹងទេ?

**ឆ៖** គាត់មិនបាននិយាយថា ស្រឡាញ់គ្នាស្រឡាញ់អីទេ គាត់គ្រាន់តែប្រាប់ថាឲ្យរៀបចំគ្រួសារទៅ តាំងពីអាយុ ១៩ឡើងទៅ យុទ្ធជនអាយុ២៥ អីទុកធ្វើអីទៀត។ ស្នើតាមក្រសួងមន្ទីរទាំងអស់ឲ្យគិតគូររៀបការយុទ្ធជននារីឲ្យអស់ទៅ គាត់គ្រាន់ -- ទុកតែក្មេងៗសិនទៅបានហើយ។ គាត់និយាយអ៊ីចឹង។

**ស៖** ចាសៗអរគុណអ្នកស្រី។ ដែលគាត់និយាយអំពីពាក្យថា យុវជន យុវនារី ដែលចាស់ៗហើយឲ្យរៀបការ។ អ៊ីចឹងគាត់មានដែលមានបានពន្យល់ប្រាប់នៅពេលដែលកំពុងតែនិយាយថា យុវជន យុវនារី រៀបការៗក្នុងគោលបំណងអ្វីដែរអ្នកស្រី?

[១៣:៥០:១០]

**ឆ៖** គាត់ថារៀបការទៅ ដើម្បីបង្កើតកូន កើតចៅឲ្យបានគ្នា បានកូនចៅច្រើនទៅ ដើម្បីជាកម្លាំងការពារប្រទេសជាតិ។ គាត់និយាយប៉ុណ្ណឹង។

**ស៖** ចាស អរគុណ។ ចាស អ៊ីចឹងខ្ញុំសុំជម្រាបសួរអ្នកស្រីចូលពាក់ព័ន្ធនឹងអង្គហេតុនៃការរៀបការ។ អ៊ីចឹងខ្ញុំចង់សួរអ្នកស្រីថា ដែលលោកតា ខៀវ សំផន គាត់លើកបញ្ហាពាក់ព័ន្ធនឹងយុវជនយុវនារីដែលពេញវ័យឲ្យរៀបការហ្នឹង តើអ្នកស្រីហ្នឹងមានបានរៀបការនៅក្នុងសម័យខ្មែរក្រហមហ្នឹងទេ?

**ឆ៖** ការពី -- ក្រោយពីគាត់និយាយរួច មិនទាន់បានប៉ុន្មានផងពួកយើងខ្ញុំក៏ត្រូវរៀនការជំនាន់ខ្មែរក្រហមនោះដែរ។

**ស៖** ចាស អរគុណ។ អ្នកស្រីរៀបក្នុងឆ្នាំណាដែរ?

**ឆ៖** ក្នុងឆ្នាំ១៩៧៥ ប៉ុនមិនដឹងខែណា ថ្ងៃណា ខ្ញុំអត់ដឹងខែដឹងថ្ងៃផង គ្មានអីមើលផង។

**ស៖** អ៊ីចឹងអ្នកស្រី អ្នកណាដែលជាអ្នកផ្តួចផ្តើម ឬជាអ្នកដែលថាចាប់ផ្តើម ដូចថាជាអ្នកកោះហៅអ្នកស្រី ឬក៏ប្រាប់អ្នកស្រីថា អ្នកស្រីត្រូវរៀបការ រៀបអី? អ្នកណាជាអ្នកហៅអ្នកស្រី អ្នកប្រាប់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អ្នកស្រីហ្នឹង?

**ធ៖** អ្នកដែលគិតគូរផ្តួងផ្តើមឲ្យខ្ញុំរៀបគ្រួសារ គឺប្រធានរបស់ខ្ញុំឈ្មោះ ពូផាន់។ គាត់ជាប្រធានគ្រប់មុខព្រួញរបស់ខ្ញុំផ្ទាល់តែម្តង។

[១៣:៥១:៥០]

**ស៖** ចាស អរគុណ។ អ៊ីចឹងអ្នកស្រី ពេលដែលប្រធានមុខព្រួញប្រាប់ឲ្យអ្នកស្រីរៀបការ អ្នកស្រីអត់មានការប្រកែកទេ? អ្នកស្រីព្រមរៀបការតាមការកំណត់ ឬក៏តាមការចាត់តាំងរបស់ប្រធានមុខព្រួញនុ៎ងតែម្តង ឬក៏ម៉េចដែរ?

**ធ៖** ពេលដែលគាត់ហៅខ្ញុំសួរលើកទី១អ៊ីចឹង ខ្ញុំឆ្លើយថាខ្ញុំអត់យកទេ គិតតែគូចាស់ៗសិនទៅ ខ្ញុំមិនទាន់រៀបទេ ព្រោះខ្ញុំនៅក្មេងណាស់ អាចបម្រើអង្គការបានយូរទៀត។ សូមមិត្តបងរៀបឲ្យ រៀបតែចាស់ៗមុនទៅ លើកទី១។ លើកទី២ ខ្ញុំប្រកែកបាន លើកទី១។ លើកទី២ គាត់ហៅខ្ញុំសួរទៀត។ សួរទៀត ខ្ញុំឆ្លើយតែពាក្យដដែលៗ។ ដល់លើទី៣ គាត់ឲ្យខ្ញុំមកមន្ទីរគ-៦ នៅផ្សារអូរឫស្សី ឲ្យមកជួបមេថ្នាក់លើទៀត។ ខ្ញុំក៏មកតាមគាត់។ ដល់ពេលមកតាមគាត់អ៊ីចឹងទៅ មេថ្នាក់លើគេថា មិត្តជាកូនអង្គការ បើមិត្តនៅជាមួយម៉ែឪ មិត្តគោរពម៉ែឪ។ មិត្តនៅជាមួយអង្គការ មិត្តគោរពអង្គការ។ ដូច្នេះត្រូវធ្វើតាមអង្គការចាត់តាំង។ ដល់ខ្ញុំប្រកែកម្តងពីរដងហើយមិនបាន លើកទី៣ ខ្ញុំថាធ្វើម៉េចក៏ធ្វើទៅ ស្រេចតែចិត្តទៅ បើខ្ញុំប្រកែកមិនបានហើយ។ តែប៉ុណ្ណឹង។

[១៣:៥៣:០៧]

**ស៖** ចាស សូមអរគុណ។ អ៊ីចឹងលើកទី៣ បានអ្នកស្រីព្រមរៀបការណា?

**ធ៖** ចាស។

**ស៖** ចាស អ៊ីចឹងខ្ញុំចង់សួរអ្នកស្រីរៀបការ អ្នកស្រីរៀបការនៅកន្លែងណាដែរ? ហើយនៅពេលណាដែរ អ្នកស្រី?

**ធ៖** ពួកខ្ញុំរៀបការនៅផ្សារដើមគ។

**ស៖** ពេលណាដែរ អ្នកស្រី?

**ធ៖** ពេលរៀបការ ពេលថ្ងៃ។ ពេលព្រឹកឡើងគេរៀបកម្មវិធី ទល់ថ្ងៃត្រង់គឺរួចតែម្តង។

**ស៖** អ្នកស្រីដឹងពីការរៀបការរបស់អ្នកស្រី អ្នកស្រីមានដឹងមុនទេ មានដឹងព័ត៌មានមុនថា អ្នកស្រី ត្រូវបានអង្គការគេឲ្យអ្នកស្រីរៀបការ អ្នកស្រីមានបានដឹងព័ត៌មានហ្នឹងមុនទេ?

**ឆ៖** ក្រោយពីសួរខ្ញុំ មេហ្នឹងសួរខ្ញុំរួចទៅ រយៈកាលនុ៎ង គេប្រាប់ថាបីថ្ងៃទៀត ខ្ញុំត្រូវទៅរៀប-ការ។ ដល់រយៈបីថ្ងៃទៀត បានៗទៅមែន។

**ស៖** ចាស អរគុណ។ អ៊ីចឹងក្នុងអំឡុងពេលបីថ្ងៃក្រោយមក បានអ្នកស្រីរៀបការ។ អ៊ីចឹងមែនទេ?

**ឆ៖** ចាស។

**ស៖** ចាស ក្នុងអំឡុងពេលបីថ្ងៃហ្នឹង អ្នកស្រីមានបានផ្តល់ព័ត៌មានទៅឪពុកម្តាយអ្នកស្រី បងប្អូនអ្នកស្រី ឬក៏បានពិភាក្សាជាមួយឪពុកម្តាយថា ឥឡូវហ្នឹងអ្នកស្រីត្រូវបានអង្គការឲ្យរៀបការហើយអ៊ីចេះអ៊ីចុះ ហើយមានការយល់ព្រមពីឪពុកម្តាយអ្នកស្រី មានបានពិភាក្សាជាមួយគាត់ទេ បញ្ហាហ្នឹង?

[១៣:៥៤:៥៦]

**ឆ៖** ខ្ញុំមិនដែលបានពិភាក្សាជាមួយម៉ែឪបងប្អូនទេ ព្រោះនៅឆ្ងាយ។ ទោះបីសុំគេទៅ ក៏គេមិនទៅ ក៏គេមិនឲ្យទៅដែរ គឺស្រេចតែអង្គការតែហ្នងហ្នឹង។

**ស៖** ចាស អរគុណអ្នកស្រី។ អ៊ីចឹងពិធីរៀបការរបស់អ្នកស្រីហ្នឹង ឪពុកម្តាយអ្នកស្រី បងប្អូនអ្នកស្រី អត់មានបានចូលរួមក្នុងពិធីហ្នឹងទេ មែនទេ?

**ឆ៖** ម្តាយឪពុក បងប្អូនរបស់ខ្ញុំ អត់បានចូលរួមទេ មានតែអង្គការទេដែលចូលរួម។

**ស៖** ចាស អរគុណ។ ខ្ញុំចង់ជម្រាបសួរអ្នកស្រីថា អ្នកស្រី ហើយគូអ្នកស្រីហ្នឹង អនាគតប្តីអ្នកស្រី អ្នកស្រីមានដែលស្គាល់គ្នាមុនទេ? តើគាត់នៅឯណា គាត់ធ្វើអី អ្នកស្រីមានស្គាល់គាត់មុនទេ?

**ឆ៖** មិនដែលស្គាល់ មិនដែលឃើញមុខម៉េចទេ ទល់តែថ្ងៃរៀបតែហ្នងហ្នឹង បានជួបគ្នាតែហ្នងហ្នឹង មិនដែលស្គាល់ប្រវត្តិ ស្គាល់អី ត្រង់ណា ត្រង់ណី អត់បន្តិចសោះ។

**ស៖** ចុះអ្នកស្រីរៀបការ អ្នកស្រី ពេលអ្នកស្រីរៀបការ អ្នកស្រីរៀបការប៉ុន្មានគូដែរ អ្នកស្រី?

**ឆ៖** ពេលរៀបការខ្ញុំ មាន១២គូ។

[១៣:៥៦:៣១]

**ស៖** ចាស។ តើអ្នកស្រីមានស្គាល់ឈ្មោះអ្នកដែលរៀបការជាមួយអ្នកស្រីទាំង១២គូហ្នឹងទេ?

**ឆ៖** ក្នុង១២គូ ខ្ញុំស្គាល់បានបីគូ។ ស្គាល់តែ មិត្តសៃ មិត្តថា មិត្តសៅ មិត្តវី ហើយនិង មិត្តជី មិត្តលាង។ ស្គាល់តែប៉ុណ្ណឹងទេ ក្រៅពីហ្នឹងអត់ស្គាល់។

**ស៖** ចាស អរគុណ។ ខ្ញុំចង់ជម្រាបសួរអ្នកស្រីៗ បញ្ជាក់កន្លែងហ្នឹងឡើងវិញឲ្យបានច្បាស់។ ខ្ញុំ

ចង់សួរថា ក្នុង១២គូដែលរៀបការជាមួយអ្នកស្រី ចាស សួរថា ខាង១គូអ្នកស្រី ខាងនារី១ គឺ១ពួកគាត់នៅក្នុងកងជាមួយអ្នកស្រីទាំងអស់ ឬក៏មកពីកងផ្សេងខ្លះដែរ?

**ឆ៖** មកពីកងផ្សេង១គ្នា នារី យុទ្ធជនហ្នឹង ខ្ញុំក៏អត់ដែលស្គាល់គ្នាអស់ដែរ ព្រោះមុខព្រួញខុសគ្នា។ ដល់ពេលរៀប បានមកជុំគ្នានៅ១ផ្សារដើមគហ្នឹងតែម្តង ដឹងកងណា១ អត់បានស្គាល់ផង។

**ស៖** ចាស១ អរគុណ។ ចាស សូមអ្នកស្រីបញ្ជាក់ឲ្យច្បាស់ ពាក់ព័ន្ធនឹងបញ្ហាខាងគ្រួសារអ្នកស្រី។ តើគ្រួសារអ្នកស្រី អ្នកស្រីមានដឹងថា ពីមុនគាត់ធ្វើអ្វីដែរ ហើយគាត់នៅកន្លែងណាដែរ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

អ្នកស្រីដើមបណ្តឹងរដ្ឋប្បវេណី ចាំមីក្រូហ្វូនដំណើរការសិន។

**លោកស្រី ជា ឌៀប៖**

**ឆ៖** ក្នុងគ្រួសារទាំង១២គូរៀបហ្នឹង គឺថាផ្នែកនារី ក៏សុទ្ធតែនារីកងស្នែង និងយោធាដែរ។ ចំណែកយុទ្ធជនសុទ្ធតែយោធាទាំងអស់។ ប៉ុនពួកយុទ្ធជនទាំងអស់ហ្នឹង សុទ្ធយុទ្ធជនពិការ ព្រោះពិការវៃខ្លាំងមិនកើត គេយកមកដាក់មួយកន្លែង។ ដាក់កន្លែង ដល់ពេលរៀបការហ្នឹង គេយកសុទ្ធជនពិការហ្នឹងមករៀប។ ប៉ុនពិការ មិនពិការខ្លាំងទេ ខ្លះក៏កំបុតដៃមួយចំហៀង ខ្លះខ្វះ ខ្លះខ្វាក់ភ្នែកមួយចំហៀង ខ្លះទៀតគ្រាន់តែដូចថា ខូចដៃបន្តិច ជើងបន្តិច អីទៅ គ្រាន់ថា ដើរកើតប៉េលប៉ាលអីបន្តិច១អីចឹង១ទៅ។ សុទ្ធតែអ្នកពិការទាំងអស់ រៀបមួយសាខ្ញុំហ្នឹង។

[១៣:៥៩:០១]

**សួរដោយលោកស្រី ស៊ីន សុវ៉ាន៖**

**ស៖** ចាស អរគុណ។ អីចឹងអ្នកស្រីថា យុវជនដែលយកមករៀបការ សុទ្ធតែអ្នកពិការ។ អីចឹងគូរបស់អ្នកស្រី គឺជាជនពិការ ឃោធិនពិការដែរ ឬក៏ម៉េចដែរអ្នកស្រី?

**ឆ៖** គ្រួសាររបស់ខ្ញុំផ្ទាល់ គឺពិការជើងដែរ ប៉ុន្តែគ្រាន់តែជើងហ្នឹង ដើរប៉េល១ មិនកំបុត មិនអីទេ គ្រាន់ដើរទៅប៉េល១មួយចំហៀង។

**ស៖** ចាស អរគុណ។ ចាស ខ្ញុំចង់ឲ្យអ្នកស្រីបញ្ជាក់ឲ្យបានច្បាស់ពីពិធីនៃរៀបការ។ ពិធីរៀបការនៅក្នុងសម័យខ្មែរក្រហម គេរៀបការដោយ គេធ្វើម៉េចដែរអ្នកស្រីពិធីគេ គេចាប់ផ្តើមឡើង គេធ្វើម៉េចដែរ?

**ធ៖** ក្នុងពិធីរៀបការនៅជំនាន់ខ្មែរក្រហមហ្នឹង គឺចាប់ចូលដំបូងអ៊ីចឹងទៅ គេហៅដាក់តាមគូអ៊ីចឹង ព្រោះពួកខ្ញុំ នាងខ្ញុំទាំងអស់គ្នាសុទ្ធតែអត់ស្គាល់ទេ។ ដឹងមួយណា ដឹងគូមួយណាទេ ទាល់គេហៅឈ្មោះ គេដឹកដៃដាក់ហៅឈ្មោះ ដឹកដៃដាក់ទៅ បានដឹងគូណាៗ។ ដល់ពេលចូលទៅដល់អ៊ីចឹងទៅ ក៏អង្គការគេផ្ដែផ្ដាំ ដូចថាឲ្យគោរពអង្គការវិន័យអីបន្តិចបន្តួចអ៊ីចឹងទៅ ក៏គេឲ្យសាមីខ្លួនហ្នឹងប្ដេជ្ញាចិត្តៗ ហើយកន្លែងប្ដេជ្ញាចិត្តហ្នឹង គ្មានស្អីទេ មានតែកណ្ដៀវ ហើយនិងកម្រងកួរស្រូវ កន្លែងប្ដេជ្ញាហ្នឹង។ អត់មានម៉ែឪបងប្អូនជីដូនជីតាណាមកជាមួយទេ។ មានតែប៉ុណ្ណឹង។

[១៤:០០:៣១]

**ស៖** ចាស អរគុណ។ អ្នកស្រីបានជម្រាបអង្គសវនាការថា គូមួយៗឡើងប្ដេជ្ញាចិត្ត ខ្ញុំចង់ជម្រាបសួរអ្នកស្រីថា អត្ថន័យនៃការប្ដេជ្ញាចិត្តគេឲ្យនិយាយអីខ្លះដែរអ្នកស្រី?

**ធ៖** អង្គការគ្រាន់តែណែនាំថា ឲ្យគោរពអង្គការវិន័យ កុំឲ្យដល់រៀបគ្រួសារឲ្យហើយ កុំឲ្យធ្វើឲ្យអង្គការពិបាកអ៊ីចឹងទៅ ឲ្យចេះស្រឡាញ់គ្នា ហើយចេះខំប្រឹងកសាង ខំប្រឹងធ្វើការងារកសាងប្រទេសជាតិឲ្យរីកចម្រើនអ៊ីចឹងទៅ។ មានតែប៉ុណ្ណឹង។

**ស៖** ចាស អរគុណអ្នកស្រី។ តើអ្នកណាជាអ្នកចាប់ផ្ដើមកម្មវិធីនៃការប្ដេជ្ញាហ្នឹងអ្នកស្រី?

**ធ៖** នៅកម្មវិធីហ្នឹង ខ្ញុំមិនដឹងអ្នកណាជាអ្នកចាប់ផ្ដើមទេ ខ្ញុំអត់ដឹងដែរ ព្រោះខ្ញុំទៅហ្នឹងឃើញតែមិត្តបងៗហ្នឹង ដឹងខាងណាអង្គការអីៗ ខ្ញុំអត់បានដឹងដែរ។ ដឹងគេរៀបចាប់ផ្ដើមកម្មវិធី ខ្ញុំអត់ដឹង អត់ស្គាល់អង្គការខាងអីៗ អស់ស្គាល់ផង។

**ស៖** ចាស អរគុណ។ គូទាំង១២ ដែលរៀបការជាមួយអ្នកស្រីហ្នឹង ជាពិសេសគូរបស់អ្នកស្រីពេលរៀបការអ្នកស្រី ហើយប្ដីអ្នកស្រីហ្នឹងមានអាយុប្រហែលប៉ុន្មានដែរ អ្នកស្រី?

**ធ៖** អាយុរបស់ខ្ញុំ គឺ១៩ឆ្នាំ គ្រួសារខ្ញុំ២៦ឆ្នាំ ហើយគូផ្សេងៗទៀតក៏ស្របាលៗ ខ្ញុំហ្នឹងដែរ។ មួយស្រករៗតែខ្ញុំនឹងដែរ។

[១៤:០២:៣៣]

**ស៖** ចាស សូមអរគុណ។ អ្នកស្រីបានជម្រាបអង្គសវនាការថា គូរបស់អ្នកស្រីពិការ។ អ៊ីចឹងខ្ញុំចង់ជម្រាបសួរអ្នកស្រីថា ក្នុង១២គូៗដែលអង្គការគេឲ្យឡើងប្ដេជ្ញាជាមួយអ្នកស្រី តើអ្នកស្រីក្ដី គូផ្សេងៗក្ដី មានសិទ្ធិក្នុងការជ្រើសរើសថា ១២គូហ្នឹង ខ្ញុំយក ខ្ញុំអត់យកគូមួយនេះទេ ខ្ញុំសុំយកមួយគូមួយនេះ ឬក៏យើងដោះដូរគ្នាថា ខ្ញុំអត់ស្រឡាញ់នេះទេ ខ្ញុំស្រឡាញ់អ្នកនេះ យើងមានសិទ្ធិក្នុងការជ្រើសរើស

គូក្នុងចំណោម១២គូហ្នឹងទេ អ្នកស្រី?

**ផ៖** ក្នុង១២គូហ្នឹង គ្មានការជ្រើសរើសរបស់យុទ្ធជននារីទេ អង្គការដាក់មួយណា យកមួយហ្នឹងហើយ។ អត់មានបើកឱ្យជ្រើសរើសផង។

**ស៖** ចាស អរគុណ។ អ៊ីចឹងក្រោយពេលដែលអ្នកស្រីឡើងប្ដេជ្ញាចិត្តហើយ តើគេឱ្យគូរបស់អ្នកស្រីទាំង១២គូនោះទៅសម្រាកនៅកន្លែងណាដែរ?

**ផ៖** ពេលរៀបការហើយហ្នឹង ក្នុង១២គូហ្នឹង គេចែកតាមមុខព្រួញ។ មុខព្រួញយើងខ្ញុំមានបីគូ ហើយមុខព្រួញផ្សេងៗទៀត ដឹងមានប៉ុន្មានៗ ខ្ញុំអត់ដឹងដែរ។ ខ្ញុំដឹងតែខាងមុខព្រួញខ្ញុំហ្នឹងមានបីគូ មកខាងមុខព្រួញខ្ញុំវិញមក។

[១៤:០៤:០១]

**ស៖** មុខព្រួញអ្នកស្រីបីគូនុ៎ង ទីតាំងទៅសម្រាក ដែលអ្នកស្រីត្រូវទៅសម្រាកនៅពេលដែលប្ដេជ្ញាហើយ ទៅសម្រាកនៅកន្លែងណា?

**ផ៖** គឺគូខ្ញុំទាំងបីគូហ្នឹង គឺទៅសម្រាកនៅផ្សារទួលទំពូង គឺកន្លែងខ្ញុំធ្វើការនៅកន្លែងនុ៎ង។

**ស៖** ចាស អរគុណ។ សូមអ្នកស្រីរៀបរាប់ជូនអង្គសវនាការជ្រាបមើលថា យប់ដំបូងនៃថ្ងៃប្ដេជ្ញាចិត្តហើយនោះ តើមានអ្វីកើតឡើងចំពោះអ្នកស្រី?

**ផ៖** ពេលខ្ញុំទៅសម្រាកនៅផ្សារទួលទំពូងហ្នឹង គឺមានបងម្នាក់ប្រាប់ខ្ញុំថា "មិត្តឯងប្រយ័ត្នខ្លួនណា៎ គេកំពុងតែតាមដានហើយ"។ ដល់ពេលខ្ញុំទៅសម្រាកនៅផ្ទះមួយហ្នឹង គឺបីនាក់ ផ្ទះហ្នឹងមានបន្ទប់ច្រើន។ ទៅបីនាក់ហ្នឹង បីគូហ្នឹង វាបីបន្ទប់ហ្នឹង។ ដល់ពេលយប់ ខ្ញុំចាំៗស្ដាប់មើល ចាំស្ដាប់មើល ឮសម្រិបជើងៗដើរទៅត្រឹបៗអ៊ីចឹងទៅ ដល់ពេលទៅឡើងជណ្ដើរ។ ទៅឡើងជណ្ដើរអ៊ីចឹង ឮជណ្ដើរប៉ុន្មានកាំខ្ញុំចាំរាប់មើល ខ្ញុំអង្គុយរាប់មើលគ្រប់កាំទាំងអស់ គឺឈ្លបទៅតាមដានពួកខ្ញុំ។ ហើយទៅអ៊ីចឹងខ្ញុំចេះតែអង្គុយស្ដាប់មើលទៅ នៅទៅដល់ឡើងទៅស្ងាត់។ ស្ងាត់មួយសន្ទុះធំអ៊ីចឹងបានពួកហ្នឹងគេចុះមកវិញ។ ពួកខ្ញុំអត់ហ៊ានមាត់ទេ នាំគ្នាសម្ងំ អត់ហ៊ានមាត់ទេ។

[១៤:០៥:៣០]

**ស៖** ចាស អរគុណ។ ខ្ញុំសូមសួរអ្នកស្រីបន្ត ក្នុងយប់ដំបូងនៃថ្ងៃប្ដេជ្ញាចិត្តហ្នឹង តើអ្នកស្រីព្រមរួមដំណេកជាមួយប្ដីអ្នកស្រីទេ?

**ផ៖** អត់មានបានរួមដំណេកជាមួយប្ដីរបស់ខ្ញុំទេ ព្រោះបានអី ខាងណាខ្លាចឈ្លប ខ្លួនខ្ញុំផ្ទាល់

ណាខ្លាចប្តី មួយទៀតខ្លាចឈ្លបទៀត ម្ល៉ោះហើយសុខចិត្តនាំគ្នាសម្ងំ អត់ហ៊ានមាត់ ហ៊ានកអីទាំងអស់។

**ស៖** ក្រោយពេលប្តេជ្ញាចិត្តហើយ តើអ្នកស្រីនិងប្តីអ្នកស្រីរស់នៅជាមួយគ្នាបានប៉ុន្មានថ្ងៃដែរ?

**ឆ៖** ពេលរៀបការរួច គេឲ្យមកសម្រាកនៅនឹងកន្លែងបានតែបីថ្ងៃទេ ទៅគេចែកកន្លែងដូចថាប្តីនៅណាឲ្យទៅនុ៎ង។ ចំណែកខ្លួនខ្ញុំៗនៅធ្វើការកន្លែងខ្ញុំទៅ ចំណែកប្តីខ្ញុំទៅធ្វើការកន្លែងគេផ្សេងទៅ។ គ្រប់គូទាំងអស់ ធ្វើអ៊ីចឹងដូចគ្នាទាំងអស់។

**ស៖** ចាស អរគុណ។ អ៊ីចឹងពេលណាដែលអ្នកស្រីព្រមរួមដំណេកជាមួយប្តីអ្នកស្រីជាលើកដំបូង?

**ឆ៖** រយៈកាលហ្នឹងពី១០ថ្ងៃទៅកន្លះខែបានគេឲ្យមកជួបគ្នាម្តង ពេលនោះក៏ធម្មតាប្តីប្រពន្ធទាល់តែយូរហើយឃើញថាជួបជុំគ្នាក៏រួមរក្សទៅ។

[១៤:០៧:១៤]

**ស៖** ចាស អរគុណ។ ក្នុងការរួមដំណេកយប់ដំបូង ដែលអ្នកស្រីថាបែកគ្នាកន្លះខែក្រោយមកបានអ្នកស្រីព្រមរួមដំណេកជាមួយប្តីអ្នកស្រី។ អ៊ីចឹងខ្ញុំចង់សួរអ្នកស្រីថា ជម្រើសនៃការរួមដំណេកដែលកន្លះខែក្រោយពេលដែលឡើងប្តេជ្ញាចិត្តហើយហ្នឹងជាជម្រើសរបស់អ្នកណា ជាជម្រើសរបស់ប្តីអ្នកស្រី ឬក៏ជាជម្រើសរួមគ្នា?

**ឆ៖** ជាជម្រើសរបស់ខាងបុរស។

**ស៖** ចាស អរគុណ។ ខ្ញុំចង់សួរអ្នកស្រីត្រឡប់ក្រោយវិញ ពាក់ព័ន្ធនឹងបញ្ហាអ្នកស្រីថា ក្រោយពេលប្តេជ្ញាចិត្តហើយយប់ដំបូងហ្នឹងអ្នកស្រីដឹងថាឈ្លបគេមកតាមដាន។ អ៊ីចឹងខ្ញុំចង់សួរអ្នកស្រីថា បើក្នុងករណីដែលឈ្លបតាមដានទៅឃើញថា គូណាមួយក្នុងចំណោម ១២គូហ្នឹងមិនមានការចុះសម្រុងនឹងគ្នា តើមានអ្វីកើតឡើងលើគូហ្នឹង អ្នកស្រីមានដឹងទេបញ្ហាហ្នឹង?

**ឆ៖** បើសិនជាឈ្លបតាមដានបានដឹងគូណាមិនត្រូវគ្នា គឺគេយកទៅកសាង។ គឺគេហៅយើងទៅកសាងតែម្តងអាហ្នឹង ឲ្យតែឈ្លបគេដឹង។

**ស៖** ចាស អរគុណ។ ខ្ញុំចង់សួរអ្នកស្រីៗថាកន្លះខែក្រោយមកបានអ្នកស្រីជួបប្តីអ្នកស្រី ចុះខែបន្ទាប់ៗទៀត តើអ្នកស្រីជួបប្តីអ្នកស្រីញឹកញាប់ទេ?

[១៤:០៩:១៩]

**ឆ៖** នៅក្នុងរបបនោះមិនថារូបខ្ញុំផ្ទាល់ក៏ជាអ្នកណាទេ គឺថារយៈកាលយ៉ាងរហ័សហើយត្រឹម

01364558



មួយអាទិត្យឲ្យជួបម្តង មានកន្លះខែ ទៅមួយខែ បើគ្រួសារទៅធ្វើការឆ្ងាយទៀតមានតែមួយខែពីរខែបាន ៗជួបគ្នាម្តង។ ដូចគ្រួសារខ្ញុំជាដើម ពេលរៀបរួចមិនបានប៉ុន្មានផងគេបញ្ជូនទៅឲ្យនៅខាងភ្នំគិរីរម្យ ទៅរកបន្លែ ទៅរកម្ហូបមកផ្គត់ផ្គង់កន្លែង។ ម្ល៉ោះហើយគ្មានបានជួបគ្នា មួយខែពីរខែទើបឃើញមកដល់ម្តងអីទេ។ ហ្នឹងគ្រួសារខ្ញុំផ្ទាល់តែម្តង។

**ស៖** ចាស អរគុណ។ ចុះអ្នកស្រីផ្ទាល់ចាស អ្នកស្រីថាអ្នកស្រីរៀបការ អ្នកស្រីអត់ពេញចិត្តទេ។ អ៊ីចឹងបានន័យថា មិនពេញចិត្ត គឺបង្ខំហើយ។ ចាស អ្នកស្រីត្រូវបានគេបង្ខំឲ្យអ្នកស្រីរៀបការ។ តើអ្នកស្រីមានអារម្មណ៍--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារលោក ខៀវ សំផន!

[១៤:១០:២២]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះការសន្និដ្ឋានរបស់អ្នកស្រីមេធាវី ដែលប្រើពាក្យថា "ជាការបង្ខំ"។ កន្លងមកអ្នកស្រីដើមបណ្តឹងរដ្ឋប្បវេណី មិនបានប្រើពាក្យនេះនៅឡើយទេ ហើយជាក់ស្តែង តាមសក្ខីកម្មរបស់គាត់ គាត់បានបដិសេធពីរដងរួចហើយ ហើយលើកទី២ គាត់ប្រើពាក្យថា "គាត់យល់ព្រម" ដូច្នេះមិនមានការបង្ខំទេ។ បាទ សូមអរគុណ។

**លោកស្រី ស៊ីន សុវ៉ន៖**

ចាស សូមអរគុណ។ ចាស ចំពោះការដែលនាងខ្ញុំជម្រាបសួរសំណួរទៅដើមបណ្តឹងថា ពាក់ព័ន្ធនឹងបញ្ហាថាបង្ខំ ពីព្រោះដើមបណ្តឹង គាត់បានជម្រាបហើយ លើកទី១ លើកទី២ គាត់បានបដិសេធមិនព្រមរៀបការ ដល់លើកទី៣ គាត់បដិសេធដែរ ប៉ុន្តែបដិសេធមិនបាន បានន័យថាគាត់បង្ខំចិត្ត។ គាត់បាននិយាយរួចហើយ គាត់ថាទៅម៉េចក៏ទៅចុះ បើពេលហ្នឹងគេមិនព្រមហើយ គេមិនព្រមស្តាប់តាមការបដិសេធរបស់គាត់ថាគាត់មិនព្រមរៀបការ គាត់ថាទៅម៉េចទៅចុះ ហ្នឹងទី១។ ទី២ ទៀត គាត់ក៏បានជម្រាបថា គាត់មិនៗស្ម័គ្រចិត្តជាមួយប្តីរបស់គាត់ទេ រៀបការហើយ គាត់មិនបានរួមភេទ គឺគាត់អត់ស្រឡាញ់ប្តីគាត់។ ការដែលមិនស្រឡាញ់ ការដែលមិនព្រមព្រៀងនេះ វាកើតចេញពីឆន្ទៈហ្នឹង គឺជាឆន្ទៈដោយបង្ខំ។

[១៤:១១:៤២]

**ប្រធានអង្គជំនុំ៖**

សូមលោកស្រីមេធាវីសួរសំណួរទៅតាមអង្គហេតុ ហើយសូមកុំឱ្យមានការធ្វើការសន្និដ្ឋាន។

**លោកស្រី ស៊ីន សុវ៉ន៖**

ចាស សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី ស៊ីន សុវ៉ន៖**

**ស៖** អ៊ីចឹងខ្ញុំចង់ជម្រាបសួរអ្នកស្រីបន្តសំណួរ។ ចំពោះអ្នកស្រីផ្ទាល់ អ្នកស្រីនិងប្ដីអ្នកស្រីដូច មិនបានស្រឡាញ់គ្នា មិនបានស្គាល់គ្នាពីមុន តើអ្នកស្រីមានអារម្មណ៍យ៉ាងម៉េចដែរ អ្នកស្រីមានគិតថា អ្នកស្រីទៅថ្ងៃមុខ អ្នកស្រីនិងប្ដីអ្នកស្រីនឹងបែកផ្លូវគ្នាឬក៏យ៉ាងម៉េច អ្នកស្រីមានបានគិតបញ្ហាហ្នឹងដែរ?

**លោកស្រី ជា ឡៀប៖**

**ឆ៖** ខ្ញុំមានគ្រួសារខ្ញុំផ្ទាល់ តាមតែខ្ញុំមិនពេញចិត្ត ប៉ុន្តែខ្ញុំរក មិនរក -- មិនដឹងធ្វើដូចម្ដេចតាម ការឈឺចាប់របស់ខ្លួននោះ ឈឺចាប់ហើយ ឈឺចាប់នឹងអង្គការបង្ខំឱ្យរៀបការ។ ប៉ុន្តែដល់ពេលដែលថា បើសិនជាខ្ញុំ ហើយរៀបការរួចហើយ ទោះបីខ្ញុំក្រឡេសម៉េច ក៏ទៅមិនរួច បើខ្ញុំរត់ទៅពួនណា ក៏ពួនមិន ជិតដែរ បើអង្គការភ្នែកម្នាស់យ៉ាងនេះ រួចមិនដឹងទៅពួនត្រង់ណា ទៅនៅត្រង់ណា ម្ល៉ោះហើយបើថា បើ និយាយទៅថាទ្រាំតាមដំណើរ។ និយាយឆាប់ចប់តែម្ដងអ៊ីចឹងទៅ។

[១៤:១២:៥៩]

**ស៖** ចាស អរគុណ។ ចាស ខ្ញុំចង់ជម្រាបសួរអ្នកស្រីថា អ្នកស្រីជានារីស្មែងដែលមានស្នាដៃល្អ ចំពោះបក្ស។ បក្សរៀបការឱ្យអ្នកស្រីមានគូស្រករ។ ចាស ហើយខ្ញុំចង់សួរថា ពេលនេះបក្សរៀបការ ឱ្យអ្នកស្រីមានគូស្រករ តើអ្នកស្រីសប្បាយចិត្តនឹងការរៀបការហ្នឹង ឬក៏អ្នកស្រីមានការពិបាកចិត្តនឹង ការរៀបការ ដែលបក្ស ដែលអង្គការរៀបការឱ្យអ្នកស្រីហ្នឹង?

**ឆ៖** ដូចខ្ញុំបាននិយាយអ៊ីចឹងថា ខ្ញុំមិនពេញចិត្តទេ ខ្ញុំក៏មិនចង់ទាន់ចង់បានប្ដីដែរ ប៉ុន្តែបើអង្គការ រៀបហើយ ដូចខ្ញុំបាននិយាយ ធ្វើម៉េច ថាគេដូចខ្ញុំនិយាយទៅ ថាទៅតាមដំណើរទៅ បើអង្គការឱ្យរៀប ការហើយ បើខ្ញុំប្រកែក ក៏ប្រកែកមិនបាន ម្ល៉ោះហើយមានទៅតាមដំណើរដែលអង្គការរៀបការឱ្យ ទៅ តាមហ្នឹងទៅ មិនដឹងធ្វើម៉េច ប្រកែកម៉េចទៀត បើទៅហើយ។

**ស៖** ចាស អ្នកស្រី ខ្ញុំចង់ជម្រាបសួរអ្នកស្រីថា ឱ្យអ្នកស្រីឆ្លើយថា តើអ្នកស្រីសប្បាយចិត្តក្នុង ការរៀបគូស្រករហ្នឹងទេ?

**ឆ៖** នៅពេលដែលអង្គការរៀបគូស្រករនេះ ខ្ញុំគ្មានសប្បាយចិត្តអីម៉ាបន្តិចណាទេ ខ្ញុំមានតែទឹកភ្នែករហូតហ្នឹង។ តាំងពីមិនទាន់ចូលផ្ទឹមរហូតផ្ទឹម ផ្ទឹមរួចទៀត ខ្ញុំយំរាល់តែថ្ងៃ មិនថាយប់ មិនថាថ្ងៃទេ ព្រោះខ្ញុំ ខ្ញុំឈឺចិត្តណាស់ ប៉ុន្តែមិនដឹងធ្វើម៉េច។ តូចចិត្ត។

[១៤:១៤:៤០]

**ស៖** ចាស អរគុណ។ អ្នកស្រីសូមអ្នកស្រីបញ្ជាក់ឲ្យច្បាស់ អ្នកស្រីថាអ្នកស្រីមិនមានការពេញចិត្តជាមួយប្ដីអ្នកស្រីទេ អ្នកស្រីទឹកភ្នែករហូត តាំងពីមិនទាន់ផ្ទឹម រហូតដល់ពេលផ្ទឹម។ អ៊ីចឹងខ្ញុំចង់សួរអ្នកស្រីថា អង្គការដែលឲ្យអ្នកស្រីប្ដេជ្ញាចិត្តហ្នឹង គេមានធ្វើពិធីដូចសម័យបច្ចុប្បន្ន មានការផ្ទឹម មានការបាចផ្កាស្លាអ៊ីចឹងដូចគ្នា ឬក៏ម៉េច? អ្នកស្រីបញ្ជាក់កន្លែងហ្នឹងឲ្យបានច្បាស់បន្តិចមើលអ្នកស្រី?

**ឆ៖** ដែលពេលរៀបការហ្នឹង ដូចខ្ញុំបាននិយាយអ៊ីចឹង ថាគ្មានផ្ទឹម គ្មានអីបាចផ្កាស្លាអីទេ។ មានគ្រាន់តែហៅទៅ ហៅឈ្មោះដាក់គូណា១អ៊ីចឹងទៅ បញ្ចូលតាមគូទៅ ហើយអង្គការណែនាំបន្តិចបន្តួចអ៊ីចឹងទៅ ក៏គោរពទង់បក្សអ៊ីចឹងទៅ គឺរួចជាស្រេចទៅហើយ។ ហើយឡើងប្ដេជ្ញាចិត្តគោរពទង់បក្សអ៊ីចឹងទៅ។ ធ្វើមិនបានមួយម៉ោងផងហ្នឹង។

**ស៖** ចាស អរគុណ។ ចាស ខ្ញុំចង់ឲ្យអ្នកស្រីធ្វើការប្រៀបធៀបមើល រវាងការឡើងប្ដេជ្ញាចិត្ត គឺការរៀបគ្រួសារនៅក្នុងសម័យខ្មែរក្រហម និងការរៀបអាពាហ៍ពិពាហ៍ ឬក៏ការរៀបការមុនសម័យខ្មែរក្រហមក៏ដូចជាសម័យបច្ចុប្បន្ន តើមានភាពខុសគ្នាយ៉ាងម៉េចដែរអ្នកស្រី?

[១៤:១៦:១៤]

**ឆ៖** បើនិយាយពីប្រៀបធៀបរៀបការនៅជំនាន់ខ្មែរក្រហម និងសម័យមុន១ខ្មែរក្រហម មកក្រោយខ្មែរក្រហម គឺថាខុសគ្នាដាច់។ ដូចសម័យខ្មែរក្រហមរៀបការតែហៅដាក់១ ម្ដងបួនដប់គូ ម្ដងបួនប្រាំគូ ម្ដង១០០គូ ក៏មានដែរ។ រួចចុះចំណែកសម័យឥឡូវនេះ គេរៀបការម្ដងតែមួយគូ១ ហើយមានភ្លេងមានភ្ញៀវ មានម៉ែមានឪ មានយាយតា ជីដូនជីតា បងប្អូន ហើយមានហែជំនួន ហែផ្កាស្លា បាចផ្កាស្លា បើប្រៀបធៀបខុសគ្នា មិនដឹងប្រដូចទៅនឹងស្អីទេនេះ បើប្រៀបដូចមេឃនិងដីទៅ ក៏វាមិនតិចជាងផង។ បានថាខ្ញុំតូចចិត្តដែរហ្នឹង ដល់ឃើញសព្វថ្ងៃ មកឃើញសម័យឥឡូវនិងសម័យពីដើម តូចចិត្តនឹងវាសនាខ្លួនឯង។

**ស៖** ចាសអរគុណ។ ចាស អ៊ីចឹងខ្ញុំជម្រាបសួរអ្នកស្រីពាក់ព័ន្ធនឹងការឈឺចាប់ផ្លូវកាយ ផ្លូវចិត្ត និងការបាត់បង់សាច់ញាតិ និងទ្រព្យសម្បត្តិ។ អ៊ីចឹងខ្ញុំចង់ជម្រាបសួរអ្នកស្រីថា នៅពេលដែលអ្នកស្រី

នឹកឃើញពីពិធីប្តេជ្ញាចិត្ត គឺការរៀបការរបស់អ្នកស្រីជាពិសេស ការរួមដំណេកដំបូងរបស់អ្នកស្រីជាមួយប្តីអ្នកស្រីដែលអ្នកស្រីមិនបានស្រឡាញ់ប្តី តើពេលដែលអ្នកស្រីនឹកឃើញពីបញ្ហាហ្នឹង តើអ្នកស្រីមានអារម្មណ៍យ៉ាងម៉េចដែរ?

**ឆ៖** ពេលណាខ្ញុំនឹកឃើញ ពេលដែលខ្ញុំមិនពេញចិត្តនឹងគ្រួសារ មិនពេញចិត្តនឹងអង្គការរៀបគ្រួសារ គឺថាក្នុងចិត្តក្តុកក្តួលឈឺចាប់ចុកណែន ប៉ុនមិនដឹងនិយាយថាម៉េច ឆ្លើយថាម៉េចទៀត មានតែប៉ុណ្ណឹង។

[១៤:១៨:០២]

**ស៖** ចាសអរគុណ។ តើនៅក្នុងសម័យ ៣ឆ្នាំ ៨ខែ ២០ថ្ងៃហ្នឹង តើអ្នកស្រីមានបាត់បង់សាច់ញាតិ បងប្អូន ឬអ្នកជាទីស្រឡាញ់នៅសម័យហ្នឹងទេអ្នកស្រី?

**ឆ៖** បើនិយាយពីការបាត់បង់វិញ យើងខ្ញុំបាត់បង់ច្រើនណាស់។ មកធ្វើបដិវត្តន៍ថា ដើម្បីការពារសមរភូមិខាងក្រោយ តែការពិត មកអាល័យតែប្រឹងពីមុខ ឯក្រោយនោះបាត់បង បាត់ប្អូន បាត់ម្តាយ -- បាត់មីង បាត់មា អស់រលីង។ គិតទៅខ្ញុំឈឺចិត្តណាស់ ខ្ញុំឈឺចិត្តទល់សព្វថ្ងៃហ្នឹង។

**ស៖** ចាសអរគុណ។ អ្នកស្រីថាបាត់បង់សាច់ញាតិ បងប្អូន អ្នកជាទីស្រឡាញ់របស់អ្នកស្រីក្នុងសម័យហ្នឹង អ្នកស្រីមានការឈឺចិត្ត។ ខ្ញុំចង់សួរថា អ្នកស្រីបាត់បង់ចំនួនប៉ុន្មាននាក់ដែរ ក្នុងសម័យហ្នឹង?

**ឆ៖** ចំពោះខ្លួនខ្ញុំផ្ទាល់ បាត់បង់បងប្អូនៗបង្កើតមានចំនួនបួននាក់ និង ក្មួយ។ ក្មួយៗទៀត គឺអស់ច្រើនណាស់ប្រហែលជាងដប់ ប្រហែលប្រាំដណ្តប់នាក់។ ចំណែកឪពុកមា ជីតា និងឪពុកមា អស់ប្រហែល ១០នាក់ទៀត មានតែលើសផង ប៉ុនខ្ញុំថាឲ្យតិចប៉ុណ្ណឹង។ បានថាខ្ញុំឈឺចិត្តណាស់សព្វថ្ងៃនេះ ខ្ញុំនឹកឃើញរឿងបងប្អូន នឹកឃើញដល់មីងមា ជីដូនជីតាឡើង ខ្ញុំទឹកភ្នែកខ្ញុំតែងតែៗហូរជានិច្ច មិនថានៅផ្ទះ នៅកន្លែងណាទេ ធ្វើការប៉ុនណាក៏ខ្ញុំនឹកឃើញ ខ្ញុំហូរទឹកភ្នែកជាប់ដែរ។

[១៤:១៩:៥៨]

**ស៖** ចាស សូមអរគុណ។ តើអ្នកស្រីមានអារម្មណ៍ដូចម្តេចដែរ បន្ថែមលើការឈឺចាប់ផ្ទាល់ខ្លួនរបស់អ្នកស្រី ក្រោយពេលដែលថាសាច់ញាតិ បងប្អូន អ្នកជាទីស្រឡាញ់របស់អ្នកស្រី ដែលបានបាត់បង់ជីវិតដោយអយុត្តិធម៌ហ្នឹង? តើអ្នកស្រីមានការឈឺចាប់ប៉ុនណាដែរ?

**ឆ៖** ការបាត់បង់បងប្អូន ជីដូនជីតា មីងមា ក្នុងឈឺចាប់របស់ខ្ញុំ មានការឈឺចាប់ណាស់សព្វថ្ងៃ

នេះ។ ម្ល៉ោះហើយខ្ញុំមានតែតុលាការទេ ដើម្បីជួយដោះស្រាយដល់យើងខ្ញុំ ឲ្យខ្ញុំធូរស្បើយពីការទុក្ខសោកទាំងប៉ុន្មាន។

**ស៖** ចាស អរគុណ។ ចុះនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យហ្នឹង អ្នកស្រីមានបាន មានបាត់បង់សម្ភារៈ ផ្ទះសម្បែង ដីធ្លី គោក្របី អីទេអ្នកស្រី?

**ឆ៖** ចំពោះខ្លួនខ្ញុំផ្ទាល់ តាំងពីសម័យនោះមក ខ្ញុំនឹកឃើញថា ខ្ញុំឈឺចុកចាប់ រីងរៃក្នុងខ្លួនរកអ្វីប្រៀបផ្ទឹមមិនបាន ព្រោះវិលទៅដល់ផ្ទះវិញ គោក្របី ផ្ទះសម្បែង ស្រែចម្ការអស់រលីង។ ចំណែកឯបងប្អូនក៏អស់ទៀត ដូច្នេះ ខ្ញុំមានតែការទុក្ខព្រួយ។ សព្វថ្ងៃនេះកើតទុក្ខរីករៃរហូត គ្មានពេលថ្ងៃល្ហែ។

[១៤:២១:៥១]

**ស៖** ចាស អរគុណ។ តើអ្វីទៅដែលធ្វើឲ្យអ្នកស្រីឈឺចាប់ ដែលអ្នកស្រីចងចាំមិនភ្លេចចំពោះរូបអ្នកស្រីហ្នឹង តើអ្វីដែលធ្វើឲ្យអ្នកស្រីឈឺចាប់ខ្លាំងជាងគេ ដែលអ្នកស្រីចងចាំមិនភ្លេចរហូតដល់បច្ចុប្បន្នហ្នឹង តើអ្វី? អ្វីខ្លះអ្នកស្រី?

**ឆ៖** ខ្ញុំចង់ចាំមិនភ្លេចដែលគេសម្លាប់ឪពុក -- អ៎! បងប្អូន ឪពុកម្ដាយខ្ញុំនៅទេ។ ស្លាប់បងប្អូនមាមីង ប្អូនបង្កើត បងបង្កើតអស់។ ខ្ញុំឈឺចាប់មែនទែន ដែលប្អូនប្រុសខ្ញុំមួយដែលបន្ទាប់ខ្ញុំ។ ពេលទៅឃើញគេសីលធម៌ ពេលឃើញគេសីលធម៌ គេចាប់បានគេយកទៅចងជើងឡើងលើ យោលទង្គិចនឹងដើមអំពិល។ សាច់ឡើងសស្កុស ឡើងខ្មៅរោលអស់។ ហើយចំណែកឯមុខ ស្បែកជើងកង់ឡាន។ គេវៃឡើងជាំមុខអស់រលីង ហើយក៏មិនដឹងគេយកទៅទម្លាក់អណ្ដូងចោលកន្លែងណាទៀត។ បានថា គេប្រាប់ថាទម្លាក់អណ្ដូង ប៉ុនមិនដឹងគេប្រាប់ កន្លែងទម្លាក់កន្លែងណា។ បានថាខ្ញុំឈឺចាប់ណាស់ ខ្ញុំអាណិតប្អូន។ ខ្ញុំខ្លោចចិត្តរឿងប្អូនខ្ញុំណាស់។ ចំណែកបងៗមាមីងដែលមិនឃើញ ខ្ញុំមិនតូចចិត្តទេ។ ខ្ញុំមកតូចចិត្តនឹងប្អូនប្រុសខ្ញុំមួយ ខ្ញុំតូចចិត្តជាងគេបំផុត។ មុននឹងស្លាប់ គេធ្វើទារុណកម្មគ្នា តើគ្នាខុសអ្វី គ្នាមិនបានធ្វើអីខុសផង។

**ស៖** ចាស អរគុណ។ អ៊ីចឹងខ្ញុំចង់ជម្រាបសួរអ្នកស្រីថា តើអ្នកស្រីបច្ចុប្បន្ន អ្នកស្រីកសាងជីវិតយ៉ាងដូចម្ដេចដែរ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំក្រោយឆ្នាំ១៩៧៩ហ្នឹង ពីព្រោះអ្នកស្រីបានបាត់បង់ទ្រព្យសម្បត្តិ ផ្ទះសម្បែង គោក្របីដីធ្លីអស់ហើយ តើស្ថានភាពជីវភាពរបស់អ្នកស្រីមានយ៉ាងម៉េចដែរ?

**ឆ៖** ក្រោយពីបាត់បង បង់ទ្រព្យសម្បត្តិ បងប្អូនមីងមាមក គោក្របី ស្រែចម្ការអស់រលីង ខ្ញុំគឺបង្កបមុខរបបរកស៊ីចិញ្ចឹមជីវិតនៅក្រុមគ្រួសារខ្ញុំសព្វថ្ងៃ ទាំងឪពុកម្ដាយ និងនៅប្អូនពីរនាក់ ហើយនិង

គ្រួសាររបស់ខ្ញុំ កូនរបស់ខ្ញុំ គឺលំបាកវេទនាណាស់។ ចាប់កសាងឡើងធ្វើតែស្រែចម្ការនឹងចប គ្មានស្ពឺភ្ជួររាស់ គ្មាន -- ដកស្ទូងនឹងកម្លាំងមនុស្ស បានបន្តិចបន្តួចគ្រាន់តែចិញ្ចឹមជីវិត។ តាំងពីពេលនោះមក ខ្លួនខ្ញុំក៏ចេះតែឈឺថ្កាត់គ្រាំគ្រាវីងរ៉ៃ រហូតធ្វើអីមិនកើត។ រហូតដល់ពេលបច្ចុប្បន្ននេះ បន្សល់ទុកនៅតែទុក្ខពិបាករហូតដល់ថ្ងៃស្លាប់។

[១៤:២៥:១០]

**ស៖** ចាស អរគុណ។ ពាក់ព័ន្ធរឿងបញ្ហាសុខភាពរបស់អ្នកស្រី ក្រោយរបបខ្មែរក្រហមដួលរលំ តើស្ថានភាពសុខភាពអ្នកស្រី មានអ្វីបន្សល់ទុកតាំងពីសម័យខ្មែរក្រហម រហូតដល់បច្ចុប្បន្ន តើសុខភាពអ្នកស្រីយ៉ាងម៉េចដែរ?

**ឆ៖** ក្រោយៗរបបខ្មែរក្រហមបានផុតទៅ រូបនាងខ្ញុំផ្ទាល់ គឺលំបាកវេទនា។ ដូចខ្ញុំនិយាយអំមិញ ធ្វើស្រែចម្ការតែនឹងចប ភ្ជួរៗរាស់តែនឹងចប ដោយគ្មានស្ពឺធ្វើនឹងគេទេ ដោយខ្វះខាតជាថវិកា មិនអាចទិញអីបាន ម្ល៉ោះហើយលំបាកវេទនាខ្លួនខ្ញុំផ្ទាល់ ក៏ស្គមរីងរ៉ៃ រហូតកើតទុក្ខ រហូតដល់សព្វថ្ងៃនេះកើតទុក្ខរហូតដល់សព្វថ្ងៃ គឺមានតែរហូតដល់ថ្ងៃស្លាប់ទៀត ដើម្បីបន្សល់ទុកការលំបាកវេទនារបស់ខ្ញុំ និងការឈឺចាប់របស់ខ្ញុំពីរបបដែលកន្លងផុតទៅនោះ។

**លោកស្រី ស៊ីន សុវ៉ន៖**

ចាស សូមអរគុណ។ សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ លោកប្រធានចាស។ សូមអរគុណលោកស្រីដើមបណ្ដឹង។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីលោកស្រីមេធាវី។ សូមអញ្ជើញលោកព្រះរាជអាជ្ញាមានសំណួរលើដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ជម្រាបសួរលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំនឹងបន្តសួរលោកស្រី រហូតដល់ពេលឈប់សម្រាកនៅម៉ោងពីរ សែសិបនាទី។ ខ្ញុំនឹងត្រឡប់មកនិយាយអំពីហេតុការណ៍ដែលកើតឡើងនៅ

ចន្លោះឆ្នាំ៧៤ និង ឆ្នាំ៧៥។ មុននេះលោកស្រីបាននិយាយថាលោកស្រីបានចូលបដិវត្តន៍។ ខ្ញុំចង់សួរលោកស្រីថា នៅពេលលោកស្រីចូលបដិវត្តន៍ហើយមកនោះ ក្រោយមកទៀតនោះ តើលោកស្រីបានចូលទៅធ្វើជាសមាជិកយុវកកទេ?

[១៤:២៧:៥៤]

**លោកស្រី ជា ឌៀប៖**

**ឆ៖** ស្អីសមាជិក ខ្ញុំសុំសួរវិញថា សមាជិកយុវកកហ្នឹងស្អីគេ? ខ្ញុំអត់ស្គាល់ អត់យល់។

**ស៖** បាទ <>បក្សកុម្មុយនីស្តកម្ពុជា <មានរួមបញ្ចូលទាំង>បក្ខជន ហើយនិង<សមាជិកជា>យុវជន <គឺអ្នកដែលមិនទាន់រៀបការ>។ អ៊ីចឹង<យុវជនដែលមិនទាន់រៀបការអាចជាសមាជិកនៃចលនាកុម្មុយនីស្ត> ខ្ញុំចង់ដឹងថា លោកស្រីមានធ្វើជាសមាជិកនៃចលនាកុម្មុយនីស្តហ្នឹង ដែលគេហៅថាយុវកកហ្នឹងទេ?

**ឆ៖** ខ្ញុំអត់យល់រឿងយុវកកហ្នឹង។ ខ្ញុំគ្រាន់ថា ខ្ញុំចូលទៅជាសមាជិកក្នុង ដូចខ្ញុំប្រាប់ពីដំបូងថា ខ្ញុំចូលទៅជាកងចល័ត -- កងយោធានារី ហើយនិងកងស្នែង សែងៗអ្នករបួស អ្នកពលី។ ប៉ុនដល់កងយុវកកអំមិញហ្នឹង ខ្ញុំអត់យល់។ ខ្ញុំយោធាក៏ធ្វើ សែងស្នែងក៏ធ្វើ សែងគ្រាប់ក៏ធ្វើ។ ហ្នឹងពួកខាងនារីយើងខ្ញុំទាំងអស់ហ្នឹង។

**ស៖** បាទ មិនអីទេអ៊ីចឹង។ អ៊ីចឹងតើកងរបស់លោកស្រីហ្នឹងមានឈ្មោះអ្វីទេ? អម្បាញ់មិញនេះលោកស្រីនិយាយអំពីវរសេនាតូចដែលមានគ្នា៣០០នាក់។ អ៊ីចឹង វរសេនាតូចហ្នឹងមានឈ្មោះអ្វីទេ? ហើយលោកស្រីដឹងថា វរសេនាតូចរបស់លោកស្រីហ្នឹង ស្ថិតនៅក្នុងកងវរសេនាធំណា កងពលធំណា លោកស្រីដឹងទេ?

[១៤:២៩:៤៩]

**ឆ៖** កាលពីខ្ញុំចូលដំបូង វរៈខ្ញុំហ្នឹង គឺវរៈ៣០៤ -- ៤០១ វរៈខ្ញុំហ្នឹង។ ប៉ុននៅក្នុងកងវរសេនាធំណា ខ្ញុំអត់ដឹងទេ ដឹងតែវរសេនាតូច ដឹងថា ៤០១។ វរសេនាធំអត់ដឹង ព្រោះកងវរៈ -- កងនារីយើងខ្ញុំមានតែមួយវរៈ មានតែយុទ្ធជន បានមានច្រើន។

**ស៖** លោកស្រីបានឆ្លើយថា ពីឆ្នាំ៧៤ ដល់ ៧៥ លោកស្រីធ្វើការនៅភាគខាងជើងនៃទីក្រុងភ្នំពេញ។ ខ្ញុំចង់ដឹងថា កន្លែងនុំងនៅជិតខដុង្គមែនទេ?

**ឆ៖** ខ្ញុំចាប់ធ្វើការហ្នឹង តាំងពីខដុង្គកំពង់ហ្លួង រហូតចូលដល់ទីក្រុងភ្នំពេញតែម្តង។ ចាប់ពីថ្ងៃ

០១ ខែ០១ មកនៅឧដុង្គកំពង់ហ្លួង រហូតចូលដល់ទីក្រុងភ្នំពេញ ថ្ងៃ១៧មេសាហ្នឹង។

**ស៖** នៅឆ្នាំ៧៤ តើលោកស្រីនឹកឃើញថាមានហេតុការណ៍អ្វីកើតឡើងនៅឧដុង្គទេ? <តើកងទ័ព>ខ្មែរក្រហម<មានបាន>វាយយកឧដុង្គ<ទេ>នៅឆ្នាំ៧៤ហ្នឹង? លោកស្រីមានចាំពីហេតុការណ៍ហ្នឹងទេ?

**ឆ៖** ខ្ញុំអត់ចាំផង ព្រោះខ្ញុំមកចុង -- មកដើមឆ្នាំ៧៥ហើយ ខ្ញុំមិនសូវដឹងដែរ។ ព្រោះមកចុង ៧៤ ជិតដាច់៧៤ មកដល់៧៥ហ្នឹងហើយ បានខ្ញុំមកចូលឧដុង្គកំពង់ហ្លួង មកដល់ទីក្រុងភ្នំពេញ ហែមកតែម្តង។

[១៤:៣១:៤០]

**ស៖** មុនពេលវាយយកទីក្រុងភ្នំពេញបាននៅ<ថ្ងៃទី១៧> ខែមេសា ឆ្នាំ១៩៧៥ ហ្នឹង លោកស្រីធ្លាប់ឃើញមេដឹកនាំធំៗរបស់បក្សកុម្មុយនីស្តកម្ពុជាទេ គឺខ្ញុំសំដៅដល់មេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហម?

**ឆ៖** នៅតាមសមរភូមិ ខ្ញុំអត់ដែលឃើញទេ ឃើញបានតែត្រឹមប្រធានកងពល ប្រធានអនុកងពលអ៊ីចឹងឃើញ ប៉ុន្តែបើថា អ្នកដឹកនាំជាន់ខ្ពស់ធំៗអត់ដែលស្គាល់ អត់ដែលឃើញទេ។ មិនដែលស្គាល់ ហើយមិនដែលឃើញទៀត។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំចូលទៅនិយាយក្រោយពេលរំដោះទីក្រុងភ្នំពេញ។ លោកស្រីបាននិយាយថា លោកស្រីទៅប្រមូលជយភណ្ឌ ហើយនិងរបស់របរមាសប្រាក់អីជាដើម។ អ៊ីចឹង ខ្ញុំចង់ដឹងថា លោកស្រីធ្វើការផ្នែកណានៅក្នុងក្រសួងពាណិជ្ជកម្មហ្នឹង ហើយលោកស្រីដឹងទេថា ពេលនុ៎ងអ្នកណាជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម?

**ឆ៖** កាលពីជំនាន់នោះ ខ្ញុំនៅខាងជ័យ -- ខាងកន្លែងខ្ញុំ គឺខាងជយភណ្ឌ។ ជយភណ្ឌហ្នឹង គឺជញ្ជូនទូទៅ ជញ្ជូនតាំងពីគ្រឿង--

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយ!

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន សូមអរគុណ។ <នេះគឺលើសពីការជំទាស់ទៅទៀត។ ជាការពិត> ខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់<ថា យើងកំពុងតែនិយាយពីបញ្ហាតែមួយ។> ព្រោះថាក្នុងភាសាបារាំងតាមរយៈការបក

ប្រែមក ខ្ញុំអត់បាននិយាយ -- គាត់និយាយអំពីក្រសួងពាណិជ្ជកម្មទេ គ្រាន់តែខ្ញុំឮថា ជាក្រុមពាណិជ្ជកម្ម។ អ៊ីចឹងដូចដែលសាក្សីផ្សេងៗទៀត គាត់និយាយអ៊ីចឹង ភាគីច្រើនគាត់និយាយតែជាអង្គភាព ឬជា <អ៊ី>អ៊ីចឹងទេ។ <ប្រហែលជាមុនពេលដែលយើងសន្និដ្ឋានថា យើងកំពុងតែនិយាយអំពី> ក្រសួងពាណិជ្ជកម្ម<នោះ ប្រហែលជាយើងត្រូវសួរបញ្ជាក់ឲ្យច្បាស់ថា គ្មានការនិយាយសរុបជារួម ឬការភាន់ច្រឡំនោះទេ>។ អ៊ីចឹង ខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់ មិនមែនជាការជំទាស់ទេ លោកប្រធាន។ ការនិយាយហ្នឹង គឺវាសន្និដ្ឋានលឿនពេក។

[១៤:៣៤:០៤]

**សួរដោយលោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្នាឯល៖**

**ស៖** បាទ មិនអីទេ។ អ៊ីចឹង ខ្ញុំសួរលោកស្រីថា តើផ្នែកលោកស្រីដែលប្រមូលជយភណ្ឌហ្នឹង ស្ថិតនៅក្រោមក្រសួងពាណិជ្ជកម្ម ឬក៏នៅក្រោមឃ្លាំងរដ្ឋ ឬក៏អង្គភាពណាផ្សេង?

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមជំទាស់ទៅនឹងរបៀបដែលសហព្រះរាជអាជ្ញាសួរសំណួរនេះ។ សំណួរនេះ ជាសំណួរពហុជ្រើសរើស សូមឲ្យគាត់សួរជាសំណួរបើកទូលាយវិញ កុំឲ្យផ្ដល់ជាជម្រើសស្រាប់ទៅហើយ ហើយគ្រាន់តែឲ្យសាក្សីហ្នឹង គាត់រើសយកមួយណា។ អ៊ីចឹងមិនត្រឹមត្រូវទេ ការធ្វើបែបនេះនោះ។

**លោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្នាឯល៖**

បាទ លោកប្រធាន គឺអម្បាញ់មិញហ្នឹង គឺដើមបណ្ដឹងរដ្ឋប្បវេណីខ្លួនឯងទេ ដែលគាត់និយាយថា ក្រុមរបស់គាត់ហ្នឹង អង្គភាពរបស់គាត់បញ្ចូលទៅខាង<កង>ពាណិជ្ជកម្ម អ៊ីចឹងបានជាខ្ញុំសួរគាត់នោះ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្នាឯល៖**

**ស៖** លោកស្រីៗ អាចបញ្ជាក់បានទេ <នេះគឺអ្វីដែល>ខ្ញុំ<បាន>ស្ដាប់ឮមុន<ហ្នឹង។ តើ> លោកស្រី<អាចបញ្ជាក់ចំណុចនេះបានទេ ឬក៏តើលោកស្រីអាចប្រាប់យើងបានទេ តើកងជយភណ្ឌរបស់លោកស្រី>ហ្នឹង គឺស្ថិតនៅ<ក្រោមមេដឹកនាំជាន់ខ្ពស់>ណាដែរ?

**លោកស្រី ជា ឌៀប៖**

**ឆ៖** ខ្ញុំបានជម្រាបហើយតើ ថាខ្ញុំដែល ក្រុមគ្នាខ្ញុំមានជាង៣០០នាក់ បានគេដកមួយកងធំទៅខាងយោធា មួយកងធំទៅខាងកំពង់សោម មួយកងធំខ្ញុំនៅខាងពាណិជ្ជកម្ម។ ខ្ញុំបាននិយាយអ៊ីចឹងតើ។

---

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហើយខ្ញុំនៅហ្នឹង ក្នុងពាណិជ្ជកម្មហ្នឹង ការដឹកនាំដោយប្រធានពាណិជ្ជកម្មហ្នឹង គឺឈ្មោះ អ៊ំធុច។ អ៊ំធុច គាត់នៅម្តុំ -- ផ្ទះគាត់អង្កាល់ទ៉ុង គាត់នៅហ្នឹងនេះនឹងដែរ។ គាត់នៅកន្លែងដាក់ ដែលកន្លែងប្រាក់ហ្នឹង កន្លែងរោងចក្រជីបតុង ស្បែកជើងជីបតុងហ្នឹង គាត់នៅនឹងផ្ទះហ្នឹងតែម្តង។ ហើយខ្ញុំជញ្ជូនប្រាក់ជញ្ជូន មកហ្នឹង ខ្ញុំយកដាក់ខាងកើតផ្ទះគាត់ហ្នឹង។ ហ្នឹងខ្ញុំជម្រាបអ៊ីចឹងហើយតើ ថាខ្ញុំនៅក្រសួងពាណិជ្ជកម្ម។ អ៊ំធុចៗ ហ្នឹងហៅ កុយ ឃួន – អ៊ំ ធុច ហៅ កុយ ឃួន។ គេមានហៅពីរឈ្មោះគាត់នោះ។

[១៤:៣៦:១៧]

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមការបញ្ជាក់តូចមួយពាក់ព័ន្ធនឹងការរៀបការរបស់លោកស្រី។ ពេលដែលលោកស្រីរៀបការហ្នឹង លោកស្រីនៅខាងផ្នែកជយភណ្ឌ នៅក្រសួងពាណិជ្ជកម្មដដែល ឬក៏ គេបញ្ជូនលោកស្រីទៅអង្គភាពកាត់ដេរនៅអូរឫស្សីហើយ?

**ឆ៖** ពេលដែលខ្ញុំរៀបការ គឺនៅអង្គភាព នៅខាងពាណិជ្ជកម្មដដែល។ នៅក្រសួងពាណិជ្ជកម្ម ដដែលហ្នឹង ដល់ខ្ញុំរៀបការរួច បានគេបញ្ជូនទៅនៅខាងផ្សារអូរឫស្សី។

**ស៖** អង្គភាពកាត់ដេរនៅផ្សារអូរឫស្សីហ្នឹងស្ថិតនៅក្រោមក្រសួងពាណិជ្ជកម្ម ឬក៏នៅក្រោម ក្រសួង ឬក៏ថ្នាក់ណា?

**ឆ៖** កន្លែងកាត់ដេរហ្នឹងក្នុងក្រសួងពាណិជ្ជកម្មជាមួយពួកជយភណ្ឌហ្នឹងដែរ ព្រោះប្រធានមាន តែមួយ ឈ្មោះ អ៊ំគុណៗ ហ្នឹងគាត់នៅនឹងផ្សារអូរឫស្សីហ្នឹង គាត់គ្រប់គ្រងទាំងកន្លែងពាណិជ្ជកម្ម -- ទាំង កន្លែងជយភណ្ឌ ទាំងកន្លែងកាត់ដេរ។

**ស៖** លោកស្រីដឹងថា មានរឿងអ្វីកើតឡើងចំពោះ អ៊ំឃួន ដែលជាអ្នកដឹកនាំ -- អ៎! អ៊ំគុណ សូមទោស ដែលជាអ្នកដឹកនាំអង្គភាព<ទាំងពីរនេះនៅសម័យ>ហ្នឹងទេ?

**ឆ៖** ខ្ញុំអត់ដែលដឹងដែរ រឿងគាត់ មិនដែលដឹងយ៉ាងម៉េចៗ អត់ដែលដឹងទេ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកព្រះរាជអាជ្ញា។ ឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០ នាទី ចាប់ពីពេលនេះតទៅ។

សូមអញ្ជើញសម្រាក!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

01364568



*(សវនាការសម្រាកពីម៉ោង ១៤:៣៨នាទី ដល់ម៉ោង ១៤:៥៧ នាទី)*

[១៤:៥៧:៤៩]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញអង្គុយ!

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញាបន្តសំណួរ។

**សួរដោយលោក វាំងសង់ វ៉ាយដ៏ ដេស្មាងល៖**

**ស៖** សូមអរគុណលោកប្រធាន។ លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី តើលោកស្រីធ្លាប់ឮគេនិយាយអំពីមន្ទីរស-៧១ ទេ? លោកស្រីធ្លាប់ឮឈ្មោះមន្ទីរហ្នឹងទេ មន្ទីរស-៧១?

**លោកស្រី ជា ឡៀប៖**

**ឆ៖** ខ្លួនខ្ញុំផ្ទាល់មិនដែលឮ មិនដែលដឹងផង។ នៅភ្នំពេញមែន ប៉ុនអត់ដែលដឹងមានស-៧១។ តែ ស-២១ ក៏មិនដែលដឹងដែរ។

**ស៖** មុននេះលោកស្រីបាននិយាយថា លោកស្រីបានជួបលោក ខៀវ សំផន នៅភ្នំពេញ គឺជួបពីរដង។ ទី១ នៅវត្តឧណ្ណាលោម ហើយទី២ គឺនៅស្តាតអូឡាំពិក។ ឥឡូវនេះខ្ញុំសួរពេលដែលលោកស្រីឃើញ លោក ខៀវ សំផន លើកទី២ នៅស្តាតអូឡាំពិក លោកស្រីអាចបញ្ជាក់បានទេថា លោកស្រីជួបហ្នឹងជួបនៅពេលណា ហើយក្នុងឱកាសពិធីអីដែរ? ខ្ញុំអម្បាញ់មិញនេះប្រហែលជាស្តាប់លោកស្រីមិនទាន់ អ៊ីចឹងសូមលោកស្រីរៀបរាប់ឲ្យបានច្បាស់បន្តិចអំពីការដែលលោកស្រីឃើញលោក ខៀវ សំផន លើកទី២ នៅពេលហ្នឹងគឺជួបនៅពេលណា ហើយពេលហ្នឹងគាត់បាននិយាយអ្វីខ្លះ?

**ឆ៖** ខ្ញុំសូមជម្រាបថា លោក ខៀវ សំផន ខ្ញុំលើកទី១ ខ្ញុំជួបនៅវត្តឧណ្ណាលោម គឺបើកសន្និបាតនារី និងយុទ្ធជន នៅឧណ្ណាលោម។ ដល់ជួបលើកទី២ ខ្ញុំជួបនៅស្តាតបុរីកីឡា មិនមែនស្តាតអូឡាំពិកទេ។ ស្តាតបុរីកីឡាហ្នឹងកាត់ទោស ហ៊ូ នឹម, ហ៊ូ យន់។ ពីរដងហ្នឹង ខ្ញុំជួបគាត់។

[១៥:០០:២៣]

**ស៖** នៅបុរីកីឡាហ្នឹង មានអ្នកណាខ្លះនៅទីនុ៎ង? <តើមានមនុស្សច្រើនទេនៅទីនោះ> សុទ្ធតែជាសមាជិកកងរបស់លោកស្រី ពិតមែនទេ? ហើយពេលនុ៎ងគឺនៅឆ្នាំណាដែរ?

**ឆ៖** ក្នុងឆ្នាំ១៩៧៥ហ្នឹង ប៉ុនមិនដឹងខែប៉ុន្មានថ្ងៃប៉ុន្មានទេ ខ្ញុំអត់ដឹងខែដឹងថ្ងៃអីទេ។ គ្រាន់តែដឹង

ថាខ្ញុំចូលទៅប្រជុំហ្នឹង គឺស្ពាតបុរីកីឡាហ្នឹងគឺ ឃើញអ៊ំ ខៀវ សំផន គាត់ជាទីប្រឹក្សា ហើយឃើញមានច្រើនទៀត ប៉ុនខ្ញុំមិនស្គាល់ មិនដឹងខាងណាខាងណីទេ។ ហើយមិនមែនអង្គភាពខ្ញុំទាំងអស់ទេ គឺតាមគ្រប់អង្គភាពមកហ្នឹង។ ទាំងខាងយោធា តាំងពីភូមិភាគបស្ចិម ភូមិភាគឧត្តរអីមកទាំងអស់ មកជុំគ្នានៅកន្លែងហ្នឹង ប៉ុនមិនមកច្រើនទេ មកមួយកន្លែងពីរបីនាក់ៗទេ មកជុំនៅស្ពាតបុរីកីឡាថ្ងៃកាត់ទោស ហ៊ូ នឹម, ហ៊ូ យន់។ ហ្នឹងខ្ញុំដឹងប៉ុណ្ណឹង។ ទទួលដល់ខ្ញុំគ្រុនទៅ គេយកខ្ញុំទៅដេកពេទ្យទៅ មិនដឹងទៅអីទៀត ខ្ញុំអត់ដឹង។

**ស៖** បាទ ឥឡូវខ្ញុំត្រឡប់មកនិយាយអំពីការជួបលើកទី១។ អ៊ីចឹងខ្ញុំចង់ដឹងថា ពេលដែលលោកស្រីជួបគាត់នៅឆ្នាំ៧៥ នៅវត្តឧណ្ណាលោមហ្នឹង គឺពេលហ្នឹង គឺកើតមុនពេលដែលលោកស្រីជួបគាត់នៅបុរីកីឡាមែនទេ?

**ឆ៖** ចាស ខ្ញុំជួបគាត់នៅវត្តឧណ្ណាលោម ជួបមុន។ បុរីកីឡាជួបក្រោយទេ។

[១៥:០២:១៥]

**ស៖** បាទ លោកប្រធាន ខ្ញុំអត់បានទទួលការបកប្រែជាភាសាបារាំងនូវចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ សុំលោកស្រីឆ្លើយម្ដងទៀត។ ខ្ញុំអត់ទទួលបានការបកប្រែទេ។

**ប្រធានអង្គជំនុំ៖**

សុំដើមបណ្ដឹងរដ្ឋប្បវេណីឆ្លើយម្ដងទៀត ព្រោះខាងព្រះរាជអាជ្ញា ភាសាបារាំងមិនបានបកប្រែឱ្យគាត់ទេ។ សូមខាងបកប្រែ។

**លោកស្រី ជា ឌៀប៖**

**ឆ៖** ខ្ញុំជួបគាត់ -- អំមិញខ្ញុំនិយាយច្រឡំតិចហើយថា ជួបគាត់នៅលើកទី១ ជួបនៅស្ពាតបុរីកីឡា ជួបលើកទី១ ព្រោះកាលហ្នឹងខាងឆ្នាំ៧៥ ប៉ុនមិនដឹងខែប៉ុន្មានទេ លើកទី១ ព្រោះអំមិញខ្ញុំនិយាយច្រឡំតិចហើយ។ ហើយដល់លើកទី២ ខ្ញុំជួបនៅវត្តឧណ្ណាលោម។ អាហ្នឹងគាត់បើកសន្និបាតហ្នួងសន្និបាតនារីយុទ្ធជនពេញមួយសាលាហ្នឹងហ្នួង រយៈមួយថ្ងៃហ្នឹង។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោក ខៀវ សំផន នៅវត្តឧណ្ណាលោមហ្នឹង ពេញមួយថ្ងៃតែម្ដងមែនទេ?

**ឆ៖** ចាស គាត់បង្រៀនពេញមួយថ្ងៃហ្នួង។

**ស៖** មុននេះ លោកស្រីបាននិយាយថា គាត់ប្រាប់ថា កម្មាភិបាលនារីត្រូវធ្វើការជូនរដ្ឋ ហើយ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អ្នកដែលមានអាយុចាប់ពី១៩ឆ្នាំហ្នឹងត្រូវតែរៀបការ។ <តើខ្ញុំយល់ពាក្យដែលលោកស្រីនិយាយហ្នឹងត្រឹមត្រូវទេ?> តើពាក្យពេចន៍ទាំងអស់ហ្នឹង គាត់សុទ្ធតែជាពាក្យដែលលោក ខៀវ សំផន បាននិយាយនៅពេលនុ៎ងមែនទេ?

**ឆ៖** ចាស ខ្ញុំជម្រាបថា ពេលនោះគាត់បាននិយាយមែន ប៉ុនគាត់និយាយហ្នឹងគាត់ថាពី១៩ឆ្នាំទៅ២៥ យុទ្ធជន៣០អីរៀបឲ្យអស់ទៅ កុំទុកទៀត ទុកតែក្មេងបានហើយ។ គាត់និយាយអ៊ីចឹងមែន។

**ស៖** បើខ្ញុំមិនច្រឡំទេ មុននេះលោកស្រីក៏បានឆ្លើយផងដែរថា លោក ខៀវ សំផន និយាយថា អ្នកដែល -- "ស្ត្រីដែលមានអាយុចាប់ពី១៩ឆ្នាំហ្នឹង ត្រូវតែរៀបការដើម្បីបង្កើតកូន ដើម្បីមានកម្លាំងការពារទឹកដី"។ តើពេលសន្និបាតនៅវត្តខណ្ឌលោមហ្នឹង គាត់ពិតជាបាននិយាយពាក្យបែបហ្នឹងមែនទេ?

**ឆ៖** ចាស ខ្ញុំស្តាប់មិនច្រឡំទេ គឺគាត់និយាយអ៊ីចឹងមែន។ "ពី១៩ ដល់២៥, ៣០, ៣៥អីរៀបអស់ទៅ ទុកតែក្មេងៗបានហើយ" គាត់ប្រាប់អ៊ីចឹងមែន។

[១៥:០៦:០៣]

**ស៖** តើបើតាមសម្តីរបស់លោក ខៀវ សំផន ហ្នឹង ការដែលគេឲ្យរៀបការហ្នឹង គោលដៅសំខាន់ហ្នឹង គេចង់ឲ្យបង្កើតកូនមែនទេ?

**ឆ៖** ខ្ញុំក៏មិនបានដឹងដែរ ប៉ុន្តែថាគាត់បាននិយាយអ៊ីចឹងទៅ ហើយក៏និយាយទៅមិនថាត្រឹមតែគាត់មួយទេ ប្រជុំរៀនសូត្រកន្លែងណា ក៏លើកតែអ៊ីចឹងដែរ មិនថាតែគាត់មួយទេ គឺអ៊ីចឹងតែម្តង។ កម្មាភិបាលណាក៏លើកតែអ៊ីចឹង ឲ្យតែពេលប្រជុំ ពេលរៀនសូត្រ។

**ស៖** ក្នុងពេលសន្និបាតនោះ តើលោក ខៀវ សំផន មានបាននិយាយអ្វីផ្សេងក្រៅពីរឿងរៀបការទេ? ឧទាហរណ៍ដូចជាគាត់និយាយអំពីការសំខាន់ដែលត្រូវបំពេញការងារឲ្យបានល្អ ត្រូវតែគោរពអង្គការវិន័យ។ តើគាត់មានបាននិយាយអំពីរឿងបែបហ្នឹងទេ?

**ឆ៖** លោក ខៀវ សំផន គាត់បាននិយាយដែរ មុននឹងគាត់និយាយរឿងរៀបការហ្នឹង ក៏គាត់ដឹកនាំយុទ្ធជននារីឲ្យខិតខំធ្វើការងារជូនរដ្ឋ ជូនបក្សអ៊ីចឹងទៅ កុំឲ្យមាន ដូចថាកុំឲ្យមានឆ្វេងស្តាំអី ឆ្វេងអីខុសពីវិន័យអ៊ីចឹងទៅ គាត់និយាយហូរហែអ៊ីចឹងមែនហ្នឹង។ គាត់និយាយពីគោលនយោបាយរបស់អង្គការអ៊ីចឹងទៅ។ គាត់គ្មាននិយាយពីអីទៀតទេ គាត់និយាយច្រើនតែពាក្យអ៊ីចឹង។

[១៥:០៨:០០]

**ស៖** តើវិន័យបក្សមានលក្ខណៈតឹងរ៉ឹងទេ ហើយគេបានប្រាប់លោកស្រីយ៉ាងម៉េចខ្លះពាក់ព័ន្ធនឹងរឿងវិន័យនេះ? <តើវិន័យនោះមានអ្វីខ្លះ?>

**ឆ៖** វិន័យជំនាន់ៗខ្មែរក្រហម គឺតឹងរ៉ឹងមែនទែនហ្នឹង ហាម សូម្បីតែសីលធម៌ក៏មិនឲ្យមានដែរនៅក្នុងជួរបក្សទាំងអស់ហ្នឹង។ គឺការពារបានទាំងអស់ ទោះបីមានក៏មានតិចតួច ក៏គេទប់ទល់បានដែរ អត់មានអីឲ្យលើសទេក្នុងជំនាន់ខ្មែរក្រហមហ្នឹង។

**ស៖** ខុសសីលធម៌ហ្នឹង លោកស្រីចង់និយាយថាគេហាមមិនឲ្យរួមភេទគ្នា ឧទាហរណ៍បើស្ត្រីអ៊ីចឹង គេហាមមិនឲ្យរួមភេទជាមួយបុរស អ៊ីចឹងមែនទេ?

**ប្រធានអង្គជំនុំ៖**

លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី សូមកុំអាលទាន់ឆ្លើយ!

សូមអញ្ជើញលោកស្រីមេធាវីការពារលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ដដែលលោកប្រធាន ព្រោះថាសហព្រះរាជអាជ្ញាគាត់តែងតែស្នើនូវចម្លើយរួចទៅហើយនៅក្នុងសំណួររបស់គាត់នោះ។ ខ្ញុំមិនជំទាស់ទេ បើសិនជាសំណួររបស់គាត់មានលក្ខណៈទូលំទូលាយនោះ ក៏ប៉ុន្តែបើគាត់ដាក់ចម្លើយនៅក្នុងសំណួររបស់គាត់ទៅហើយ ខ្ញុំសូមជំទាស់ទៅនឹងការសួរសំណួររបៀបនេះ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ខ្ញុំគិតថាភាគីទាំងអស់បានដឹងច្បាស់ហើយអំពីពាក្យថា "ខុសសីលធម៌"ហ្នឹង អ៊ីចឹងឥឡូវខ្ញុំរៀបចំសំណួរឡើងវិញ។

[១៥:១០:០៣]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកស្រី ពេលដែលលោកស្រីនិយាយពីរឿងខុសសីលធម៌នេះ តើលោកស្រីចង់សំដៅទៅលើរឿងអ្វីដែរ?

**លោកស្រី ជា ឌៀប៖**

**ឆ៖** ខ្ញុំចង់និយាយពីរឿងសីលធម៌នៅក្នុងជួរខ្មែរក្រហមហ្នឹង បើសិនជាតាមមុខព្រួញទូទៅក្នុងជួរកងទ័ពក៏ដោយ ជួរពាណិជ្ជកម្មក៏ដោយ ផ្នែកយុទ្ធជន ហើយនារីអត់មានឲ្យហៅមិត្តបង ហៅមិត្ត

ទទេអត់បានទេ។ នារីហៅយុទ្ធជនពូទាំងអស់ យុទ្ធជនហៅមិត្តនារីបាន។ បើថាចំណែកពូៗ អំ! ចំណែកនារីវិញ ហៅយុទ្ធជន ហៅពូទាំងអស់ក្នុងជួរកងទ័ពក៏ដោយ ជួរពាណិជ្ជកម្មក៏ដោយ។ ដល់ពេលអ៊ីចឹងទៅ ដល់ពេលរឿងសីលធម៌ខ្ញុំនិយាយចង់និយាយថា សីលធម៌មានខ្លះស្រឡាញ់គ្នា ប៉ុន្តែមិនទាន់ឲ្យជ្រុលជ្រួសទេ។ តែស្រឡាញ់គ្នា គេដឹងគេបំបែក មួយទៅដាក់អីណាផ្សេងទៅៗ ប៉ុន្តែបើគេតាមដានទៅ មើលថាសភាពអ្នកទាំងពីរហ្នឹងអត់ជ្រើមជ្រួលទេ គេយកមករៀបឲ្យវិញ ប៉ុន្តែរៀបវិញ រៀបតែពេលយប់។ មួយគូក៏គេរៀបដែរ តែពេលយប់ទេ។ ហ្នឹងអ្នកខុសសីលធម៌។

[១៥:១១:៣៤]

**ស៖** តើលោក ខៀវ សំផន មានបាននិយាយអំពីរឿងខ្មាំងទេ ជាពិសេសនោះ ពេលក្នុងសន្និបាតនៅវត្តឧណ្ណាលោមនោះ គាត់មានបាននិយាយថា តើអ្នកណាខ្លះជាខ្មាំងបដិវត្តន៍ទេ?

**ផ៖** គាត់អត់មាននិយាយផង ខ្ញុំអត់ឮដែលផង។

**ស៖** តើលោកស្រីធ្លាប់ឮថា គេចង់បង្កើនប្រជាជនពី១៥ ទៅ២០លាន ឲ្យបានឆាប់រហ័ស?

**ផ៖** ខ្ញុំអត់ដឹងដែរ ខ្ញុំមិនដែលឮដែរអ៊ីចឹង។ ខ្ញុំមិនដែលបានឮ អត់ដឹងទេ។

**ស៖** ក្នុងពេលសន្និបាតនៅវត្តឧណ្ណាលោម តើលោក ខៀវ សំផន មានបានបញ្ជាក់មូលហេតុទេថា ហេតុអ្វីបានជាឲ្យស្ត្រីអាយុពី១៨ឆ្នាំឡើងហ្នឹង ត្រូវរៀបការនោះ? កាលដែលរៀបការនៅអាយុ១៨ឆ្នាំហ្នឹង លោកស្រីគិតថាវាក្មេងពេកទេ?

**ផ៖** ចំពោះរៀបការអាយុ១៨ឆ្នាំ បើចំពោះខ្ញុំផ្ទាល់ថានៅក្មេងពេក ប៉ុន្តែបើសិនជាគេផ្សេងម៉េចមិនដឹង ខ្ញុំមិនដឹងដែរ។ ខ្ញុំដឹងខ្លួនខ្ញុំផ្ទាល់ថា ខ្ញុំនៅក្មេង អាយុ១៨ឆ្នាំ។

[១៥:១៣:៣៩]

**ស៖** ក្រៅពីនិយាយថា ស្ត្រីអាយុពី១៨ឆ្នាំឡើងត្រូវរៀបការ ដើម្បីបង្កើតកូន ដើម្បីបង្កើនប្រជាជនឲ្យមានកម្លាំងការពារទឹកដីនោះ តើលោក ខៀវ សំផន មានបាននិយាយអំពីគ្រួសារបដិវត្តន៍ទេ គាត់បាននិយាយអ្វីពាក់ព័ន្ធនឹងរឿងគ្រួសារទេ របៀបវាមានលក្ខណៈខុសពីមុនយ៉ាងម៉េចខ្លះ?

**ផ៖** គាត់មានបាននិយាយផង ខ្ញុំអត់មានបានឮផង គ្រួសារបដិវត្តន៍ហ្នឹងមិនដឹងម៉េចផង ខ្ញុំអត់យល់ដែរ។

**ស៖** ខ្ញុំចង់ដឹងថា នៅក្រោមរបបខ្មែរក្រហមលោកស្រីធ្លាប់ឮកម្មាភិបាលនិយាយថា ទំនាក់ទំនងគ្រួសារនោះ ដូចជា ឪពុកម្តាយ និងកូន បងនិងប្អូន ហ្នឹង គឺថាវាមិនមានលក្ខណៈដូចពីអ្វីដែលធ្លាប់

មានកាលពីមុនរបបខ្មែរក្រហមទេ។ លោកស្រីដែលមានពួកម្នាភិបាលណា គេនិយាយរឿងហ្នឹងទេ?

**ឆ៖** ខ្ញុំដូចមិនយល់ដែរ ដូចឆ្លើយរឿងរបបខ្មែរក្រហម។ ផ្ដាច់ ចង់សួរថាផ្ដាច់អី ផ្ដាច់ការទាក់ទងអី?

**ស៖** បាទ គឺអ៊ីចឹងហើយ ក្នុងរបបខ្មែរក្រហមនុ៎ង តើចាំបាច់ទេ ដែលថាកូនៗហ្នឹងត្រូវតែផ្ដាច់ទំនាក់ទំនងពីឪពុកម្ដាយរបស់ខ្លួននោះ?

**ឆ៖** មែន បើកន្លែងហ្នឹងមាននិយាយមែន បើថាអ្នកដឹកនាំប្រជុំអី ច្រើនថា កុំអាល័យតែគិតម៉ែឪ នឹកម៉ែឪ គិតតែខំប្រឹងធ្វើការជូនបក្ស ជូនរដ្ឋទៅ រឿងម៉ែឪទុកមួយឡែក។ ហ្នឹងនិយាយមែន អ្នកៗដឹកនាំថ្នាក់លើៗបន្តៗទៅហ្នឹង បើខាងលើបង្អស់ ខ្ញុំមិនដឹង មិនសូវបានជួបគាត់ដែរ។

[១៥:១៦:២០]

**ស៖** តើការមានមនោសញ្ចេតនាជាមួយឪពុកម្ដាយ ឬក៏ជាមួយសមាជិកគ្រួសារហ្នឹងវាមានលក្ខណ:ផ្ទុយទៅនឹងសមូហភាពទេ? ឬក៏មួយទៀតនោះ ខ្ញុំចង់សួរពីរឿងកម្មសិទ្ធិឯកជននោះ តើគេមានប្រាប់ថាត្រូវតែកាត់ផ្ដាច់ពីរឿងកម្មសិទ្ធិឯកជនទេ?

**ឆ៖** ចាស រឿងឪពុកម្ដាយ គឺកាត់ផ្ដាច់ឪពុកម្ដាយបងប្អូន មិនដែលឲ្យជួបគ្នាទេ។ រួចបើកម្ម-សិទ្ធិ បើថាអង្គការប្រជុំហើយ មានតែកម្មសិទ្ធិតូចមួយហ្នឹង អត់មានអីសំពីងសំពោងមានអីច្រើនទេ ទៅណាមានតែវ៉ាឡូមួយហ្នឹងហើយ។ សំពីងសំពោងច្រើន ផែកឥឡូវហ្នឹង។ តែចេញពីកន្លែងមួយទៅកន្លែងមួយ ផែកដកអស់ឥឡូវហ្នឹង មានអីលើសដកតែម្ដង។ ហ្នឹងនៅតាមកន្លែងខ្ញុំផ្ទាល់តែម្ដង។

**ស៖** <តើនៅក្នុងរបស់នោះ>គេធ្លាប់ប្រាប់លោកស្រីទេ ថាលោកស្រីមិនមែនជាកូនឪពុកម្ដាយទៀតទេ គឺជាកូនរបស់អង្គការ?

**ឆ៖** ដូចខ្ញុំបានលើកនិយាយហើយតើ ពេលរៀបគ្រួសារ មិនអង្គការនិយាយអ៊ីចឹង។ និយាយថាមិត្តនៅជាមួយអង្គការ គឺគ្រប់គ្រងអង្គការ -- ក្រោមការគ្រប់គ្រងរបស់អង្គការ មិនមែនទៅចាំម៉ែឪអាល័យតែទៅរកម៉ែរកឪទៀតទេ គឺអង្គការជាម៉ែឪហើយ។ ពេលរៀបការគេនិយាយអ៊ីចឹង។ ហើយដល់ពេលក្រោយៗមកក៏និយាយអ៊ីចឹងដែរ តែពេលប្រជុំ ពេលរៀនសូត្រអី និយាយតែអ៊ីចឹង ថារស់នៅក្រោមគ្រប់គ្រងរបស់អង្គការ គឺអង្គការជាម៉ែឪ។

[១៥:១៨:២៥]

**ស៖** ដូច្នេះមានន័យថា រាល់ការសម្រេចរបស់អង្គការទាំងអស់ លោកស្រីត្រូវតែគោរពតាម

មែនទេ?

**ឆ៖** ចាសគ្រប់ការងារទាំងអស់ គោរពតាមអង្គការទាំងអស់ហ្នឹង បើកុំតែគោរពតាមអង្គការ មិនបានរស់នៅទល់ឥឡូវទេ ហ្នឹងនិយាយឲ្យចំអ៊ីចឹងតែម្តងទៅ។

**ស៖** ពាក់ព័ន្ធនឹងការរៀបការ ជាពិសេសការរៀបការរបស់លោកស្រីនោះ ខ្ញុំចង់អានឯកសារផ្លូវការមួយរបស់កម្ពុជាប្រជាធិបតេយ្យ ហើយនិងពិនិត្យមើលជាមួយលោកស្រី ថាតើខ្លឹមសារនៅក្នុងឯកសារហ្នឹង វាត្រូវគ្នានឹងអ្វីដែលលោកស្រីបានឆ្លងកាត់ដែរឬក៏អត់ គឺឯកសារ E3/775 គឺជាឯកសារដែលបានបោះពុម្ព<ឡើងវិញ>នៅខែមិថុនា ឆ្នាំ៧៥។ គឺជាអត្ថបទរបស់ទស្សនាវដ្តីទង់បដិវត្តនៅ<ខែកុម្ភៈ>ឆ្នាំ៧៤ ឯកសារនេះមានចំណងជើងថា “បញ្ហាបដិវត្ត និង មិនបដិវត្តនៃការកសាងគ្រួសារ”។ ជាភាសាខ្មែរនោះគឺ 00407100 ទៅដល់ 01, ជាភាសាអង់គ្លេស 00417943, ជាភាសាបារាំង 00593930។ នៅក្នុងសម្រង់នេះគេនិយាយថា តើយុវជន យុវនារីបដិវត្តហ្នឹងត្រូវរើសគ្រួសារបែបណា។ នៅចំណុចទី២ហ្នឹងគេបានសរសេរដូចតទៅ ខ្ញុំដកស្រង់៖ “ត្រូវគោរពអង្គការវិន័យដាច់ខាត។ ក្នុងបញ្ហាកសាងគ្រួសារនេះ បើអង្គការសមូហភាព ពិនិត្យឃើញយ៉ាងណា សម្រេចយ៉ាងណា ត្រូវគោរពតាមដាច់ខាត។ កុំទោមនស្ស កុំថ្នាំងថ្នាក់ ព្រោះមានតែអង្គការ មានតែសមូហភាពទេដែលអាចពិនិត្យមើលបានម៉ត់ចត់ និងគ្រប់ជ្រុងជ្រោយបាន។” សូមបញ្ចប់ការដកស្រង់។ លោកស្រីនៅក្នុងឯកសារនេះគេនិយាយថា ត្រូវតែគោរព អង្គការ និងសមូហភាព ពាក់ព័ន្ធនឹងការជ្រើសរើសប្តីឬក៏ប្រពន្ធ។ តើលោកស្រីធ្លាប់ឮចំណុចហ្នឹងគេដែល -- លោកស្រីធ្លាប់ឮគេនិយាយអំពីចំណុចហ្នឹងដែរទេ?

**ឆ៖** ចំណុចនេះអង្គការដូចដែលថាក្នុងឯកសារហ្នឹងក៏ដូចគ្នានឹងការពិតដែរ។ ចំពោះខ្ញុំផ្ទាល់ក៏ឮដែរ។ ឮមានតែគោរពអង្គការ គោរពវិន័យ និងសមូហភាពហ្នឹង។ តែសមូហភាពថាម៉េចទៅអ៊ីចឹងហើយ អត់មានកែប្រែបានទេ តែប៉ុណ្ណឹង។

[១៥:២២:០១]

**ស៖** មុននេះលោកស្រីធ្លាប់ លោកស្រីបាននិយាយថាបានប្រកែកមិនព្រមរៀបការពីរដង ប៉ុន្តែលើកទី៣ហ្នឹង គេបញ្ជាឲ្យលោកស្រីទៅផ្សារអូរឫស្សី។ អ៊ីចឹងខ្ញុំចង់ដឹងថា ពីលើកទី១ ដែលលោកប្រកែក ដែលលោកស្រីប្រកែកទៅដល់លើកទី៣ ដែលលោកស្រីយល់ព្រមហ្នឹង មានរយៈពេលប្រហែលប៉ុន្មានដែរ?

**ឆ៖** កាលពីលើកទី១ ដែលខ្ញុំប្រកែកបាន គឺប្រកែកនៅមុខព្រួញ ប្រធានមុខព្រួញផ្ទាល់។

ហើយរយៈបីថ្ងៃទៀតបានគាត់សួរខ្ញុំទៀត បីបួនថ្ងៃគាត់សួរខ្ញុំទៀត នៅមុខព្រួញខ្ញុំដដែល។ ដល់ក្រោយមកបានប្រហែលជាមួយថ្ងៃ ពីរថ្ងៃ គាត់ថាគាត់លែងសួរហើយ ហើយទៅមន្ទីរទៅ ទៅជួបអ៊ំនៅមន្ទីរ។ ខ្ញុំក៏មកមន្ទីរមក។ មកមន្ទីរក៏ខ្ញុំមិនមែនជួបអ៊ំមេប្រធានហ្នឹងទេ ខ្ញុំជួបអនុហើយសមាជិកគាត់។ ហើយគាត់ក៏និយាយដូចតែគ្នាដដែលៗ ដល់និយាយដដែលខ្ញុំថាទៅ ខ្ញុំថាបើខ្ញុំប្រកែកមិនបានហើយធ្វើម៉េចក៏ធ្វើទៅ ខ្វាក់ក៏យកខ្វិនក៏យក កំបុតក៏យកដែរ។ ខ្ញុំក៏ថាអ៊ីចឹងខ្ញុំដើរចេញវិញមក។ ខ្ញុំនិយាយរាងសោះកក្រោះខ្ញុំដើរចេញខ្ញុំអត់តអីទៀត។ គាត់ ក៏គាត់មិនថាអីឲ្យខ្ញុំដែរ។

**ស៖** លោកស្រីថា លោកស្រីទៅផ្សារអូរឫស្សី ហើយលោកស្រីមិនបានឃើញពូទេ។ អ៊ីចឹងមានន័យថាពេលដែលលោកស្រីទៅទីនុំង គឺលោកស្រីត្រូវតែជួប ពូគុណ ហ្នឹងមែនទេដែលជាមេប្រធានអង្គភាពកាត់ដេរផង ហើយជាប្រធានអង្គភាពជយភណ្ឌផង?

[១៥:២៤:០៤]

**ឆ៖** ខ្ញុំទៅនឹងគេប្រាប់ខ្ញុំថាឲ្យទៅជួប អ៊ំគុណ ហ្នឹង។ ប៉ុនដល់ខ្ញុំទៅអត់ជួប អ៊ំគុណ គឺជួបតែអ៊ំម៉ុញ ហើយនិង អ៊ំឈុំ ជួបពីរនាក់ហ្នឹង។ គាត់ពីរនាក់ហ្នឹង គាត់មិនមែនសម្លាសតែខ្ញុំមួយទេ គាត់មិននិយាយតែខ្ញុំមួយទេ មានគូផ្សេងៗទៀតក៏ទៅហ្នឹងពីរបីគូដែរ។ ហើយគាត់សួរខ្ញុំមុន សួររួចខ្ញុំឆ្លើយគាត់ទៅ ខ្ញុំក៏ដើរចេញមក ខ្ញុំមិនបានស្តាប់គេទៀតទេ។ ហើយក៏ជួបតែគាត់ពីរនាក់ហ្នឹង អ៊ំគុណ អត់នៅ មិនដឹងគាត់ទៅណាផង។ ជួបតែអ៊ំៗពីរនាក់បន្ទាប់ៗគាត់ហ្នឹង។

**ស៖** ពេលដែល ម៉ុញ និង ឈុំ ហ្នឹងនិយាយជាមួយលោកស្រីហ្នឹង គឺលោកស្រីដឹងប្រាកដច្បាស់ថាពេលហ្នឹង គឺលោកស្រីគ្មានជម្រើសអ្វីទៀតនៅក្នុងការប្រកែកមិនព្រមរៀបការទេ មែនទេ?

**ឆ៖** ចាស ខ្ញុំឆ្លើយថាខ្ញុំអស់ជម្រើសហើយ។ បើខ្ញុំប្រកែកពីរដងបីដងហើយ ដល់ថ្នាក់ទី៣ទៀតខ្ញុំថា ខ្ញុំលែងប្រកែកហើយ។

**ស៖** លោកស្រីខ្លាចអី បើលោកស្រីប្រកែកជាថ្មីម្តងទៀតនោះ? អ៊ំទាំងពីរហ្នឹង បានពន្យល់ប្រាប់លោកស្រីថា បើលោកស្រីប្រកែកទៀត នឹងមានរឿងហេតុអីកើតឡើងចំពោះលោកស្រី អ៊ីចឹងមែនទេ?

[១៥:២៥:៤៨]

**ឆ៖** ទេទៅដល់ហ្នឹង គាត់ទាំងពីរនាក់គាត់មិននិយាយអី ក៏ថាគំរាមអី គាត់អត់គំរាមដែរ។ គាត់ទៅ គាត់និយាយល្អទេ។ គាត់ថាមិនមែនតែមិត្តឯងមួយទេ មិត្តដទៃទៀតក៏គេរៀបគ្រួសារអ៊ីចឹងដែរ រួច

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មិត្តឯងចាំប្រកែកធ្វើអីទៀត។ គាត់និយាយច្រើនណាស់ មិនដឹងស្អីៗខ្លះ ចាំមិនបានអស់។ រួចទៅ ខ្ញុំក៏ថា បើខ្ញុំប្រកែកមិនបានទេ តាមតែអង្គការទៅ ធ្វើម៉េចក៏ធ្វើទៅ។

**ស៖** ដោយសារតែលោកស្រីត្រូវតែគោរពវិន័យតឹងតែងជារៀងរាល់ថ្ងៃ អ៊ីចឹងលោកស្រីគិតក្នុងចិត្តទេថា បើសិនជាលោកស្រីចេះតែប្រកែកអ៊ីចឹង លោកស្រីនឹងមានគ្រោះថ្នាក់នោះ?

**ឆ៖** ដល់ខ្ញុំប្រកែកញយដងពេក ខ្ញុំគិតដែរ ខ្ញុំខ្លាចដែរ នឹកឃើញថាមិនដឹងម៉េចហើយ បើប្រកែកញយដងម្ល៉េះ។ រួចគេៗមិនអី តែឯងមួយប្រកែកលើសគេលើសឯង។ ក៏មិនហ៊ានប្រកែកទៀត ខ្លាចក្រែងលោមានបញ្ហាអីទៀត ក្រែងគេចោទថាម៉េចទៅ។ ព្រោះម្ដងជាពីរដង ម្ដងលើកទី១ ចោទថាខ្ញុំមានគូដណ្ដឹងនៅផ្ទះ។ លើកទី២ចោទថា ខ្ញុំហ្នឹងមានសង្សានៅក្រសួង នៅក្នុងក្រសួងជាមួយគ្នា។ ខ្ញុំថា បើចង់ដឹងទេ ឲ្យស៊ើបមើលទៅ។ អង្គការភ្នែកម្នាស់តើ ឲ្យតាមមើលទៅ។ បើសិនថា ខ្ញុំខុសសីលធម៌មែន យកខ្ញុំធ្វើអី យកទៅ ហ្នឹងលើកទី២។ ដល់លើកទី៣ទៀត បានខ្ញុំថា ដល់មកគាត់លែងសួរថា ខ្ញុំតមាត់គាត់ពេក គាត់លែងសួរខ្ញុំ។ គាត់ប្រគល់ឲ្យខ្ញុំមកផ្សារអូរឫស្សីម្ដង មកប្រធានធំម្ដង។ ដល់មក ខ្ញុំជួបតែអនុប្រធាន សមាជិកៗ ហើយអនុហ្នឹង ជួបពីរនាក់ហ្នឹង គាត់ក៏និយាយល្អដែរ។ ខ្ញុំក៏ថា បើខ្ញុំប្រកែកមិនបានទេ តាមដំណើរទៅ អង្គការធ្វើម៉េចធ្វើទៅ។ ខ្ញុំនិយាយអ៊ីចឹងហ្មងទៅ។

[១៥:២៧:៥០]

**ស៖** ខ្ញុំសូមត្រឡប់មកនិយាយអំពីពិធីរៀបអាពាហ៍ពិពាហ៍និងការប្ដេជ្ញាបន្តិច។ នេះជាចម្លើយរបស់លោកស្រីនៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីគឺ E3/5010, ជាភាសាបារាំង 01212920, ជាភាសាខ្មែរ 01003331, ជាភាសាអង់គ្លេស 01312791។ ខ្ញុំសូមដកស្រង់នូវអ្វីដែលលោកស្រីបានបំពេញនៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោកស្រី៖ "ការរៀបការនោះគឺគ្មានការរៀបចំជាពិធីអ្វីនោះទេ ហើយក៏គ្មានការចូលរួមពីឪពុកម្ដាយសាច់ញាតិបងប្អូនអ្វីនោះដែរ ដោយគេគ្រាន់តែឲ្យឡើងប្ដេជ្ញាចិត្តម្ដងមួយគូៗ ឲ្យចេះស្រឡាញ់គ្នា ខិតខំធ្វើការបម្រើឲ្យអង្គការ មិនក្បត់នឹងអង្គការ ព្រមទាំងខំបង្កើតកូនឲ្យអង្គការ។" សូមបញ្ចប់ការដកស្រង់។

ដូច្នេះលោកស្រី តើការប្ដេជ្ញាចិត្តឲ្យចេះស្រឡាញ់គ្នា ខិតខំធ្វើការបម្រើអង្គការ មិនក្បត់អង្គការ ខិតខំបង្កើតកូនឲ្យអង្គការនុ៎ង គឺជាអ្វីដែលគេឲ្យគូនីមួយៗឡើងប្ដេជ្ញានៅពេលរៀបការនុ៎ងមែនទេ?

**ឆ៖** ចាស ពេលរៀបការរួចហ្នឹង គេឲ្យឡើងមួយគូម្ដងៗ ប៉ុនមិនឡើងទាំងអស់ទេ។ គ្រាន់ថាមានតំណាង ពីរគូបីគូអីៗអ៊ីចឹងទេ។ បើឡើងទាំងអស់ វាយូរ។ ម្ល៉ោះហើយ សុខចិត្តឡើងតែពីរគូបីគូអី

ហ្នឹង ចប់ហើយ ចប់កម្មវិធីហើយ រួចប្ដេជ្ញ--

[១៥:៣០:១៧]

**ស៖** អ៊ីចឹងមានន័យថាពីរបីគូហ្នឹង តំណាងឲ្យគូផ្សេងទៀតទាំង១២ហ្នឹងមែនទេ គឺថាអ្នកដែលឡើងទៅហ្នឹងគាត់និយាយថាបម្រើអង្គការស្មោះត្រង់នឹងអង្គការ មិនក្បត់អង្គការនោះគឺតំណាងឲ្យទាំង១២គូហ្នឹងតែម្ដងមែនទេ?

**ឆ៖** ចាស ពីរគូ បីគូហ្នឹង តំណាងឲ្យទាំង១២គូហ្នឹងតែម្ដង។

**ស៖** លោកស្រីបាននិយាយថានៅក្នុងការប្ដេជ្ញាចិត្តហ្នឹងគឺថា មិនក្បត់នឹងអង្គការ។ មានន័យថាម៉េចក្បត់នឹងអង្គការហ្នឹង? អ្នកណាខ្លះដែលគេចាត់ទុកថាជាអ្នកក្បត់នឹងអង្គការហ្នឹងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** ខ្ញុំអត់ដឹងដែរ ពាក្យក្បត់ៗហ្នឹងឮតែក្បត់ ប៉ុនមិនដឹងក្បត់អីផង មិនដឹងក្បត់យ៉ាងម៉េចផង បើពួកខ្ញុំហ្នឹង ខ្ញុំទាំងអស់គ្នាមិនដឹងម៉េចក្បត់ផង។ ហើយមួយទៀត គឺខ្ញុំនៅទីក្រុងភ្នំពេញ ក៏មិនដឹងថាគេកាប់សម្លាប់ គេចាប់យកទៅណាទីអី ក៏មិនសូវ -- មិនៗមាន ដូចមិនដែលឮ ឮតែដូចថាកម្មាភិបាលគ្រប់ជាន់ថ្នាក់អ៊ីចឹង លើៗ បន្ទាប់ៗដែលទាបៗក្រោមៗហ្នឹង ជួនកាលទៅមួយអ៊ីចឹងទៅ ថាយកផ្លាស់ប្ដូរការងារ។ យកមួយទៅ ឃើញមួយមកចូលវិញទៅ គ្រាន់តែផ្លាស់ប្ដូរការងារគ្នា។ ត្រង់ថាយកទៅសម្លាប់ ទៅយកទៅណាក្បត់នឹងអង្គការអីអត់ដែលដឹងសោះ មកនៅទីក្រុងហ្នឹង អត់ដែលដឹង។

[១៥:៣២:០០]

**ស៖** ពេលរៀបការ តើគេបាននិយាយប្រាប់លោកស្រីច្បាស់ទេ ថាលោកស្រីហ្នឹងត្រូវតែរួមដំណេកជាមួយស្វាមីឲ្យបានឆាប់ដើម្បីបង្កើតកូន។ មានអ្នកណាណែនាំប្រាប់លោកស្រីអ៊ីចឹងទេនៅក្នុងពេលរៀបការនោះ?

**ប្រធានអង្គជំនុំ៖**

លោកៗស្រីដើមបណ្ដឹងរដ្ឋប្បវេណី មីក្រូហ្វូនប្រតិបត្តិការសិន ចាំឆ្លើយ។

**លោកស្រី ជា ឌៀប៖**

**ឆ៖** ពេលរៀបការហ្នឹងគឺថា អ្នកដឹកនាំហ្នឹងគាត់និយាយដែរ រឿងពាក្យអ៊ីចឹងៗគាត់និយាយថាឲ្យៗខំប្រឹងធ្វើការជូនអង្គការកុំឲ្យអង្គការពិបាកចិត្ត។ ដូចថារៀបការរួច ឲ្យចេះស្រឡាញ់គ្នា ហើយកសាងសុភមង្គលឲ្យបានល្អអ៊ីចឹងទៅ ហើយទៅកុំឲ្យដូចថាមានកូនមានចៅអ៊ីចឹងទៅ ជួយអង្គការអ៊ីចឹង

ឲ្យបានច្រើនអ៊ីចឹងទៅ។ គាត់និយាយមិននិយាយច្រើនទេ គាត់និយាយតិចៗដែរបើពេលវេលាខ្លី។

**ស៖** លោកស្រីបាននិយាយថា ពេលការហើយហ្នឹង ប៉ុន្មានយប់ដំបូងហ្នឹង គឺមានគេមកឈ្លបមើល ហើយនៅយប់ទី៤ លោកស្រីព្រមរួមដំណេក តើមានចំណុចអ្វីដែលធ្វើឲ្យលោកស្រីយល់ព្រមរួមដំណេកជាមួយស្វាមីនោះ?

**ឆ៖** យប់ទី១ យប់ទី២ យប់ទី៣ គឺថាគេឲ្យតែនៅតែបីនាក់ទេ -- បីថ្ងៃទេជាមួយគ្រួសារ។ ប៉ុន្តែក្នុងបីថ្ងៃហ្នឹងគឺឈ្លបតាមដានរាល់យប់ ខ្ញុំដេកស្ដាប់ រួចទៅទាំងគ្រួសារទាំងខ្ញុំផ្ទាល់គឺថាខ្លាចគេដែរ ចេះតែនាំគ្នាសម្ងំមិនហ៊ានមាត់មិនហ៊ាននិយាយទេ។ ដល់ពេលបីថ្ងៃហ្នឹងក៏បែកគ្នា។ បែកគ្នាត្រួតត្រាតែប្រហែលជាមួយអាទិត្យ ឬ១០ថ្ងៃទេ បានខ្ញុំមកជួបគ្នាម្ដងទៀត គេឲ្យមកជួបគ្នា ទើបខ្ញុំព្រមប្រគល់ខ្លួនឲ្យគ្រួសារខ្ញុំ។ ខ្ញុំមិនបានចាំខែចាំថ្ងៃ។

[១៥:៣៤:២៦]

**ស៖** លោកស្រីមានបាននិយាយជាមួយប្ដីលោកស្រីថាគាត់ហ្នឹងក៏ខ្លាចដែរ មិនព្រម មិនហ៊ានប្រកែកមិនព្រមរៀបការទេ លោកស្រីមានបានសួរនាំគាត់អំពីអារម្មណ៍របស់គាត់ទេ ព្រោះថាលោកស្រីមិនបានស្គាល់គាត់មុនពេលរៀបការទេ អ៊ីចឹងពេលហ្នឹង លោកស្រីមានបានសួរគាត់ថាគាត់ហ្នឹងក៏ខ្លាចមិនហ៊ានប្រកែកនឹងគេដែរ សុខចិត្តរៀបការដូចដែលលោកស្រីអ៊ីចឹងដែរ?

**ឆ៖** ខ្ញុំមិនដែលបានសួរផង អៀនរៀងតែខ្លួន គ្មានពីណាសួរពីណាទេ គេក៏មិនសួរខ្ញុំ ខ្ញុំក៏មិនសួរគេដែរ ដែលបានសួរគ្នាទេ។

**ស៖** មុននេះលោកស្រីបាននិយាយថា បើឈ្លបដឹងថាអ្នកណាមិនព្រមរួមដំណេកហ្នឹង គេបញ្ជូនទៅអប់រំកសាង។ អ៊ីចឹងក្នុងចំណោមអ្នកទាំង១២គូហ្នឹង មានអ្នកណាមិនព្រមរួមដំណេក ហើយត្រូវបានគេបញ្ជូនយកទៅអប់រំកែប្រែទេ?

**ឆ៖** ក្នុងអ្នកទាំង១២គូហ្នឹង ខ្ញុំមិនបានដឹងទេ បើដឹងនៅគូទី -- ខ្ញុំបីគូនៅជាមួយខ្ញុំ នៅជាមួយខ្ញុំបីគូ ខ្ញុំឃើញគូមួយៗអត់ត្រូវគ្នាដែរ ប៉ុន្តែពេលដែលឈ្លបតាមដាន គាត់ចេះសំងំដែរ គាត់អត់ហ៊ានមាត់ដែរ។ គាត់សំងំទាំងអស់គ្នាអត់ហ៊ានមាត់ហ៊ានកអីទេ។ ដល់ថ្ងៃក្រោយមក ដល់គេ -- គាត់ ប្ដីគាត់មិនពេញចិត្តប្រពន្ធ ប្ដីជាជនជាតិភាគតិច ប្រពន្ធខ្មែរ។ ដល់ពេលគាត់មិនពេញចិត្តអ៊ីចឹងទៅ ថ្ងៃក្រោយមកយូរខែយូរថ្ងៃដែរ យូរថ្ងៃដែរ បានប្រពន្ធគាត់ហ្នឹងរាយការណ៍ប្រាប់អង្គការ។ ប្រាប់អង្គការទៅ អង្គការយកគាត់ទៅអប់រំ អប់រំម្ដងជាពីរដងអ៊ីចឹង។ អប់រំពីរបីដង គាត់នៅតែមិនព្រមយក គាត់មិនស្រឡាញ់

មនុស្សស្រីហ្នឹងទេ គាត់ប្រុសទេ អត់ស្រឡាញ់ស្រីនោះ។ ដល់ពេលយូរទៅ ដល់ញយដងពេក ខាងប្រុសហ្នឹង គាត់ឆ្លើយថាប្រដាប់គាត់ងាប់។ ដល់ឆ្លើយថាប្រដាប់គាត់ងាប់ ពេទ្យហ្នឹងយកទៅព្យាបាលនៅត្រង់ គ-៩ ហ្នឹង នៅមន្ទីរ គ-៩ ហ្នឹង យកទៅព្យាបាលនៅហ្នឹង ហើយឲ្យប្រពន្ធហ្នឹងទៅនៅប្រើ ទៅបម្រើដឹងប៉ុន្មានថ្ងៃ ខ្ញុំមិនបានដឹងទេ គ្រាន់តែដឹងថា គាត់ទៅដេកពេទ្យហ្នឹងទាំងប្ដីទាំងប្រពន្ធហ្នឹង។ ដល់ក្រោយមកទៀត ក៏ប្ដីហ្នឹងគេអប់រំច្រើនដងទៀត គាត់ក៏ព្រមយកប្រពន្ធហ្នឹងទៅ។ ហ្នឹងតាមខ្ញុំដឹង។ យកប្រពន្ធហ្នឹងទៅ ក្រោយមកគាត់មានកូន ពោះធំៗបានកូនមួយ កូនប្រុស។ រយៈកូនហ្នឹងមិនទាន់ចេះដើរផងប្រពន្ធនុំងក៏ស្លាប់ទៅ។ ហើយបងប្រុសហ្នឹងគាត់នៅដឹកជញ្ជូនជើងគោក នារីនៅខាងកាត់ដេរ។

[១៥:៣៧:០៩]

ដល់ពេលបងស្រីហ្នឹងស្លាប់ទៅ កូននុំងក៏ដោយទៅប្រធានគាត់ដឹកជញ្ជូនជើងគោកទៅ បងប្រុសនុំងគាត់អត់យកខ្លួនគាត់ទេ គាត់ថាគាត់លំបាក មិនដឹងមានពីណាមើល គាត់អាល័យតែធ្វើការ ហើយប្រធានដឹកជញ្ជូនគាត់ហ្នឹងជាស្រី ប្រពន្ធកម្មាភិបាលក៏មិនដឹងអីក៏មិនដឹងទេ ប៉ុន្តែគាត់ឲ្យទៅបងស្រីនុំងទៅកូនគាត់នោះ។ ហ្នឹងខ្ញុំដឹងប៉ុណ្ណឹង។ អ្នកដែលមិនត្រូវគ្នា ខ្ញុំដឹងមួយហ្នឹងទេ។ ហើយគូផ្សេងទៀត ខ្ញុំអត់ដឹងទេ នៅឆ្ងាយៗពីគ្នា។

**ស៖** នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោកស្រី គឺ E3/5010 ជាភាសាខ្មែរ 01003331 គឺដូចទំព័រដែលខ្ញុំបានដកស្រង់មុននឹងដែរ ហើយជាភាសាអង់គ្លេស 01312791, ជាបារាំង 01212920។ លោកស្រីបានរៀបរាប់ថា "ខ្ញុំបង្ខំចិត្តរួមរស់ជាមួយនឹងប្ដីខ្ញុំ ព្រោះថាមានតែធ្វើបែបនេះទេ ទើបអាចរក្សាជីវិតបាន។" អ៊ីចឹងមានន័យថា ពេលនុំងគឺលោកស្រីខ្លាចមែនទែន បើលោកស្រីមិនព្រមរួមដំណេកទេ គេនឹងសម្លាប់ចោល។ លោកស្រីពិតជាខ្លាចអ៊ីចឹងមែនទេ?

[១៥:៣៨:៥០]

**ឆ៖** នាងខ្ញុំខ្លាចមែននុំង បើមិនខ្លាចណា បើគេបង្ខំហើយ ហើយដល់រៀបការហើយនៅតែមិនព្រមទៀត ក៏ខ្លាចដែរនុំង។ ដឹងគេយកសម្លាប់ យកធ្វើអីអត់ដឹង ប៉ុន្តែចេះតែខ្លាចទៅ។

**ស៖** នៅក្នុងរបបខ្មែរក្រហម <ឬនៅពេលក្រោយមកទៀត>តើលោកស្រីមានផ្ទៃពោះទេ?

**ឆ៖** ក្នុងរបបខ្មែរក្រហមនាងខ្ញុំផ្ទាល់អត់មានផ្ទៃពោះទេ រហូតទាល់ខ្ញុំទៅដល់ស្រុកកំណើតខ្ញុំវិញ បានមាន។ ជំនាន់ខ្មែរក្រហមអត់មានសោះ។

**ស៖** អម្បាញ់មិញនេះ លោកស្រីបាននិយាយថា គេឲ្យរៀបការដើម្បីបង្កើតកូនឲ្យបានច្រើន

ហើយលោកស្រីបានជួបប្ដីហ្នឹងតែមួយខែ ឬក៏ពីរខែម្ដងទេ។ អ៊ីចឹងលោកស្រីមិនគិតថា ដូចជាចម្លែកទេ ឬ បើគេប្រាប់ថាឲ្យខិតខំបង្កើតកូនឲ្យអង្គការឲ្យបានច្រើន ក៏ប៉ុន្តែគេឲ្យជួបប្ដីហ្នឹងយូរៗម្ដង មួយខែឬក៏ពីរខែហ្នឹងម្ដង មិនរស់នៅដូចជាប្ដីប្រពន្ធធម្មតាទេ?

**ឆ៖** ចាស ធ្វើម៉េចបានអ៊ីចឹង ខ្ញុំវាគ្មាន ខ្ញុំមិនដឹងធ្វើម៉េចដែរ ព្រោះអត់រហូតទៅហើយ។

[១៥:៤០:៤៦]

**ស៖** លោកស្រីធ្លាប់ឮថា ក្រៅពីគូទាំង១២ហ្នឹង មានគូណាផ្សេងទៀត ដែលមានអាយុពី១៨ឆ្នាំ <ទៅ២៥ឆ្នាំ>ហ្នឹង ឧទាហរណ៍ដូចជានៅក្នុង នៅកន្លែងជយភណ្ឌ ឬក៏កន្លែងកាត់ដេរ នៅផ្សារអូរឫស្សីហ្នឹង តើមានគេរៀបការផ្សេងទៀតទេ?

**ឆ៖** មានតើ អាយុច្រើនដូចបង ដែលខ្ញុំនិយាយថា អត់ត្រូវគ្នាហ្នឹង គាត់ហ្នឹង២៦ដូចគ្នា ហើយបើផ្សេងៗទៀត ដែលរៀបការក្រោយៗខ្ញុំមកដឹងតើ ខ្លះមាន៣០, ៣៥, ៤០ យុទ្ធជន៤០ជាង នារី៣០, ៣០ជាងអី មានតើ។ ឃើញតែរៀបមួយសាខ្ញុំហ្នឹង ច្រើនតែមានក្មេង បើថារៀបក្រោយៗ សុទ្ធតែចាស់ៗ។

**ស៖** លោកស្រីបាននិយាយអំពីលក្ខខណ្ឌការងារនៅផ្សារអូរឫស្សី នៅក្នុងពាក្យសុំ គឺក្នុងទម្រង់ព័ត៌មានបន្ថែមរបស់លោកស្រី គឺឯកសារ E3/5010a ទំព័រជាភាសាបារាំង 01030100, ជាភាសាខ្មែរ 01003331, ជាភាសាអង់គ្លេស 01137888។ លោកស្រីបាននិយាយដូចតទៅ៖ "នៅពាក់កណ្ដាលឆ្នាំ៧៦ គេបញ្ជូនខ្ញុំទៅខាងកាត់ដេរនៅផ្សារអូរឫស្សី ហើយខ្ញុំត្រូវធ្វើខោអាវ គេបង្ខំឲ្យដេរខោអាវខ្មៅហ្នឹងក្នុងមួយថ្ងៃហ្នឹងឲ្យបានដេរសំពត់ឲ្យបាន១០០ <និង>អាវ<១២។> ហើយមានអ្នកខ្លះហ្នឹង ដេរមិនហើយ អ្នកខ្លះខ្យល់គរ ខ្លះសន្លប់ដោយការហត់ហេវ គ្មានអីហូប ហូបតែនំប៉័ងមួយថ្ងៃ មួយ"។ ដូច្នេះ ខ្ញុំចង់ដឹងថាក្នុងចំណោមអ្នកទាំងអស់ហ្នឹង តើមានអ្នកណាដែលមិនមករដូវទេ?

[១៥:៤៣:២៣]

**ឆ៖** ក្នុងចំណោមក្នុងនារីទាំងអស់ ភាគច្រើន ច្រើនមាន ច្រើនអ្នកកើតឫដូង ឫដូងបាត។ នារីៗហ្នឹង ច្រើនកើតឫដូងបាតនៅក្នុងមន្ទីរកាត់ដេរហ្នឹង។ ហើយពេលដែលហត់ហេវខ្លាំង សម្រុកខ្លាំងហ្នឹង មានថ្ងៃមួយ លោកៗអ៊ំ ប៉ុល ពត គាត់បានទៅដល់នៅកន្លែងកាត់ដេរហ្នឹង។ គាត់ទៅដល់កន្លែងកាត់ដេរ ខ្ញុំកំពុងអង្គុយដេរអ៊ីចឹង គាត់ទៅដល់ឈរពីមុខខ្ញុំ ឈរពីមុខខ្ញុំ គាត់សួរថា "មិត្តនារី នំប៉័ងមួយថ្ងៃមួយ ហូបឆ្អែតដែរ? ខ្ញុំថាអ៊ំអើយ ហូបអត់ឆ្អែតទេ មួយថ្ងៃមួយនោះ ព្រោះ បើនារីឆ្អែត បើយុទ្ធជន

01364581



អត់ឆ្អែត រួចណាគ្មានបន្លែ គ្មានម្ហូប -- អ៊ំ! គ្មានម្ហូបហូបជាមួយទេ បើមានបានបន្លែត្រកួនមក សម្លម្ជូរត្រកួនទៅ បើអត់ត្រកួន អត់បន្លែអីទេ នាំគ្នាចុចប្រហុកនំប៉័ងប៉ុណ្ណឹង រួចហូបអត់ឆ្អែតទេ អ៊ំអើយ។" ដល់ខ្ញុំប្រាប់គាត់អ៊ីចឹង គាត់ថា អ៊ីចឹងហ៎! គាត់សួរបញ្ជាក់ខ្ញុំតែប៉ុណ្ណឹង ក៏គាត់ដើរចេញទៅ ស្រាប់តែស្អែកឡើងគាត់ឲ្យមួយថ្ងៃពីរៗ នំប៉័ង គាត់ឲ្យហូបមួយថ្ងៃពីរ ឈប់ឲ្យហូបមួយថ្ងៃមួយហើយ។ ពីដើមមួយព្រឹកតែមួយកំណាត់ ល្ងាចមួយកំណាត់ទេ។ ហ្នឹងខ្ញុំជួបជាមួយអ៊ំ ប៉ុល ពត ផ្ទាល់តែម្ដង គាត់មកសួរមុខហ្នឹង។

[១៥:៤៤:៤៥]

**ស៖** លក្ខខណ្ឌការងារ និងរបបអាហារហ្នឹង គឺថាមានលក្ខណៈខ្សត់ខ្សោយ ធ្វើឲ្យឃ្លាន។ អ៊ីចឹងខ្ញុំចង់ដឹងថា លោកស្រីជាអ្នកនៅ -- ពីមុនជាអ្នកនៅភ្នំពេញ លោកស្រីជាអ្នកនៅភ្នំពេញ និងលោកស្រីជាកម្មករអ៊ីចឹង តើគេមានប្រាប់ថាលោកស្រីហ្នឹងហើយ គឺជាអ្នកឈានមុខ គេមានប្រាប់អ៊ីចឹងទេ?

**ឆ៖** អត់មានប្រាប់អីផង។ គ្រាន់តែថាធ្វើការអីធ្វើទាំងអស់គ្នា ស្មើទាំងអស់គ្នា គ្មានអ្នកណាឈានមុខអ្នកណា អត់ឮ គាត់អត់និយាយទេ។

**ស៖** ឥឡូវនេះខ្ញុំចូលទៅប្រធានបទថ្មីមួយទៀត។ លោកស្រីបាននិយាយពីការដែលលោកស្រីទៅធ្វើការកាត់ដេរនៅឫស្សីកែវ។ អ៊ីចឹងខ្ញុំចង់ដឹងថាលោកស្រីចាកចេញពីផ្សារឫស្សីកែវទៅកន្លែងផ្សេងទៀតហ្នឹងនៅពេលណា? ហើយហេតុអីបានជាគេដកលោកស្រីចេញពីកន្លែងកាត់ដេរទៅនៅកន្លែងផ្សេង?

**ឆ៖** នៅឆ្នាំ១៩៧៨ ខែ២ គេបានដកខ្ញុំពីទីក្រុងភ្នំពេញទៅ។ មុនដំបូងគេដកប្ដីៗទេ ដកទៅមួយឡាន ថាយកទៅឲ្យធ្វើការឲ្យ -- អ៊ំ! ធ្វើផ្ទះឲ្យអង្គការ។ ស្រាប់ទៅពីព្រឹកអ៊ីចឹង យកប្ដីៗទៅ ស្រាប់តែល្ងាចឡើងថ្ងៃរសៀល ឃើញវាយកប្រពន្ធៗទៀត រួចទៅថាឲ្យយកទៅនៅជាមួយ។ ដល់ពេលយកទៅហ្នឹង យកពួកខ្ញុំទៅហ្នឹង ពួកប្រុសៗហ្នឹងប្ដីៗហ្នឹង យកទៅដាក់ស្ទឹងកន្ទួត គេហៅស្ទឹងកន្ទួតហ្នឹងនៅតាមមាត់ស្ទឹង។

[១៥:៤៦:៣០]

ហើយថ្ងៃមួយហ្នឹង ដល់ពេលថ្ងៃល្ងាចឡើងខ្ញុំទៅតាមក្រោយទៀត ទៅដល់កន្លែងហ្នឹង ទៅដល់ស្ទឹងកន្ទួតហ្នឹង ឃើញថា ពូៗនៅហ្នឹងមែន ហើយកន្លែងស្ទឹងកន្ទួតហ្នឹងឃើញសុទ្ធតែចិនៗ។ ចិនហ្នឹងដល់ខ្ញុំសួរគេថាចិនមកពីណាមក ខ្លះពុកមាត់ត្រឹមៗចង្កេះ ត្រឹមទ្រូង ចាស់ៗ។ រួចថាចិនមកពីណាមក? គេថាចិនរោងចក្រភ្នំពេញ។ រួចទៅគេប្រាប់ខ្ញុំថាចិនរោងចក្រហ្នឹងពីដើម ពីសង្គមមកគាត់នៅធ្វើការរោង

ចក្រ ដល់ពេលដាច់មក ប៉ុល ពត – ប៉ុល ពត ឲ្យនៅក្នុងរោងចក្រហ្នឹងអត់ឲ្យចេញទេ។ ដល់ពេលឥឡូវហ្នឹង ដល់ពួកចិនហ្នឹងបង្រៀនពួកខ្មែរក្រហមចេះទៅ ត្រូវដកចិនៗហ្នឹងចេញ។ ខ្ញុំឮគេនិយាយអ៊ីចឹង អាហ្នឹងខ្ញុំសួរគេនៅកន្លែងស្ទឹងកន្ទួត។ ខ្ញុំទៅនៅហ្នឹងបានប្រហែលមួយអាទិត្យ អត់មានការងារធ្វើគេទៅដល់ហ្នឹង គេសួរខ្ញុំថា មូលហេតុអីបានគេដកចេញពីទីក្រុងភ្នំពេញ? រួចកន្លែងគេសួរចម្លើយមានបន្ទប់មួយ។ បន្ទប់មួយមានកាំបិតមាន ពូថៅ មានចប មានច្រវាក់ មានខ្នោះ។ រួចទៅគេហៅពួកខ្ញុំទៅសួរចម្លើយថា៖ "មូលហេតុអីបានគេដកចេញពីទីក្រុងភ្នំពេញ?" ពួកខ្ញុំឆ្លើយថា៖ "អត់ដឹង ខ្ញុំអត់ដឹងផង គេដកមកខ្ញុំអត់ដឹងផង"។ រួចដល់ទៅអ្នកដែលសួរចម្លើយនឹងគេប្រាប់ថាជាប់ឥទ្ធិពលអ្នកដឹកនាំ គេកត់ក្នុងបញ្ជីគេ គេដាក់អ៊ីចឹងទៅ។ គេថាតែចាប់ដឹកនាំទៅ អ្នកក្រោមគេចាប់បណ្ដើរៗអ៊ីចឹងហើយ។ អាហ្នឹងគាត់ប្រាប់អ៊ីចឹងតែប៉ុណ្ណឹង។ រួចរយៈកាលមួយអាទិត្យក្រោយមក ក៏គេដកខ្ញុំពីស្ទឹងកន្ទួតមកវត្តស្លែង មកនៅវត្តស្លែង មកធ្វើស្រែដកស្ទូង ភ្ជួរស្រែ ជីកអាង លើកទំនប់ នៅនឹងវត្តស្លែងហ្នឹង។

[១៥:៤៨:១៣]

**ស៖** សំណួរមួយពាក់ព័ន្ធនឹងបញ្ហានេះ តើគេចោទលោកស្រីថាមានទំនាក់ទំនងជាមួយខ្សែខាង លន់ នល់ ដែរឬទេ ឬក៏ជាមួយមេដឹកនាំខាងភូមិភាគឧត្តរដែរឬទេ? គឺជាប់ខ្សែ កុយ ធួន ហៅ ធុច ដែលយើងនិយាយថាខាងដើមហ្នឹងឬទេ?

**ឆ៖** ខ្ញុំអត់ដឹងផង គ្រាន់គេអត់មានថាអី គ្រាន់ថាជាប់ឥទ្ធិពលអ្នកដឹកនាំ។ ប៉ុនមិនមែនខ្ញុំម្នាក់ណាទូទៅពីរឡានទៅទៀត ឆ្លើយអ៊ីចឹងទាំងអស់គ្នាៗ គេដាក់អ៊ីចឹងទៅ អត់ដឹងទាំងអស់គ្នា។

**ស៖** នៅក្នុងទម្រង់ព័ត៌មានបន្ថែម គឺ <E3/5010a>, បារាំង <01030101>, អង់គ្លេស <01137888>, ខ្មែរ 01003332។ ពិបាកក្នុងការអានថាភាសាខ្មែរបន្តិច ប៉ុន្តែលោកនិយាយថាខ្មែរក្រហមបានបញ្ជូនលោកស្រីទៅចោមចៅ ហើយនិងទៅវត្ត<ជ្រៃដុំ>មុនគេបញ្ជូនទៅពេជនិល។ ហើយលោកស្រីបន្ថែមថា "វត្តនេះគឺឋិតនៅក្រោមការត្រួតត្រារបស់ លោក ខៀវ សំផន ផ្ទាល់"។ តើនៅវត្តនោះគេឲ្យលោកស្រីធ្វើអ្វី? តើវត្ត<ជ្រៃដុំ>កន្លែងនោះ គេប្រើធ្វើជាអ្វីដែរ?

**ប្រធានអង្គជំនុំ៖**

លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយ!

សូមអញ្ជើញលោកស្រីមេធាវីការពារលោក ខៀវ សំផន!

**លោក សេង លាង៖**

លោកប្រធាន ខ្ញុំសុំបញ្ជាក់បន្តិច អំមិញអ្នកបកប្រែគាត់បកថា វត្តស្រែធំ តាមពិតវត្តជ្រៃធំ ជ័យឧត្តម។

**កញ្ញា អង់តា ហ្គីសសេ៖**

ចាស គឺថាកំណត់សម្គាល់ខ្លីមួយ ដើម្បីផ្តល់សេចក្តីដកស្រង់ទាំងស្រុង ពីព្រោះ<ព្រះរាជអាជ្ញាដកស្រង់នេះ>មិនពេញលេញទេ។ ដើមបណ្តឹងរដ្ឋប្បវេណីនិយាយថា តាមព័ត៌មានបន្ថែមថាវត្តនោះស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោក ខៀវ សំផន ប៉ុន្តែ<ដើមបណ្តឹងរដ្ឋប្បវេណីនិយាយថា "យ៉ាងហោចណាស់ នេះជា>អ្វីដែលខ្ញុំបានឮ" អ៊ីចឹងគឺសំខាន់ត្រូវបន្ថែមចំណុចបញ្ជាក់ឲ្យបានច្បាស់ បន្ថែមលើករណីនេះ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៏ ដេស្នាឯល៖**

**ស៖** បាទ ជាសេចក្តីផ្តើមរបស់ខ្ញុំទេ អ៊ីចឹងថាតើ<លោកស្រីត្រូវ>ធ្វើអ្វី<ពេលលោកស្រីនៅទីនោះ>? តើ<វត្តជ្រៃធំ>ហ្នឹងគឺគេប្រើធ្វើអ្វីដែលនៅជិតចោមចៅនៅពេលនោះ?

[១៥:៥១:៣១]

**លោកស្រី ជា ឌៀប៖**

**ឆ៖** ខ្ញុំសូមជម្រាបលោកប្រធានថា កាលពីខ្ញុំទៅនៅ ដូចថាដកខ្ញុំទៅដំបូងនៅស្ទឹងកន្ទួត។ ស្ទឹងកន្ទួតបានប្រាំពីរថ្ងៃ ដកខ្ញុំមកនៅវត្តស្លែង។ ដកពីវត្តស្លែងទៅ គេចាប់អ្នកមេដឹកនាំវត្តស្លែងបាត់ទៅ គេដកពួកខ្ញុំទៅនៅតាមសហករណ៍។ នៅតាមសហករណ៍ខាងបែកចាន នៅស្រុកសំរោងទង ខាងបែកចានហ្នឹង។ ដល់នៅមួយរយៈ ថ្ងៃមួយពេលទៅនៅប៉ុន្មានខែក្រោយមក ចេះតែបាត់ពួកមិត្ត ដូចថា នៅចែកគ្នាតាមភូមិ មួយភូមិគេដាក់ពីបួនប្រាំនាក់ មួយភូមិបួនប្រាំនាក់អ៊ីចឹងទៅ យកពួកខ្ញុំទៅដាក់។ ដល់ពេលថ្ងៃក្រោយមក ចេះតែបាត់ពួកខ្ញុំ បាត់ពីនៅភូមិឯជើងឃើញបាត់មួយ នៅភូមិឯលិចបាត់មួយ។ ដល់ពួកខ្ញុំភ័យខ្លាច ថ្ងៃនុំងនាំគ្នារត់ នាំគ្នារត់ពីសហករណ៍ស្រុកសំរោងទងហ្នឹងចុះមកចូលវត្តជ័យឧត្តម។ ប៉ុនខ្ញុំឮគេនិយាយទេ ប៉ុនខ្ញុំមិនបានជួប មិនដែលជួបលោក ខៀវ សំផន។ គ្រាន់គេនិយាយថា វត្តជ័យឧត្តមហ្នឹងក្រោមការគ្រប់គ្រងរបស់លោក ខៀវ សំផន។ ប៉ុនខ្ញុំមកនៅប្រហែលមួយខែ ក៏ខ្ញុំមិនដែលឃើញគាត់ដែរ។ ខ្ញុំឃើញតែកូនចៅនៅហ្នឹង ភ្លូរាស់ ដកស្នួងនៅហ្នឹង។ បើថារឿង ចំពោះគាត់ហ្នង ខ្ញុំអត់ដែលឃើញទេ។ អាហ្នឹង សូមជម្រាបប៉ុណ្ណឹង នៅវត្តជ័យឧត្តម។

01364584



**សៈ** ក្រៅពីធ្វើស្រែ តើលោកស្រីត្រូវធ្វើអីទៀត នៅពេលដែលនៅ<ទី>នោះ? តើគេឲ្យផលិតអ្វីធ្វើអ្វីដែរឬទេ នៅវត្តជ័យឧត្តមនោះ បាទ?

[១៥:៥៣:១៨]

**ផះ** នៅវត្តជ័យឧត្តមកន្លែងនំុង ខែប្រាំង ជីកស្រះ ជីកអាង លើកទំនប់។ ដល់ពេលខែវស្សានាំគ្នាដកស្ទូង។ ហើយខ្ញុំនៅត្រឹមបានមួយវស្សាហ្នឹង គ្រាន់ដកស្ទូងរួចហ្នឹង ក៏គេដកខ្ញុំទៅភ្នំពេជនិលទៅដកពួកខ្ញុំមួយចំនួនទៅនៅកាប់ព្រៃនៅភ្នំពេជនិល។

**សៈ** តើលោក<ស្រី>ដឹងពីមូលហេតុអ្វីដែលគេនិយាយថា ខៀវ សំផន ជាអ្នកគ្រប់គ្រង ឬក៏មើលការខុសត្រូវកន្លែងហ្នឹងដោយផ្ទាល់<ទេ>?

**ផះ** មានថ្ងៃមួយថ្ងៃចូលឆ្នាំ ខ្ញុំទៅលេងនៅវត្តនំុង។ ខ្ញុំគេអត់បើកឲ្យដើរលេងនៅតាមសហ-ករណ៍។ ហើយវត្តជ័យឧត្តមក៏ធ្លាប់មានពួកមិត្តដែលចេញពីភ្នំពេញទៅនៅនឹងវត្តជ័យឧត្តមហ្នឹងច្រើនដែរ។ ដល់ខ្ញុំដើរមកលេងហ្នឹងទៅ និយាយពីការពិបាកវេទនានៅតាមសហករណ៍ហ្នឹងទៅ ក៏ពួកហ្នឹងថាឲ្យរត់មក ឲ្យនាំគ្នាលួចរត់។ ដល់ទៅក៏ ថ្ងៃមួយថ្ងៃចូលឆ្នាំថ្ងៃបង្ហើយ ពួកខ្ញុំលួចរត់មែន។ លួចរត់ពីសហករណ៍ស្រុកសំរោងទងហ្នឹង មកចូលវត្តជ័យឧត្តម។ រួចខ្ញុំគ្រាន់ឮទេ ឮគ្រាន់គេថា វត្តហ្នឹង កន្លែងហ្នឹងដែលក្រោមការគ្រប់គ្រងរបស់លោក ខៀវ សំផន។ ប៉ុនត្រង់ខ្ញុំទៅលេង ក៏ខ្ញុំមិនដែលជួប ដល់ពេលខ្ញុំមកនៅហ្នឹង ក៏មិនដែលជួបគាត់ដែរ មិនដែលឃើញគាត់ដែរ គ្រាន់ឮគេថា។ រួចមើលទៅកន្លែងហ្នឹងអត់មានពីណាប៊ានចូលមែន ពួកសហករណ៍សហាអីអត់ប៊ានចូលទេ។ ពួកស្រុកពួកអីអត់ប៊ាន ដែលប៊ានចូលកន្លែងហ្នឹងទេ។

[១៥:៥៥:១២]

**សៈ** នៅពេលដែលលោកស្រីនៅវត្តនេះ តើអ្នករួមការងាររបស់លោកស្រីណាមានបាត់ខ្លួនដែរឬទេ?

**ផះ** ខ្ញុំមកនៅវត្តហ្នឹងប្រហែលមួយខែ ប៉ុន្តែអត់មានដែលបាត់ខ្លួនទេ។ ហើយប្រធាននៅកន្លែងនោះកំបុតដៃមួយចំហៀង ប្រធាននៅកន្លែងទទួលខុសត្រូវនៅកន្លែងវត្តជ័យឧត្តមហ្នឹង។

**សៈ** សំណួរចុងក្រោយរបស់ខ្ញុំ។ លោកស្រីបាននិយាយពីខាងដើម ពីទស្សនកិច្ចរបស់ ប៉ុល ពត ទៅអង្គភាពតម្បាញ។ តើមេដឹកនាំផ្សេងទៀតទៅជាមួយគាត់ដែរឬទេ? តើគាត់ទៅជាមួយជនបរទេសដែរឬទេកាលនោះ? ហើយតើលោកស្រីក៏បានឃើញមេដឹកនាំជាន់ខ្ពស់ផ្សេងទៀតទេនៅក្នុងឱកាស

ផ្សេងៗទៀតនៅពេលដែលលោកស្រីធ្វើការនៅខាងផ្នែកតម្បាញនៅផ្សារអូរឫស្សីនោះ? អ៊ីចឹងគឺថាមានទស្សនកិច្ចរបស់ ប៉ុល ពត តើមានអ្នកណាអមដំណើរ ហើយបរទេសមានទៅជាមួយទេ? តើមានឱកាសប៉ុន្មានដងដែលលោកស្រីបានឃើញការធ្វើទស្សនកិច្ចបែបនោះ?

**ឆ៖** ខ្ញុំបានជួបលោកតា ប៉ុល ពត ជួបតែម្តងហ្នឹងទេ។ គាត់ទៅឃើញៗមានតែអង្គរក្ស ហើយនិងគាត់ដើរទេ គាត់អត់មានឃើញជិះអីទេ ឃើញដើរ ឃើញគាត់ដើរពីកើតមកៗដល់កន្លែងខ្ញុំហ្នឹង គាត់ចូលសួរ ហើយគាត់ចូលសួររួចទៅ ក៏គាត់ដើរទៅលិចទៀតទៅ ប៉ុនអត់ឃើញមានជនបរទេសមានអីអត់ ឃើញម្នាក់គាត់ ហើយនិងឃើញអង្គរក្សដើរប៉ុន្មានពីរបីនាក់តាមក្រោយ។ អត់មានឃើញមានអ្នកណាទៀតទេ។

**ស៖** តើហេតុអ្វីក៏លោកស្រីដឹងថា គាត់នោះជា ប៉ុល ពត?

[១៥:៥៧:៣៩]

**ប្រធានអង្គជំនុំ៖**

លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី មីក្រូហ្វូនប្រតិបត្តិការសិន ចាំឆ្លើយ។

**លោកស្រី ជា ខៀប៖**

**ឆ៖** ទោះបីថាមិនដែលស្គាល់គាត់ ក៏រាងប្រហាក់ប្រហែលដែរ ព្រោះគាត់ធ្លាប់ឃើញក្នុងកុន ធ្លាប់ពេលបញ្ចាំងកុន គាត់ទៅទស្សនកិច្ចនៅប្រទេសកូរ៉េអីនោះ ហើយគេយកកុនមកបញ្ចាំងឲ្យមើលទៅស្គាល់តាមរយៈកុនហ្នឹងដែរ។ បើថាជួបផ្ទាល់ ខ្ញុំបានជួបតែម្តងហ្នឹងទេ។

**លោក វាំងសង់ វ៉ាយឌ័ ដេស្នាឯល៖**

**ស៖** បាទ សូមអភ័យទោស មុននឹងបញ្ចប់ ខ្ញុំសូមសួរសំណួរមួយចំនួនទៀតគឺទាក់ទងនឹងលោក ខៀវ សំផន។ លោកស្រីបានឃើញគាត់ពីរដង លោកស្រីថាបានឃើញនៅពេលដែលគាត់មកប្រជុំ។ តើហេតុអ្វីបានជាលោកស្រីស្គាល់ថាគាត់ជា ខៀវ សំផន ដឹងដោយរបៀបណា? តើគេប្រកាស ឬគាត់ណែនាំខ្លួន ឬក៏គេប្រាប់លោកស្រីថាគាត់ជា ខៀវ សំផន ឬក៏លោកស្រីគ្រាន់តែគិតខ្លួនឯងថាគាត់ហ្នឹងជា ខៀវ សំផន?

[១៥:៥៨:៥៥]

**ឆ៖** លោក ខៀវ សំផន មិនថាគេប្រាប់ថា ខៀវ សំផន ប៉ុនចំពោះខ្ញុំស្គាល់ ក៏រាងប្រហែលតាំងពីដើមមក ដូចធ្លាប់ស្គាល់ឯណាទេ នឹកឃើញថាដូចធ្លាប់ឃើញគាត់ឯណា។ ប៉ុនដល់ឃើញគាត់ ខ្ញុំដឹងថា

គាត់ ខៀវ សំផន ហ្នឹង ប៉ុនគាត់ពីដើម គាត់រាងល្អិត ស្គមទេ គាត់មិនមែនសាច់ទេ កាលពីជំនាន់ខ្មែរក្រហម គាត់ពាក់តែអាវដៃខ្លី ស្លៀកខោកៅស៊ូ កន្ទេវ១ហ្នឹងគាត់នោះ មួយជំនាន់នៅខ្មែរក្រហមនោះ គាត់មានស្លៀកពាក់អីទេ មានតែអាវខ្មៅដៃខ្លីហ្នឹង ខោខ្មៅដាក់កៅស៊ូហ្នឹង។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណដើមបណ្ដឹងរដ្ឋប្បវេណីចំពោះការប្រឹងប្រែងឆ្លើយសំណួរខ្ញុំ ខ្ញុំមិនមានសំណួរអ្វីទៀតទេលោកប្រធាន បាទ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកព្រះរាជអាជ្ញា។ ឥឡូវដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការនឹងបន្តធ្វើនៅថ្ងៃស្អែកថ្ងៃពុធ ទី៣១ ខែសីហា ឆ្នាំ២០១៦ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។

លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណីសវនាការស្ដាប់សក្ខីកម្មរបស់លោកស្រីមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកស្រីមកបន្តផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀត។

សវនាការនៅថ្ងៃស្អែក អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីលោកស្រី ជា ឌៀប បញ្ចប់ ហើយនិងចាប់ផ្ដើមស្ដាប់សក្ខីកម្មសាក្សី 2-TCW-914។ សូមភាគីជ្រាបនិងអញ្ជើញចូលរួមតាមពេលដែលបានកំណត់។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោកនួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃុំឃាំងនៃអ.វ.ត.ក វិញ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃពុធ ទី៣១ ខែសីហា ឆ្នាំ២០១៦ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

អញ្ជើញសម្រាក៕

*(សវនាការផ្អាកនៅម៉ោង ១៦:០១ នាទី)*

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*